# Massachusetts

# ព័ត៌មាន
# អ្នកបោះឆ្នោត

## សំណួរអំពីសន្លឹកឆ្នោត 2018

## ការបោះឆ្នោតរដ្ឋ

### ថ្ងៃអង្គារទី 6 ខែវិច្ឆិកា ឆ្នាំ 2018

**សំណុំបែបបទផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍សម្រាប់ការចុះឈ្មោះអ្នកបោះឆ្នោតបានភ្ជាប់ជូន!**

រដ្ឋម៉ាសាឈូសេត Massachusetts ចុះឈ្មោះបោះឆ្នោតតាមអនឡាញ

**registertovotema.com**

*បោះពុម្ពផ្សព្វផ្សាយដោយ*

**William Francis Galvin**

លេខាធិការសហគមន៍ឯករាជ្យ

# The Commonwealth of Massachusetts

## Secretary of the Commonwealth

State House, Boston, Massachusetts 02133

*William Francis Galvin*
*Secretary of the Commonwealth*

ជូនចំពោះអ្នកបោះឆ្នោតជាទីគោរពរាប់អាន ៖

នៅថ្ងៃអង្គារទី 6 ខែវិច្ឆិកា ឆ្នាំ 2018 អ្នកបោះឆ្នោតនៅរដ្ឋម៉ាសាឈូសេត Massachusetts មានឱកាសជ្រើសរើសបេក្ខជនពី
ជម្រើសរបស់ពួកគេ ហើយសម្រេចចិត្តចំពោះសំណួរអំពីសន្លឹកឆ្នោតទូទាំងរដ្ឋ ដែលអាចផ្លាស់ប្តូរច្បាប់រដ្ឋ ។ ទីកន្លែងបោះឆ្នោតបើក
ដំណើរការចាប់ពីម៉ោង 7:00 ព្រឹកដល់ 8:00 ល្ងាចនៅទូទាំងរដ្ឋនៅថ្ងៃបោះឆ្នោត ។ **ការបោះឆ្នោតមុនអាចប្រព្រឹត្តទៅបានចំពោះ**
**ការបោះឆ្នោតនេះ ដោយចាប់ផ្តើមពីថ្ងៃទី 22 ខែតុលា ឆ្នាំ 2018 និងបញ្ចប់នៅថ្ងៃទី 2 ខែវិច្ឆិកា ឆ្នាំ 2018 ។** ប្រសិនបើលោក
អ្នកមិនអាចទៅស្ថានីយបោះឆ្នោត ឬបោះឆ្នោតមុននោះ សន្លឹកឆ្នោតបោះមុនដែលមិនអាចទៅស្ថានីយបោះឆ្នោតអាចប្រព្រឹត្តទៅបាន
យ៉ាងងាយស្រួលនៅមុនការបោះឆ្នោត ។

ប្រសិនបើលោកអ្នកមិនទាន់ចុះឈ្មោះបោះឆ្នោត ឬត្រូវការចុះឈ្មោះឡើងវិញ ដោយសារតែលោកអ្នកបានផ្លាស់ប្តូរទីលំនៅនោះ យើងខ្ញុំ
បានភ្ជាប់សំណុំបែបបទសម្រាប់លោកអ្នក ដើម្បីបំពេញ និងផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ត្រឡប់មកវិញ ឬប្រសិនបើលោកអ្នកមានប័ណ្ណ
បើកបរ ឬប័ណ្ណសម្គាល់ខ្លួននៅរដ្ឋម៉ាសាឈូសេត Massachusetts នោះ លោកអ្នកអាចចុះឈ្មោះបោះឆ្នោតបានតាមអនឡាញ
តាមវេបសាយ www.RegisterToVoteMA.com ។ ច្បាប់រដ្ឋកំណត់ថាលោកអ្នកត្រូវតែចុះឈ្មោះនៅត្រឹមថ្ងៃទី 17 ខែតុលា ឆ្នាំ
2018 ដើម្បីឱ្យឈ្មោះរបស់អ្នកបង្ហាញក្នុងបញ្ជីឈ្មោះបោះឆ្នោត ។ លោកអ្នកក៏អាចពិនិត្យមើលស្ថានភាពចុះឈ្មោះអ្នកបោះឆ្នោតតាម
វេបសាយផងដែរ ។

មានសំណួរអំពីសន្លឹកឆ្នោតទូទាំងរដ្ឋដែលចាំបាច់ចំនួនបី ដែលបង្ហាញនៅលើសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតរដ្ឋ ។ ព័ត៌មានផ្លូវការ
ឆ្នាំ 2018 សម្រាប់កូនសៀវភៅអ្នកបោះឆ្នោត មានបញ្ជីសំណួរនីមួយៗដែលមានអត្ថបទច្បាប់ដែលបានស្នើឡើង របាយការណ៍ដែល
រៀបរាប់អំពីផលប៉ះពាល់ពីសម្លេងឆ្នោតគាំទ្រ បាទ/ចាស៎ ឬ ទេ សេចក្តីសង្ខេប និងការពិភាក្សារកហេតុផលគាំទ្រ និងជំទាស់នឹង
សំណួរនីមួយៗ ។ ព័ត៌មាននេះនឹងជួយលោកអ្នកក្នុងការសម្រេចចិត្តដែលគិតពិចារណា មុនពេលលោកអ្នកចូលទៅកន្លែងបោះឆ្នោត
របស់អ្នក ហើយលោកអ្នកថែមទាំងអាចយកកូនសៀវភៅជាមួយលោកអ្នកទៅក្នុងបន្ទប់បោះឆ្នោត ប្រសិនបើលោកអ្នកត្រូវការ ។

កូនសៀវភៅនេះមានព័ត៌មានសំខាន់ៗអំពីការបោះឆ្នោតនាពេលខាងមុខនេះ ។ ជម្រើសដែលលោកអ្នកអនុវត្តនៅក្នុងការបោះឆ្នោតនេះ
នឹងកំណត់គោលដៅរដ្ឋាភិបាលសម្រាប់សហគមន៍ជាតិ រដ្ឋ និងមូលដ្ឋានរបស់យើង ។ អ្នកដឹកនាំដែលលោកអ្នកជ្រើសរើស នឹងធ្វើ
ការសម្រេចចិត្តសំខាន់ៗដែលមានផលប៉ះពាល់ដល់លោកអ្នក និងគ្រួសាររបស់អ្នក ។ ខ្ញុំជម្រុញលើកទឹកចិត្តលោកអ្នកឱ្យចូលរួមក្នុង
ដំណើរការនេះ ពីព្រោះមានបញ្ហាសម្លេងឆ្នោតរបស់អ្នក ។

សូមបោះឆ្នោត និងអនុវត្តសិទ្ធិចាំបាច់បំផុតនៃប្រព័ន្ធប្រជាធិបតេយ្យរបស់យើង ។

ដោយក្តីគោរពខ្ពង់ខ្ពស់

*William Francis Galvin*

William Francis Galvin
លេខាធិការសហគមន៍ឯករាជ្យ

## ការិយាល័យនានានៅលើសន្លឹកឆ្នោតឆ្នាំ 2018

សមាជិកព្រឹទ្ធសភានៅក្នុងអង្គការនីតិបញ្ញត្តិ
អភិបាល និងភូឈ្មួយ
អគ្គព្រះរាជអាជ្ញា
រដ្ឋមន្ត្រីក្រសួងការបរទេស
អគ្គហិរញ្ញិក
សាវនករ
អ្នកតំណាងនៅក្នុងសភា
សមាជិកក្រុមប្រឹក្សា
សមាជិកព្រឹទ្ធសភានៅតុលាការធម្មតា
អ្នកតំណាងនៅតុលាការធម្មតា
មេធាវីមណ្ឌល
ក្រឡាបញ្ជីតុលាការ
ការចុះបញ្ជីលិខិតប្រគល់កម្មសិទ្ធិ
ស្នងការខោនធី
(ក្រុមប្រឹក្សារដ្ឋាភិបាល Barnstable, Bristol, Dukes, Norfolk, Plymouth, ឬ Franklin)
អគ្គហិរញ្ញិកខោនធី
(ខោនធី Norfolk តែប៉ុណ្ណោះ)
ការចុះបញ្ជីលិខិតមរតក
(ខោនធី Dukes តែប៉ុណ្ណោះ)

## ថ្ងៃផុតកំណត់ចុះឈ្មោះបោះឆ្នោត!

**ដើម្បីបោះឆ្នោតនៅក្នុងការបោះឆ្នោតរដ្ឋនោះ សំណុំបែបបទចុះឈ្មោះអ្នកបោះឆ្នោតតាមប៉ុស្តិ៍ប្រៃសណីយ៍របស់អ្នក ត្រូវមានវាយត្រាលើសំបុត្រដោយមានកាលបរិច្ឆេទ និងម៉ោងនៅត្រឹមថ្ងៃពុធទី 17 ខែតុលា ឆ្នាំ 2018!**

**តុលា**

| អ | ច | អ | ពុ | ព្រ | សុ | ស |
|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 |
| 7 | 8 | 9 | 10 | 11 | 12 | 13 |
| 14 | 15 | 16 | **17** | 18 | 19 | 20 |
| 21 | 22 | 23 | 24 | 25 | 26 | 27 |
| 28 | 29 | 30 | 31 | | | |

### សំណុំបែបបទផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍សម្រាប់ការចុះឈ្មោះអ្នកបោះឆ្នោតបានភ្ជាប់ជូន!

ដើម្បីទទួលបានសំណុំបែបបទចុះឈ្មោះអ្នកបោះឆ្នោតផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍បន្ថែមទៀត សូមចូលមើលគេហទំព័ររបស់យើង **www.sec.state.ma.us/ele** ឬហៅទូរស័ព្ទទៅផ្នែករៀបចំការបោះឆ្នោតតាមលេខ 617-727-2828 ឬ 1-800-462-VOTE។

## មាតិកា


សំណួរទី 1 ការកំណត់អ្នកជំងឺ និងគិលានុបដ្ឋាយិកា....4
សំណួរ 2 កម្រៃជើងសារលើការកំណត់ចំណាយបោះឆ្នោត និងសិទ្ធិសាជីវកម្ម....9
សំណួរទី 3 ការរើសអើងប្រឆាំងនឹងការប្តូរភេទ....13
របៀបចុះឈ្មោះបោះឆ្នោត....16
មធ្យោបាយតាមអនឡាញ....17
ការបោះឆ្នោតមុន និងការបោះឆ្នោតមុនដែលមិនអាចទៅស្ថានីយបោះឆ្នោត....18
អ្នកបោះឆ្នោតជាយោធា និងនៅបរទេស....18
ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត....19
សេវាកម្មនៃលេខាធិការសហគមន៍ឯករាជ្យនៃរដ្ឋម៉ាសាឈូសេត Massachusetts....20
ប្រសិនបើលោកអ្នកជាជនរងគ្រោះពីការក្លែងបន្លំការវិនិយោគ....21
ជំនួយសម្រាប់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ....21
ច្បាប់ស្តីពីសិទ្ធិអ្នកបោះឆ្នោតនៅរដ្ឋម៉ាសាឈូសេត Massachusetts....22
បញ្ជីឈ្មោះផ្ទៀងផ្ទាត់អ្នកបោះឆ្នោត....23


សូមយកចិត្តទុកដាក់! ប្រសិនបើអ្នកចង់បានឯកសារនេះជាភាសាខ្មែរ សូមអ្នកទូរស័ព្ទទៅលេខ 617-727-2828 ឬ 1-800-462-VOTE (8683) ។

¡Atención! Si desea recibir este folleto en Español, llame al 617-727-2828 o al 1-800-462-VOTE (8683).

請注意！如果您希望索取本手冊的中文譯本，請致電 617-727-2828 或 1-800-462-8683 。

## សំណួរ 1 ៖ ច្បាប់ដែលស្នើឡើងតាមបណ្តឹងទាមទារដែលមានគំនិតផ្តួចផ្តើម

# 1

# *ការកំណត់អ្នកជំងឺ និងគិលានុបដ្ឋាយិកា*

*តើលោកអ្នកយល់ព្រមចំពោះច្បាប់ដែលបានសង្ខេបខាងក្រោមដែលក្នុងនោះគ្មានសម្លេងឆ្នោតគាំទ្រត្រូវបានទទួលយកដោយព្រឹទ្ធសភា ឬអ្នកតំណាងមន្ទីរដ្ឋសភានៅថ្ងៃ ឬមុនថ្ងៃទី 2 ខែឧសភា ឆ្នាំ 2018 ឬទេ?*

**សេចក្តីសង្ខេប** ▶
តាមការកំណត់ដោយច្បាប់ សេចក្តីសង្ខេបត្រូវបានសរសេរដោយអគ្គព្រះរាជអាជ្ញារដ្ឋ ។

ច្បាប់ដែលបានស្នើឡើងនេះ នឹងកំណត់ចំនួនអ្នកជំងឺប៉ុន្មាននាក់ ដែលអាចបែងចែកទៅគិលានុបដ្ឋាយិកាដែលបានចុះបញ្ជីម្នាក់ៗនៅមន្ទីរពេទ្យរដ្ឋម៉ាសាឈូសេត Massachusetts និងមណ្ឌលថែទាំសុខភាពជាក់លាក់ផ្សេងៗទៀត ។ ចំនួនអតិបរមានៃអ្នកជំងឺក្នុងគិលានុបដ្ឋាយិកាដែលបានចុះបញ្ជីមួយនាក់ អាចមានខុសៗគ្នាតាមប្រភេទក្រុម និងកម្រិតនៃការថែទាំសុខភាពដូចខាងក្រោម ៖

- ក្នុងក្រុមដែលមានអ្នកជំងឺថែទាំសុខភាពមួយចំនួន/ចំនួនមធ្យម ៖ អ្នកជំងឺ 3 នាក់ក្នុងគិលានុបដ្ឋាយិកាមួយនាក់;
- ក្នុងក្រុមដែលមានអ្នកជំងឺនៅបន្ទប់វះកាត់ ឬការថែទាំក្រោយពេលប្រើថ្នាំសន្លប់ ៖ អ្នកជំងឺ 1 នាក់ដែលស្ថិតក្រោមការប្រើថ្នាំសន្លប់ក្នុងគិលានុបដ្ឋាយិកាមួយនាក់; អ្នកជំងឺ 2 នាក់ ក្នុងគិលានុបដ្ឋាយិកាមួយនាក់ក្រោយប្រើថ្នាំសន្លប់;
- នៅផ្នែកសេវាសង្គ្រោះបន្ទាន់ ៖ អ្នកជំងឺថែទាំសុខភាពយ៉ាងខ្លាំង ឬដែលមានគ្រោះថ្នាក់ចំនួន 1 នាក់ក្នុងគិលានុបដ្ឋាយិកាមួយនាក់ (ឬ 2 នាក់ ប្រសិនបើគិលានុបដ្ឋាយិកាបានវាយតម្លៃស្ថានភាពអ្នកជំងឺម្នាក់ៗថាមានស្ថេរភាព); អ្នកជំងឺដែលមិនមានស្ថេរភាពបន្ទាន់ 2 នាក់ក្នុងគិលានុបដ្ឋាយិកាមួយនាក់; អ្នកជំងឺមានស្ថេរភាពបន្ទាន់ 3 នាក់ ក្នុងគិលានុបដ្ឋាយិកាមួយនាក់ ឬអ្នកជំងឺមានស្ថេរភាពមិនបន្ទាន់ 5 នាក់ ក្នុងគិលានុបដ្ឋាយិកាមួយនាក់;
- ក្នុងក្រុមដែលមានអ្នកជំងឺមាតុភាព ៖ (a) អ្នកជំងឺពលកម្មសកម្ម ៖ អ្នកជំងឺ 1 នាក់ក្នុងគិលានុបដ្ឋាយិកាមួយនាក់; (b) នៅអំឡុងពេលសម្រាលកូន និងរហូតដល់ពីរម៉ោង ក្រោយពេលសម្រាលកូនភ្លាមៗ ៖ ម្តាយ 1 នាក់ក្នុងគិលានុបដ្ឋាយិកាមួយនាក់ និងទារក 1 នាក់ក្នុងគិលានុបដ្ឋាយិកាមួយនាក់; (c) នៅពេលស្ថានភាពម្តាយ និងកូនត្រូវបានកំណត់ថាមានស្ថេរភាព ៖ ម្តាយ 1 នាក់ និងទារករបស់នាង ឬទារកជាច្រើននាក់ ក្នុងគិលានុបដ្ឋាយិកាមួយនាក់; (d) ក្រោយពេលសម្រាលកូន ៖ អ្នកជំងឺ 6 នាក់ក្នុងគិលានុបដ្ឋាយិកាមួយនាក់; (e) ការថែទាំកម្រិតមធ្យម ឬការថែទាំទារកបន្ត ៖ ទារក 2 នាក់ក្នុងគិលានុបដ្ឋាយិកាមួយនាក់; (f) ការត្រួតពិនិត្យសុខភាពទារកជាទៀងទាត់ ៖ ទារក 6 នាក់ក្នុងគិលានុបដ្ឋាយិកាមួយនាក់;
- ក្នុងក្រុមដែលមានអ្នកជំងឺព្យាបាលអ្នកជំងឺក្រៅមន្ទីរពេទ្យ/អង្កេតជំងឺ កុមារ វេជ្ជសាស្ត្រ វះកាត់ តេឡេមេទ្រី ឬអង្គភាពណាមួយផ្សេងទៀត ៖ អ្នកជំងឺ 4 នាក់ក្នុងគិលានុបដ្ឋាយិកាមួយនាក់; និង
- ក្នុងក្រុមដែលមានអ្នកជំងឺវិកលចរិក ឬការស្តារនីតិសម្បទាឡើងវិញ ៖ អ្នកជំងឺ 5 នាក់ក្នុងគិលានុបដ្ឋាយិកាមួយនាក់ ។

ច្បាប់ដែលស្នើឡើងនេះ នឹងតម្រូវឱ្យមណ្ឌលថែទាំសុខភាពដែលចេញថ្លៃធានារ៉ាប់រង ដើម្បីគោរពតាមការបែងចែកអ្នកជំងឺដោយគ្មានការកាត់បន្ថយកម្រិតថែទាំដោយគិលានុបដ្ឋាយិកា សេវាកម្ម បុគ្គលិកស្មៀន អ្នកជំនាញ និងបុគ្គលិកផ្សេងទៀត ។

ច្បាប់ដែលស្នើឡើងនេះក៏តម្រូវឱ្យមណ្ឌលថែទាំសុខភាពដែលចេញថ្លៃធានារ៉ាប់រងនីមួយៗដើម្បីអភិវឌ្ឍវិធីសាស្ត្រការយល់ឃើញរបស់អ្នកជំងឺដោយសរសេរជាលាយលក្ខណ៍អក្សរសម្រាប់ក្រុមនីមួយៗ ដើម្បីវាយតម្លៃស្ថានភាពអ្នកជំងឺម្នាក់ៗ ។ វិធីសាស្ត្រនេះនឹងត្រូវប្រើដោយគិលានុបដ្ឋាយិកាក្នុងការសម្រេចថាតើការកំណត់អ្នកជំងឺគួរមានកម្រិតទាបជាងការកំណត់តាមច្បាប់ដែលបានស្នើឡើងនៅពេលណាមួយឬទេ ។

ច្បាប់ដែលបានស្នើឡើងនឹងមិនបដិសេធកិច្ចសន្យាណាមួយដែលមានសុពលភាពនៅថ្ងៃទី 1 ខែមករាឆ្នាំ 2019 ដែលកំណត់ចំនួនអ្នកជំងឺខ្ពស់ជាង ។ ការកំណត់ច្បាប់ដែលបានស្នើឡើងនេះ នឹងមានប្រសិទ្ធភាពបន្ទាប់ពីកិច្ចសន្យាណាមួយបែបនេះផុតកំណត់ ។

គណៈកម្មការគោលនយោបាយសុខាភិបាលរបស់រដ្ឋ នឹងតម្រូវឱ្យប្រកាសពីបទបញ្ជានានា ដើម្បីអនុវត្តច្បាប់ដែលបានស្នើឡើង ។ គណៈកម្មការអាចអនុវត្តការត្រួតពិនិត្យដើម្បីធានាដល់ការគោរពច្បាប់ ។ មណ្ឌលថែទាំសុខភាពណាមួយដែលទទួលបានសំណុំបែបបទលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរពីគណៈកម្មការបណ្តឹង ឬការរំលោភបំពាន នឹងតម្រូវឱ្យដាក់ផែនការប្រតិបត្តិស្របច្បាប់ជាលាយលក្ខណ៍អក្សរជូនទៅគណៈកម្មការ ។ គណៈកម្មការអាចរាយការណ៍អំពីការរំលោភបំពានជូនទៅអគ្គព្រះរាជអាជ្ញារដ្ឋ ដែលអាចដាក់ពាក្យបណ្តឹងដើម្បីទទួលបានការពិន័យរដ្ឋប្បវេណីដែលមានចំនួនទឹកប្រាក់រហូតដល់ $25,000 ដុល្លារក្នុងមួយករណីនៃការរំលោភបំពាន ក៏ដូចជាចំនួនទឹកប្រាក់រហូតដល់ $25,000 ដុល្លារ សម្រាប់ថ្ងៃនីមួយៗដែលមានការរំលោភបំពានបានបន្ត បន្ទាប់ពីគណៈកម្មការបានជូនដំណឹងអំពីមណ្ឌលថែទាំសុខភាពពីការរំលោភបំពាន ដែលបានចេញថ្លៃធានារ៉ាប់រង ។ គណៈកម្មការគោលនយោបាយសុខាភិបាលនឹងតម្រូវឱ្យបង្កើតលេខទូរស័ព្ទឥតគិតថ្លៃសម្រាប់ពាក្យបណ្តឹង និងគេហទំព័រមួយដែលពាក្យបណ្តឹង ផែនការប្រព្រឹត្តិស្របច្បាប់ និងការរំលោភបំពាននានានឹងត្រូវបង្ហាញ ។

ច្បាប់ដែលបានស្នើឡើងនេះនឹងហាមឃាត់ពីការដាក់វិន័យ ឬការសងសឹកប្រឆាំងនឹងនិយោជិតណាម្នាក់ចំពោះការគោរពតាមការកំណត់ច្បាប់ស្តីពីការបែងចែកអ្នកជំងឺ ។ ច្បាប់ដែលស្នើឡើងនេះនឹងតម្រូវឱ្យមណ្ឌលថែទាំសុខភាពដែលបានចេញថ្លៃធានារ៉ាប់រងនីមួយៗដើម្បីបិទប្រកាសលិខិតជូនដំណឹងនៅក្នុងអង្គភាពនីមួយៗ បន្ទប់អ្នកជំងឺ និងកន្លែងរង់ចាំដែលពន្យល់អំពីការកំណត់អ្នកជំងឺ និងរបៀបរាយការណ៍អំពីការរំលោភបំពាន ។ ការមិនប្រព្រឹត្តិស្របច្បាប់របស់មណ្ឌលថែទាំសុខភាពជារៀងរាល់ថ្ងៃចំពោះតម្រូវការទាមទារបិទប្រកាសលិខិតជូនដំណឹង នឹងអាចមានទណ្ឌកម្មដោយការពិន័យរដ្ឋប្បវេណីដែលមានចំនួនទឹកប្រាក់ចន្លោះពី $250 និង $2,500 ដុល្លារ ។

តម្រូវការទាមទារច្បាប់ដែលបានស្នើឡើងនេះ នឹងត្រូវផ្អាកនៅអំឡុងពេលមានភាពអាសន្នផ្នែកសុខភាពសាធារណៈដែលប្រកាសនៅថ្នាក់រដ្ឋ ឬថ្នាក់ជាតិ ។

ច្បាប់ដែលបានស្នើឡើងកំណត់ថា ប្រសិនបើផ្នែកណាមួយរបស់វាត្រូវបានប្រកាសថាមិនត្រឹមត្រូវនោះ ផ្នែកផ្សេងទៀតនឹងនៅជាធរមាន ។ ច្បាប់ដែលបានស្នើឡើងនេះ នឹងចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2019។

# សំណួរ 1 ៖ ច្បាប់ដែលស្នើឡើងតាមបណ្តឹងទាមទារដែលមានគំនិតផ្តួចផ្តើម

**សម្លេងឆ្នោតគាំទ្ររបស់អ្នកនឹងមានន័យអ្វីខ្លះ**
តាមការកំណត់ដោយច្បាប់ របាយការណ៍នានាដែលរៀបរាប់អំពីផលប៉ះពាល់ដល់សម្លេងឆ្នោត “បាទ/ចាស៎” ឬ “ទេ” ត្រូវបានសរសេររួមគ្នាដោយអគ្គព្រះរាជអាជ្ញារដ្ឋ និងលេខាធិការសហគមន៍ឯករាជ្យ ។

▶ ***ការបោះឆ្នោត បាទ/ចាស៎*** នឹងកំណត់ចំនួនអ្នកជំងឺប៉ុន្មាននាក់ ដែលអាចបែងចែកទៅគិលានុបដ្ឋាយិកាដែលបានចុះបញ្ជីម្នាក់ៗនៅមន្ទីរពេទ្យនានា និងមណ្ឌលថែទាំសុខភាពជាក់លាក់ផ្សេងៗទៀត ។

***ការបោះឆ្នោត ទេ*** មិនមានការផ្លាស់ប្តូរនៅក្នុងច្បាប់បច្ចុប្បន្នដែលទាក់ទងនឹងការកំណត់អ្នកជំងឺ និងគិលានុបដ្ឋាយិកា ។

---

**របាយការណ៍អំពីផលវិបាកនៃសារពើពន្ធ**
តាមការកំណត់ដោយច្បាប់នោះ របាយការណ៍អំពីផលវិបាកនៃសារពើពន្ធ ត្រូវបានសរសេរដោយការិយាល័យប្រតិបត្តិផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ។

▶ ច្បាប់ដែលស្នើឡើងនេះអាចមានផលប៉ះពាល់ដល់ប្រាក់ចំណូល និងការចំណាយរបស់រដ្ឋ និងក្រុង ដែលមានមន្ទីរពេទ្យគ្រប់គ្រងដោយរដ្ឋ តម្រូវឱ្យចំណាយប្រាក់ប្រចាំឆ្នាំនៅចន្លោះពី $67,800,000 និង $74,800,000 ដុល្លារ ដើម្បីអនុលោមតាមច្បាប់ដែលបានស្នើឡើង ហើយគណៈកម្មការគោលនយោបាយសុខាភិបាលរបស់រដ្ឋ តម្រូវឱ្យចំណាយប្រាក់ប្រចាំឆ្នាំប្រមាណ $1,281,200 ដុល្លារ ដើម្បីត្រួតពិនិត្យការប្រព្រឹត្តិស្របច្បាប់ ។

មានផលប៉ះពាល់ដល់កម្មវិធី MassHealth, កម្មវិធី Medicaid របស់រដ្ឋ និងកាតព្វកិច្ចថែទាំសុខភាពនិយោជិត និងនិវត្តជនដែលបានទទួលថវិកាពីរដ្ឋតាមគំនិតផ្តួចផ្តើមឡើងថ្លៃសេវាមន្ទីរពេទ្យ ឬបង្កឱ្យមានការបិទមន្ទីរពេទ្យ ។ ទោះយ៉ាងណាក៏ដោយ ក៏ផលវិបាកនៃសារពើពន្ធទូទៅចំពោះហិរញ្ញវត្ថុរដ្ឋ និងក្រុង មានការលំបាកក្នុងការរៀបចំគម្រោងដោយសារតែខ្វះទិន្នន័យដែលអាចទុកចិត្តបានផងដែរ ។

---

**ការពិភាក្សារកហេតុផល**
តាមការកំណត់ដោយច្បាប់ ការពិភាក្សារកហេតុផលដែលមាន 150 ពាក្យ ត្រូវបានសរសេរដោយអ្នកគាំទ្រ និងអ្នកប្រឆាំងចំពោះសំណួរនីមួយៗ និងបង្ហាញអំពីមតិយោបល់របស់ពួកគេ ។ សហគមន៍ឯករាជ្យនៃរដ្ឋម៉ាសាឈូសេត Massachusetts មិនយល់ព្រមចំពោះការពិភាក្សារកហេតុផលទាំងនេះទេ ហើយមិនបញ្ជាក់ភាពត្រឹមត្រូវនៃរបាយការណ៍ណាមួយដែលបានធ្វើឡើងនៅក្នុងការពិភាក្សារកហេតុផលទាំងនេះឡើយ ។ ឈ្មោះរបស់បុគ្គល និងអង្គភាពនានាដែលបានសរសេរការពិភាក្សារកហេតុផលនីមួយៗ និងមតិយោបល់ណាមួយដែលសរសេរជាលាយលក្ខណ៍អក្សរដោយអ្នកដទៃទៀតអំពីការពិភាក្សារកហេតុផលនីមួយៗនោះ មាននៅក្នុងឯកសារនៅការិយាល័យលេខាធិការសហគមន៍ឯករាជ្យ ។

▶ ***តាមចំណូលចិត្ត ៖*** ខ្ញុំបានធ្វើការងារជាគិលានុបដ្ឋាយិកាមើលអ្នកជំងឺដែលដេកគ្រែពេទ្យរយៈពេល 40 ឆ្នាំ ។ ខ្ញុំបានចូលរួមជាមួយគិលានុបដ្ឋាយិកានានាមកពីទូទាំងរដ្ឋម៉ាសាឈូសេត Massachusetts ដើម្បីសរសេរច្បាប់នេះ និងកំណត់អ្នកជំងឺប្រកបដោយសុវត្ថិភាពតាមសន្លឹកឆ្នោត ដើម្បីធ្វើឱ្យប្រសើរឡើងគុណភាពនៃការថែទាំអ្នកជំងឺនៅក្នុងមន្ទីរពេទ្យរដ្ឋម៉ាសាឈូសេត Massachusetts។ ការសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រឯករាជ្យ បានរកឃើញដោយមិនផ្លាស់ប្តូរថាគុណភាពនៃការថែទាំ ថយចុះយ៉ាងខ្លាំងនៅពេលគិលានុបដ្ឋាយិកាត្រូវបានគេបង្ខំឱ្យថែទាំអ្នកជំងឺច្រើននាក់ពេកក្នុងពេលតែមួយ ដែលធ្វើឱ្យអ្នកជំងឺមានហានិភ័យខ្ពស់ចំពោះផលវិបាកនានា ដូចជាជំងឺរលាកសួត កំហុសប្រើថ្នាំ និងមានអ្វីជាច្រើនទៀត ។ គំនិតផ្តួចផ្តើមនេះ បង្កើតឡើងនូវការកំណត់កម្រិតអតិបរមាដែលមានសុវត្ថិភាពសម្រាប់ចំនួនអ្នកជំងឺដែលបានបែងចែកទៅគិលានុបដ្ឋាយិកានៅតាមមន្ទីរពេទ្យទាំងអស់ ដើម្បីធានាថាអ្នកជំងឺរបស់យើងទទួលបានការថែទាំ និងការយកចិត្តទុកដាក់តាមតម្រូវការពួកគេ ។ ការណ៍នេះផ្តល់ជូនភាពបត់បែនអតិបរមាដែលតម្រូវឱ្យមន្ទីរពេទ្យនានាកែសម្រួលតាមកម្រិតបុគ្គលិកគិលានុបដ្ឋាយិកាដែលបានចុះបញ្ជីដោយផ្អែកលើតម្រូវការរបស់អ្នកជំងឺ និងធ្វើដូច្នេះដោយមិនកាត់បន្ថយសមាជិកដទៃទៀតពីកម្លាំងពលកម្មថែទាំសុខភាពឡើយ ។ ការស្ទង់មតិនាពេលថ្មីៗនេះ បានរកឃើញថាគិលានុបដ្ឋាយិកាដែលបានចុះបញ្ជី 86% នៅរដ្ឋម៉ាសាឈូសេត Massachusetts យល់ស្របនឹងសំណួរនេះ ។

**Donna Kelly-Williams, RN**
**Massachusetts Nurses Association**
**340 Turnpike Street**
**Canton, MA 02021**
**(781) 821-4625 x 777**
**www.safepatientlimits.org**

***ការជំទាស់ ៖*** គិលានុបដ្ឋាយិកានឹងស្នើសុំលោកអ្នកឱ្យបោះឆ្នោត ទេ នៅសំណួរ 1 ។

មន្ទីរពេទ្យរដ្ឋម៉ាស្សាឈូសេត Massachusetts ស្ថិតក្នុងចំណោមដែលល្អបំផុតនៅក្នុងប្រទេស ប៉ុន្តែសំណួរ 1 នឹងកំណត់ថាគុណភាពនៃការថែទាំអ្នកជំងឺ និងសុវត្ថិភាព ស្ថិតក្នុងហានិភ័យ ។ វាកំណត់អត្រាបុគ្គលិកគិលានុបដ្ឋាយិកាដែលកំណត់ដោយរដ្ឋាភិបាលដែលតឹងរឹងនៅតាមមន្ទីរពេទ្យនីមួយៗ ការមិនយកចិត្តទុកដាក់ចំពោះការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់គិលានុបដ្ឋាយិកា និងគ្រូពេទ្យ ។

**សំណួរ 1 នឹងបង្កើតអាណត្តិរដ្ឋាភិបាលដែលមិនផ្តល់មូលនិធិដ៏ធំមួយដែលចំណាយថវិកាជាងមួយពាន់លានដុល្លារក្នុងការចំណាយថែទាំសុខភាពខ្ពស់ជាងគេប្រចាំឆ្នាំ**ដែលធ្វើឱ្យមន្ទីរពេទ្យសហគមន៍បិទទ្វារ និងបង្ខំឱ្យមន្ទីរពេទ្យផ្សេងទៀតកាត់បន្ថយសេវាសង្គ្រោះបន្ទាន់ សេវាញៀនថ្នាំ និងសេវាសុខភាពផ្លូវចិត្ត ។ សំណួរ 1 ត្រូវបានគេហៅថាជា “ដំណោះស្រាយដែលមិនទទួលខុសត្រូវច្រើនបំផុតចំពោះការថែទាំសុខភាព” ។

មិនមានភស្តុតាងខាងវិទ្យាសាស្ត្រដែលថាមានអត្រាមិនប្រែប្រួលទាំងនេះធ្វើឱ្យប្រសើរឡើងចំពោះការថែទាំសុខភាពអ្នកជំងឺឡើយ ។

សំណួរទី 1 ៖ ការចំណាយខ្ពស់ជាង អាណត្តិមិនប្រែប្រួល និងការថែទាំសុខភាពសមរម្យសម្រាប់អ្នកទាំងអស់គ្នា ។

គិលានុបដ្ឋាយិកា និងអង្គភាពថែរក្សាសុខភាពជាងមួយរយ ដែលរួមមានសមាគមគិលានុបដ្ឋាយិកាអាមេរិកនៅរដ្ឋម៉ាសាឈូសេត Massachusetts, សមាគមសង្គមវេជ្ជសាស្ត្ររដ្ឋម៉ាសាឈូសេត Massachusetts, សមាគមមហាវិទ្យាល័យគ្រូពេទ្យសង្គ្រោះបន្ទាន់នៅរដ្ឋម៉ាសាឈូសេត Massachusetts College of Emergency Physicians និងមន្ទីរពេទ្យនៅរដ្ឋម៉ាសាឈូសេត Massachusetts នីមួយៗជម្រុញលើកទឹកចិត្ត ៖ **បោះឆ្នោត ទេ នៅក្នុងសំណួរ 1** ។

**Amanda S. Oberlies, RN**
**Coalition to Protect Patient Safety**
**P.O. Box 15**
**Boston, MA 02137**
**617-840-3465**
**www.protectpatientsafety.com**

## អត្ថបទសំណួរពេញលេញ

វាត្រូវអនុម័តដោយប្រជាពលរដ្ឋ និងដោយអាជ្ញាធររបស់ពួកគេ ៖

ផ្នែក 1 ៖ ផ្នែក 2 ដល់ 4 រួមជាមួយផ្នែក 231 នៃជំពូក 111 នៃច្បាប់ទូទៅ តាមន័យនេះ ត្រូវបានគេស្គាល់ថាជា "ច្បាប់ស្តីពីសុវត្ថិភាពអ្នកជំងឺ" ។

ផ្នែក 2 ៖ ជំពូក 111 នៃច្បាប់ទូទៅ តាមន័យនេះត្រូវបានធ្វើវិសោធនកម្មដោយបន្ថែមផ្នែកនានាដូចខាងក្រោម បន្ទាប់ពីផ្នែក 231 ៖

ផ្នែក 231 A. និយមន័យ ។

ដូចដែលបានប្រើក្នុងផ្នែក 231 ដល់ 231J ពាក្យដូចខាងក្រោមនេះ ត្រូវមានអត្ថន័យដូចតទៅនេះ ៖

“ការបែងចែកអ្នកជំងឺ" ជាបុគ្គលម្នាក់ដែលបានអនុញ្ញាតឱ្យចូលមណ្ឌលថែទាំសុខភាពជាទីកន្លែងគិលានុបដ្ឋាយិកាដែលបានចុះបញ្ជី ព្រមទទួលយកការទទួលខុសត្រូវចំពោះការថែទាំព្យាបាលអ្នកជំងឺដោយផ្ទាល់ ។ អ្នកជំងឺម្នាក់ត្រូវបានគេបែងចែកទៅគិលានុបដ្ឋាយិកាដែលបានចុះបញ្ជីគ្រប់ពេលវេលា ។

“បណ្តឹងតវ៉ា” ជាការប្រាស្រ័យទាក់ទងដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរណាមួយដោយអ្នកជំងឺ អ្នកជំនាញវេជ្ជសាស្ត្រ មណ្ឌលថែទាំសុខភាព ឬនិយោជិតរបស់ខ្លួនណាម្នាក់ ដែលមន្ទីរពេទ្យមួយបានរំលោភបំពានលើការកំណត់ពេលវេលា ឬលក្ខខណ្ឌណាមួយនៃច្បាប់នេះ ។

“មណ្ឌលថែទាំសុខភាព” ជាមន្ទីរពេទ្យដែលមានអាជ្ញាប័ណ្ណនៅក្រោមផ្នែក 51 នៃជំពូកនេះ មន្ទីរពេទ្យបង្រៀននៃមហាវិទ្យាល័យនៃផ្នែកសាលាពេទ្យរដ្ឋម៉ាសាឈូសេត Massachusetts, មន្ទីរពេទ្យថែទាំសុខភាពធ្ងន់ធ្ងរទូទៅដែលប្រតិបត្តិការដោយរដ្ឋ និងគ្រប់គ្រងកម្មសិទ្ធិដោយរដ្ឋ ឬឯកជនដែលមានអាជ្ញាប័ណ្ណ មន្ទីរពេទ្យវិកលចរិកធ្ងន់ធ្ងរ មន្ទីរពេទ្យពិសេសថែទាំសុខភាពធ្ងន់ធ្ងរ ឬអង្គភាពថែទាំសុខភាពធ្ងន់ធ្ងរណាមួយនៅក្នុងមណ្ឌលថែទាំសុខភាពដែលប្រតិបត្តិការដោយរដ្ឋ ។ និយមន័យនេះមិនត្រូវរាប់បញ្ចូលមណ្ឌលស្តារនីតិសម្បទា ឬមណ្ឌលថែទាំសុខភាពរយៈពេលវែងឡើយ ។

“កម្លាំងពលកម្មថែទាំសុខភាព” ជាបុគ្គលិកដែលជួលឱ្យបម្រើការងារ ឬចុះកិច្ចសន្យាធ្វើការនៅមណ្ឌលថែទាំសុខភាពដែលមានលទ្ធផលនៅពេលមានការផ្តល់ជូនសេវាថែទាំដែលមានគុណភាពដល់អ្នកជំងឺ ដែលត្រូវរាប់បញ្ចូល ប៉ុន្តែមិនកំណត់ចំពោះគិលានុបដ្ឋាយិកាដែលបានចុះបញ្ជី គិលានុបដ្ឋាយិកាជំនួសដែលមានអាជ្ញាប័ណ្ណ បុគ្គលិកជំនួយដែលគ្មានអាជ្ញាប័ណ្ណ បុគ្គលិកសេវាកម្មបច្ចេកទេស ការថែទាំ ស្មៀន បុគ្គលិកជំនាញ និងបុគ្គលិកថែទាំសុខភាពទាំងអស់ផ្សេងទៀត ។

“ការថែទាំព្យាបាល” ការថែទាំដែលស្ថិតនៅក្នុងវិសាលភាពនៃការអនុវត្តដូចមានចែងក្នុងផ្នែក 80B នៃជំពូក 112 នៃច្បាប់ទូទៅ ឬត្រូវបញ្ចូលតាមស្តង់ដារដែលទទួលស្គាល់ពីការអនុវត្តថែទាំសុខភាពតាមរបៀបផ្សេងទៀត ដែលរួមមានការវាយតម្លៃ ការធ្វើរោគវិនិច្ឆ័យលើការព្យាបាល ការរៀបចំផែនការ ការធ្វើអន្តរាគមន៍ ការវាយតម្លៃ និងការតស៊ូមតិរបស់អ្នកជំងឺ ។

“ការរំលោភបំពាន” ការខកខានណាមួយដោយមណ្ឌលថែទាំសុខភាព ដើម្បីគោរពតាមការកំណត់ពេលវេលា ឬលក្ខខណ្ឌនៃច្បាប់នេះ ។

“ផែនការអនុវត្តជាលាយលក្ខណ៍អក្សរ” ជាផែនការលាយលក្ខណ៍អក្សរដែលរៀបរាប់លម្អិតអំពីចំនួនអ្នកជំងឺអតិបរមាដែលត្រូវបែងចែកគ្រប់ពេលវេលាទាំងអស់ដល់គិលានុបដ្ឋាយិកាដែលបានចុះបញ្ជីនៅក្នុងអង្គភាពនីមួយៗ ដែលបានរៀបរាប់នៅក្នុងផ្នែក 231C ព្រមទាំងរៀបរាប់លម្អិតនៅពេលដំណាលគ្នានេះ អំពីផែនការរបស់មណ្ឌលថែទាំសុខភាពដើម្បីធានាថា មណ្ឌលថែទាំសុខភាពនឹងអនុវត្តការកំណត់បែបនេះដោយមិនកាត់បន្ថយបុគ្គលិកនៃកម្លាំងពលកម្មថែទាំសុខភាពរបស់ខ្លួន ។

ផ្នែក 23IB ៖ ទន្ទឹមនឹងនេះការបង្កើត និងការអនុវត្តកំណត់ការបែងចែកអ្នកជំងឺដែលមានចំនួនអតិបរមា ដែលបានរៀបរាប់នៅផ្នែក 231C ខាងក្រោមនេះ មណ្ឌលថែទាំសុខភាពនីមួយៗត្រូវប្រគល់ជូនផែនការអនុវត្តជាលាយលក្ខណ៍អក្សរទៅគណៈកម្មការគោលនយោបាយសុខភាពនៅរដ្ឋម៉ាសាឈូសេត Massachusetts ដែលបញ្ជាក់ថាវានឹងអនុវត្តកំណត់ការបែងចែកអ្នកជំងឺដោយមិនបន្ថយកម្រិតបុគ្គលិកនៃកម្លាំងពលកម្មថែទាំសុខភាពរបស់ខ្លួន ។

ផ្នែក 231C ៖ វាជាសិទ្ធិរបស់អ្នកជំងឺគ្រប់រូបក្នុងមណ្ឌលទាំសុខភាពចំពោះការថែទាំព្យាបាលដែលចាត់ទុកថាមានសុវត្ថិភាពដោយគិលានុបដ្ឋាយិកាដែលបានចុះបញ្ជី ដែលព្រមទទួលយកការទទួលខុសត្រូវចំពោះការថែទាំរបស់គាត់ ។ វាជាការទទួលខុសត្រូវរបស់មណ្ឌលទាំសុខភាពនីមួយៗដើម្បីផ្តល់ជូនធនធានចាំបាច់ ដើម្បីជួយគាំទ្រដល់ការកំណត់អ្នកជំងឺដែលមានសុវត្ថិភាព ដែលបានរៀបរាប់នៅក្នុងផ្នែកនេះ ។ ចំនួនអ្នកជំងឺអតិបរមា ត្រូវបែងចែកទៅគិលានុបដ្ឋាយិកាដែលបានចុះបញ្ជីនៅមណ្ឌលទាំសុខភាពគ្រប់ពេលវេលានោះ មិនត្រូវមានលើសពីការកំណត់នានាដែលបានរៀបរាប់នៅក្នុងផ្នែកនេះ ។

គ្មានអ្វីដែលត្រូវហាមឃាត់មណ្ឌលទាំសុខភាពមួយពីការបែងចែកអ្នកជំងឺពីរបីនាក់ទៅគិលានុបដ្ឋាយិកាដែលបានចុះបញ្ជីជាងការកំណត់នានាដែលបានរៀបរាប់នៅក្នុងផ្នែកនេះឡើយ; ទោះយ៉ាងណាក៏ដោយ ក៏មិនមានការបែងចែកបែបនោះនាំឱ្យមានការកាត់បន្ថយកម្រិតបុគ្គលិកនៃកម្លាំងពលកម្មថែទាំសុខភាពដែលបានបែងចែកទៅតាមអ្នកជំងឺនៃមណ្ឌលទាំសុខភាពឡើយ ។

ការកំណត់បែងចែកអ្នកជំងឺត្រូវមានដូចខាងក្រោម ៖

a. ក្នុងក្រុមទាំងអស់ដែលមានអ្នកជំងឺថែទាំសុខភាពមួយចំនួន/ចំនួនមធ្យមនោះ ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃអ្នកជំងឺថែទាំសុខភាពមួយចំនួន/ចំនួនមធ្យម មានបី (3) នាក់ ។ អ្នកជំងឺថែទាំសុខភាពមួយចំនួន/ចំនួនមធ្យម គឺអ្នកជំងឺទាំងនោះដែលមានតម្រូវការថែទាំសុខភាពកម្រិតមធ្យមរវាងក្រុមថែទាំសុខភាពយ៉ាងខ្លាំង និងក្រុមវះកាត់ផ្នែកវេជ្ជសាស្ត្រទូទៅ ។

b. ក្នុងក្រុមទាំងអស់ដែលមានអ្នកជំងឺថែទាំសុខភាពក្រោយពេលប្រើថ្នាំសន្លប់ (PACU), ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃអ្នកជំងឺ PACU ដែលស្ថិតក្រោមការប្រើថ្នាំសន្លប់មានចំនួនមួយ (1) នាក់ ។ ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃអ្នកជំងឺ PACU ក្រោយការប្រើថ្នាំសន្លប់ មានពីរ (2) នាក់ ។

c. ក្នុងក្រុមទាំងអស់ដែលមានអ្នកជំងឺនៅបន្ទប់វះកាត់ (OR) នោះ ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃអ្នកជំងឺ OR ដែលស្ថិតក្រោមការប្រើថ្នាំសន្លប់មានចំនួនមួយ (1) នាក់ ។ ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃអ្នកជំងឺ OR ក្រោយការប្រើថ្នាំសន្លប់ មានពីរ (2) នាក់ ។

d. នៅផ្នែកសេវាសង្គ្រោះបន្ទាន់ ៖

   (1) ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃអ្នកជំងឺថែទាំសុខភាពយ៉ាងខ្លាំង ឬអ្នកជំងឺថែទាំសុខភាពធ្ងន់ធ្ងរ មានមួយ (1) នាក់ ។ គិលានុបដ្ឋាយិកាដែលបានចុះបញ្ជីអាចទទួលយកអ្នកជំងឺថែទាំសុខភាពយ៉ាងខ្លាំង ឬអ្នកជំងឺថែទាំសុខភាពធ្ងន់ធ្ងរទីពីរ ប្រសិនបើគិលានុបដ្ឋាយិកានោះវាយតម្លៃថាស្ថានភាពរបស់អ្នកជំងឺមានស្ថេរភាព ។

   (2) ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃអ្នកជំងឺមិនប្រក្រតីជាបន្ទាន់ មានពីរ (2) នាក់ ។ អ្នកជំងឺស្ថិតក្នុងស្ថានភាពមិនប្រក្រតីជាបន្ទាន់ នៅពេលការថែទាំសុខភាពអ្នកជំងឺជាបន្ទាន់ ដែលចាំបាច់ក្នុងរយៈពេលពី 15 ទៅ 60 នាទី ។

   (3) ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃអ្នកជំងឺមានស្ថេរភាពជាបន្ទាន់ មានបី (3) នាក់ ។ អ្នកជំងឺស្ថិតក្នុងស្ថានភាពដែលមានស្ថេរភាពជាបន្ទាន់ នៅពេលការ

## អត្ថបទសំណួរពេញលេញ (បន្ត)

ថែទាំសុខភាពអ្នកជំងឺជាបន្ទាន់ ដែលចាំបាច់ ប៉ុន្តែអាចរងចាំរហូតដល់បីម៉ោង បើត្រូវការចាំបាច់ ។

(4) ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃអ្នកជំងឺមិនប្រក្រតីជាបន្ទាន់ មានប្រាំ (5) នាក់ ។ អ្នកជំងឺស្ថិតនៅក្នុងស្ថានភាពមិនប្រក្រតីជាបន្ទាន់ នៅពេលអ្នកជំងឺមានស្ថានភាព ឬស្ថានភាពនានាដែលត្រូវការការយកចិត្តទុកដាក់ ប៉ុន្តែពេលវេលាមិនមែនជាកត្តាសំខាន់ឡើយ ។

e. ក្នុងក្រុមទាំងអស់ ដែលមានអ្នកជំងឺថែទាំសុខភាពកូនដោយម្ដាយ ៖

(1) ការបែងចែកចំនួនអ្នកជំងឺអតិបរមាពីអ្នកជំងឺមានកម្លាំងពលកម្មសកម្ម អ្នកជំងឺដែលមានការស្ដាប់ពិនិត្យរោគដែលកើតឡើងជាចន្លោះសម្រាប់ការវាយតម្លៃទារកក្នុងផ្ទៃ និងអ្នកជំងឺដែលមានផលវិបាកផ្នែកវេជ្ជសាស្ត្រ ឬសម្រាលកូនមានអ្នកជំងឺមួយ (1) នាក់។

(2) ការបែងចែកចំនួនអ្នកជំងឺអតិបរមានៅអំឡុងពេលសម្រាលកូន និងមានរយៈពេលរហូតដល់ពីរ (2) ម៉ោងក្រោយសម្រាលកូន ហើយភ្លាមៗ មានគិលានុបដ្ឋាយិកាមួយ (1) នាក់ដែលទទួលខុសត្រូវចំពោះម្ដាយ និងចំពោះទារកម្នាក់ៗ មានគិលានុបដ្ឋាយិកាមួយ (1) នាក់ ដែលមានការទទួលខុសត្រូវតែម្នាក់ឯងចំពោះទារកនេះ ។ នៅពេលស្ថានភាពម្ដាយ និងទារក ត្រូវបានកំណត់ថាមានស្ថេរភាព ហើយបានបំពេញ ចំណុចសំខាន់ៗហើយនោះ មានគិលានុបដ្ឋាយិកាមួយ (1) នាក់ អាចមើលថែទាំទាំងម្ដាយនិងទារក ។

(3) ការបែងចែកចំនួនអ្នកជំងឺអតិបរមានៅអំឡុងពេលសម្រាលកូនសម្រាប់ម្ដាយ ឬទារកដែលមិនមានបញ្ហាស្មុគស្មាញនោះ មានប្រាំមួយ (6) នាក់ ដែលត្រូវមានម្ដាយឬទារកចំនួនប្រាំមួយ (6) នាក់ ចំនួនដូចគ្នាម្ដាយនិងទារកបី (3) នាក់ ឬនៅក្នុងករណីចំនួនទារកច្រើនពេក ដែលមិនច្រើនជាងចំនួនអ្នកជំងឺសរុបប្រាំមួយ (6) នាក់ឡើយ ។ ដូចដែលបានប្រើក្នុងផ្នែករងនេះ ចំនួនដូចគ្នា មានន័យថាម្ដាយមួយ (1) នាក់ និងទារកមួយ (1) នាក់ ។

(4) ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃទារកថែទាំសុខភាពជាបន្ត ឬទារកថែទាំសុខភាពមធ្យម មានទារកពីរ (2) នាក់ ។

(5) ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃអ្នកជំងឺដែលមានការត្រួតពិនិត្យសុខភាពទារកជាទៀងទាត់ មានចំនួនប្រាំមួយ (6) នាក់ ។

f. បើក្រុមទាំងអស់ដែលមានអ្នកជំងឺជាកុមារនោះ ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃអ្នកជំងឺកុមារ មានចំនួនបួន (4) នាក់ ។

g. ក្នុងក្រុមទាំងអស់ដែលមានអ្នកជំងឺវិកលចរិកនោះ ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃអ្នកជំងឺវិកលចរិក មានចំនួនប្រាំ (5) នាក់ ។

h. ក្នុងក្រុមទាំងអស់ដែលមានអ្នកជំងឺផ្នែកវេជ្ជសាស្ត្រ វះកាត់ និងតេឡេមេទ្រីនោះ ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃអ្នកជំងឺផ្នែកវេជ្ជសាស្ត្រ វះកាត់ និងតេឡេមេទ្រី មានចំនួនបួន (4) នាក់ ។

i. ក្នុងក្រុមទាំងអស់ដែលមានអ្នកជំងឺព្យាបាលអង្កេតមើល/អ្នកជំងឺខាងក្រៅនោះ ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃអ្នកជំងឺព្យាបាលអង្កេតមើល/អ្នកជំងឺខាងក្រៅ មានចំនួនបួន (4) នាក់ ។

j. ក្នុងក្រុមទាំងអស់ដែលមានអ្នកជំងឺស្ដារនីតិសម្បទាឡើងវិញនោះ ការបែងចែកចំនួនអ្នកជំងឺអតិបរមានៃអ្នកជំងឺស្ដារនីតិសម្បទាឡើងវិញ មានចំនួនប្រាំ (5) នាក់ ។

k. ក្នុងក្រុមណាមួយដែលមិនរៀបរាប់តាមរបៀបផ្សេងទៀតនោះ ការបែងចែកចំនួនអ្នកជំងឺអតិបរមា មានចំនួនបួន (4) នាក់ ។

ផ្នែក 231D ៖ មណ្ឌលថែទាំសុខភាពនីមួយៗ ត្រូវអនុវត្តការកំណត់បែងចែកអ្នកជំងឺដែលបានរៀបចំឡើងដោយផ្នែក 231C។ ទោះជាយ៉ាងណាក៏ដោយ ក៏ការអនុវត្តការកំណត់ទាំងនេះ មិនត្រូវមានការកាត់បន្ថយកម្រិតបុគ្គលិកនៃកម្លាំងពលកម្មថែទាំសុខភាពឡើយ ។

ផ្នែក 231E ៖ គណៈកម្មការគោលនយោបាយសុខាភិបាលរដ្ឋម៉ាសាឈូសេត Massachusetts នឹងប្រកាសអំពីបទបញ្ជាទាំងឡាយដែលគ្រប់គ្រងនិងធានាការអនុវត្តនិងប្រតិបត្តិការតាមច្បាប់នេះ ដែលរួមបញ្ចូល ប៉ុន្តែមិនមានកំណត់ចំពោះបទបញ្ជានានាដែលកំណត់ខ្លឹមសារ និងការអនុវត្ត ៖ (a) ផែនការបញ្ជាក់វិញ្ញាបនប័ត្រសម្រាប់មណ្ឌលថែទាំសុខភាពនីមួយៗ ត្រូវរៀបចំសម្រាប់ការអនុវត្តលើការកំណត់បែងចែកអ្នកជំងឺដែលបានរៀបរាប់នៅក្នុងផ្នែក 231C ដែលរួមមានកាតព្វកិច្ចមណ្ឌលថែទាំសុខភាពដែលអនុវត្តការកំណត់លក្ខខណ្ឌនានា មិនត្រូវកាត់បន្ថយកម្រិតបុគ្គលិកនៃកម្លាំងពលកម្មថែទាំសុខភាពដែលបានបែងចែកដល់អ្នកជំងឺបែបនេះឡើយ; និង (b) ផែនការប្រតិបត្តិស្របច្បាប់ជាលាយលក្ខណ៍អក្សរដែលតម្រូវឱ្យមណ្ឌលថែទាំសុខភាពនីមួយៗគោរពតាមការកំណត់បែងចែកចំនួនអ្នកជំងឺ ។ ថ្វីបើមានលក្ខខណ្ឌនៃផ្នែកនេះ ឬផ្នែកណាមួយផ្សេងទៀតនៃច្បាប់នេះក៏ដោយ ក៏គណៈកម្មការគោលនយោបាយសុខាភិបាលរដ្ឋម៉ាសាឈូសេត Massachusetts មិនត្រូវប្រកាសបទបញ្ជាណាមួយដែលអនុញ្ញាតដោយផ្ទាល់ឬដោយមិនផ្ទាល់ចំពោះការពន្យាពេល ការឈប់ទាមទារសិទ្ធិបណ្ដោះអាសន្នឬអចិន្ត្រៃយ៍ ឬការកែសម្រួលតាមតម្រូវការទាមទារណាមួយ ដែលមានចែងក្នុងផ្នែក 231C និង 231D ខាងលើឡើយ ។

ផ្នែក 231F ៖ ឧបករណ៍កំណត់ភាពធ្ងន់ធ្ងរនៃជំងឺរបស់អ្នកជំងឺ ។ ឧបករណ៍កំណត់ភាពធ្ងន់ធ្ងរនៃជំងឺរបស់អ្នកជំងឺ ត្រូវប្រើជាឧបករណ៍បន្ទាប់បន្សំមួយចំពោះការវាយតម្លៃគិលានុបដ្ឋាយិកាដែលបានចុះបញ្ជី ហើយត្រូវរៀបចំឡើងដើម្បីលើកកម្ពស់និងជួយគាំទ្រដល់ការផ្ដល់ជូនការថែទាំព្យាបាលប្រកបដោយសុវត្ថិភាពសម្រាប់អ្នកជំងឺ; ប៉ុន្តែទោះយ៉ាងណាក៏ដោយ ក៏ឧបករណ៍បែបនេះមិនត្រូវបានប្រើប្រាស់ជំនួសការវាយតម្លៃ និងការវិនិច្ឆ័យខាងវេជ្ជសាស្ត្រចំពោះគិលានុបដ្ឋាយិកាដែលបានចុះបញ្ជី ដែលបែងចែកចំនួនអ្នកជំងឺឡើយ ។ មណ្ឌលថែទាំសុខភាពនីមួយៗត្រូវអភិវឌ្ឍឧបករណ៍កំណត់ភាពធ្ងន់ធ្ងរនៃជំងឺរបស់អ្នកជំងឺសម្រាប់អ្នកជំងឺម្នាក់ៗដែលបានរៀបចំឡើងនៅក្នុងផ្នែក 231C ។ ការវាយតម្លៃអ្នកជំងឺ និងការប្រើឧបករណ៍កំណត់ភាពធ្ងន់ធ្ងរនៃជំងឺរបស់អ្នកជំងឺ ត្រូវអនុវត្តដោយគិលានុបដ្ឋាយិកាដែលបានទទួលយកការបែងចែកចំនួនសម្រាប់អ្នកជំងឺនោះ ។ ឧបករណ៍កំណត់ភាពធ្ងន់ធ្ងរនៃជំងឺរបស់អ្នកជំងឺសម្រាប់អ្នកជំងឺម្នាក់ៗនៅមណ្ឌលថែទាំសុខភាពមួយ ត្រូវបានអភិវឌ្ឍដោយគណៈកម្មាធិមួយ ដែលភាគច្រើនមានបុគ្គលិកគិលានុបដ្ឋាយិកាដែលបានបែងចែកទៅអង្គភាពពិសេស ។ ឧបករណ៍កំណត់ភាពធ្ងន់ធ្ងរនៃជំងឺរបស់អ្នកជំងឺ ត្រូវបានអភិវឌ្ឍដើម្បីកំណត់ថាតើចំនួនអ្នកជំងឺអតិបរមាដែលអាចបែងចែកទៅគិលានុបដ្ឋាយិកាដែលបានចុះបញ្ជី ត្រូវមានចំនួនទាបជាងកម្រិតកំណត់បែងចែកចំនួនអ្នកជំងឺ ដែលបានបញ្ជាក់នៅក្នុងផ្នែក 231C ដែលក្នុងនោះករណីមានចំនួនទាបជាង នឹងត្រូវគ្រប់គ្រងសម្រាប់អ្នកជំងឺទាំងនោះ ។ ឧបករណ៍កំណត់ភាពធ្ងន់ធ្ងរនៃជំងឺរបស់អ្នកជំងឺ ត្រូវសរសេរត្រៀមជាស្រេច ដើម្បីប្រើប្រាស់និងយល់ដឹងអំពីគិលានុបដ្ឋាយិកាដែលបានចុះបញ្ជីនោះ ត្រូវវាស់វែងភាពធ្ងន់ធ្ងរនៃជំងឺរបស់អ្នកជំងឺ ដែលមានចំនួនមិនតិចជាងការផ្លាស់ប្ដូរវេននីមួយៗ នៅពេលមានការអនុញ្ញាតឱ្យអ្នកជំងឺចូលមន្ទីរពេទ្យ និងនៅពេលមានការផ្លាស់ប្ដូរសំខាន់ៗនៅក្នុងស្ថានភាពរបស់អ្នកជំងឺ និងត្រូវគិតពិចារណាលើលក្ខណៈវិនិច្ឆ័យ ដែលត្រូវរាប់បញ្ចូល ប៉ុន្តែមិនមានកំណត់ចំពោះ ៖ (1) សេចក្ដីត្រូវការចំពោះតម្រូវការទាមទារ និងបច្ចេកវិទ្យាដែលមានលក្ខណៈពិសេស; (2) ភាពខ្លាំងនៃការធ្វើអន្តរាគមន៍ព្យាបាលដែលតម្រូវឱ្យមាន និងភាពស្មុគស្មាញនៃការវិនិច្ឆ័យរោគខាងគ្លីនិកដែលត្រូវការរៀបចំ អនុវត្ត និងវាយតម្លៃ ផែនការថែទាំព្យាបាលអ្នកជំងឺម្នាក់ៗស្របតាមស្តង់ដារថែទាំសុខភាពដែលមានវិជ្ជាជីវៈ; (3) ការបញ្ចូលគ្នានូវជំនាញរបស់សមាជិកនៃកម្លាំងពលកម្មថែទាំសុខភាពដែលចាំបាច់សម្រាប់ការផ្ដល់ជូនការ

## អត្ថបទសំណួរពេញលេញ (បន្ត)

ថែទាំសុខភាពដែលមានគុណភាពសម្រាប់អ្នកជំងឺម្នាក់ៗ; និង (4) ភាពជិតគ្នារបស់អ្នកជំងឺពីម្នាក់ទៅម្នាក់ទៀត ដែលត្រូវបានបែងចែកទៅគិលានុបដ្ឋាយិកាដូចគ្នា ភាពជិតគ្នា និងភាពអាចធ្វើទៅបានចំពោះធនធានថែទាំសុខភាពផ្សេងទៀត និងការរៀបចំមណ្ឌលថែទាំសុខភាព ។ មុនការអនុវត្តនោះ ឧបករណ៍កំណត់ភាពធ្ងន់ធ្ងរនៃជំងឺរបស់អ្នកជំងឺនៃមណ្ឌលថែទាំសុខភាព ត្រូវបញ្ជាក់ដោយគណៈកម្មការគោលនយោបាយសុខាភិបាលរដ្ឋម៉ាសាឈូសេត Massachusetts តាមការបំពេញតាមលក្ខណៈវិនិច្ឆ័យខាងលើ ហើយគណៈកម្មការអាចចេញបទបញ្ជាគ្រប់គ្រងឧបករណ៍បែបនេះ ដែលរួមមានខ្លឹមសារនិងការអនុវត្តរបស់ពួកគេ ។ ឧបករណ៍កំណត់ភាពធ្ងន់ធ្ងរនៃជំងឺរបស់អ្នកជំងឺ និងព័ត៌មានបែបនេះ ដែលមាន និងបានចងក្រងជាឯកសារនៅក្នុងនោះ ត្រូវមានជាផ្នែកមួយនៃកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នកជំងឺ ។

ផ្នែក 231G ៖ ច្បាប់នេះមិនត្រូវបានបកស្រាយ ដើម្បីធ្វើឱ្យខូចខាតដល់កិច្ចព្រមព្រៀងដែលយល់ព្រមរួមគ្នាណាមួយ ឬកិច្ចសន្យាណាមួយផ្សេងទៀត ដែលមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទមានប្រសិទ្ធភាពនៃច្បាប់នេះ ប៉ុន្តែត្រូវមានអានុភាពនិងប្រសិទ្ធភាពពេញលេញតាមកាលបរិច្ឆេទផុតកំណត់ដំបូងនៃកិច្ចព្រមព្រៀងដែលយល់ព្រមរួមគ្នាណាមួយបែបនេះ ឬកិច្ចសន្យាផ្សេងទៀត ។ គ្មានអ្វីនៅក្នុងច្បាប់នេះ ត្រូវរារាំងសុពលភាព ឬការអនុវត្តលក្ខខណ្ឌនានានៅក្នុងកិច្ចព្រមព្រៀងដែលយល់ព្រមរួមគ្នា ឬកិច្ចសន្យាផ្សេងទៀត ដែលផ្ដល់ជូនចំនួនអ្នកជំងឺមានទាបជាងចំនួនដែលបានបែងចែកទៅគិលានុបដ្ឋាយិកាម្នាក់ជាងចំនួនដែលបានណែនាំតាមការកំណត់បែងចែកចំនួនអ្នកជំងឺ ដែលបានកំណត់នៅក្នុងច្បាប់នេះ ។

ផ្នែក 231H ៖ ការអនុវត្ត។ គណៈកម្មការគោលនយោបាយសុខភាពរដ្ឋម៉ាសាឈូសេត Massachusetts អាចធ្វើការត្រួតពិនិត្យមណ្ឌលថែទាំសុខភាពនានា ដើម្បីធានាដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ ។ ការខកខានរបស់មជ្ឈមណ្ឌលក្នុងការប្រកាន់ខ្ជាប់ចំពោះការកំណត់បែងចែកចំនួនអ្នកជំងឺដែលមានចែងក្នុងផ្នែក 231C ដែលត្រូវបានកែតម្រូវតាមតម្រូវការទាមទារនានា ដូចមានចែងនៅក្នុងផ្នែក 231D និង 231F ត្រូវរាយការណ៍ដោយគណៈកម្មការគោលនយោបាយសុខាភិបាលរដ្ឋម៉ាសាឈូសេត Massachusetts ជូនទៅអគ្គព្រះរាជអាជ្ញា ដើម្បីអនុវត្ត ។ អគ្គព្រះរាជអាជ្ញាអាចនាំយកវិធានការតុលាការកំពូល ដែលស្វែងរកការដោះបន្ទុកតាមបង្គាប់បញ្ជា និងការពិន័យរដ្ឋប្បវេណីក្នុងចំនួនទឹកប្រាក់រហូតដល់ម្ភៃប្រាំពាន់ដុល្លារក្នុងមួយករណីការរំលោភបំពានមួយដង ។ ការរំលោភបំពានដាច់ដោយឡែកនិងផ្សេងគ្នា ដែលក្នុងនោះមណ្ឌលថែទាំសុខភាព ត្រូវកំណត់ពិន័យរដ្ឋប្បវេណីរហូតដល់ម្ភៃប្រាំពាន់ដុល្លារ ត្រូវចាត់ទុកថាបានប្រព្រឹត្តជារៀងរាល់ថ្ងៃ ដែលនៅអំឡុងពេលនោះការរំលោភបំពាននៅតែបន្តជូនដំណឹងជាបន្តបន្ទាប់ដល់មណ្ឌលថែទាំសុខភាព ។ នៅពេលមានលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរដោយគណៈកម្មការគោលនយោបាយសុខាភិបាលថាពាក្យបណ្ដឹងត្រូវបានធ្វើឡើង ឬការរំលោភត្រូវបានកើតមានឡើងនោះ មណ្ឌលថែទាំសុខភាពដែលទទួលបានលិខិតជូនដំណឹងបែបនេះ ត្រូវប្រគល់ជូនផែនការប្រតិបត្តិស្របច្បាប់ជាលាយលក្ខណ៍អក្សរទៅគណៈកម្មការដែលបង្ហាញអំពីរបៀបដែលមណ្ឌលថែទាំសុខភាពនឹងធានាដល់ការគោរពតាមបទប្បញ្ញត្តិទាំងអស់នៃច្បាប់នេះនាពេលអនាគត នៅក្នុងក្របខណ្ឌពេលវេលាដែលកំណត់ដោយគណៈកម្មការ ។ គ្មាននិយោជិតណាម្នាក់ ត្រូវទទួលរងការដាក់វិន័យ ឬការសងសឹកតាមរបៀបណាមួយចំពោះគោរពតាមការកំណត់អ្នកជំងឺដែលមានចែងក្នុងផ្នែក 231C ខាងលើឡើយ ហើយបុគ្គលិកណាម្នាក់បែបនេះ ដែលបានទទួលរងការដាក់វិន័យ ឬការសងសឹកនោះ ត្រូវទទួលបានសិទ្ធិចំពោះដំណោះស្រាយ ដែលមានចែងក្នុងផ្នែក 185(d) នៃជំពូក 149 ដោយមិនគិតថាតើនិយោជិតពេញចិត្តតាមការកំណត់ពេលវេលាឬ លក្ខខណ្ឌណាមួយផ្សេងទៀត ដែលមានចែងនៅក្នុងផ្នែក 185 នៃជំពូក 149 ឡើយ ។ តម្រូវការទាមទារច្បាប់នេះ និងការអនុវត្តរបស់ខ្លួន ត្រូវផ្អាកនៅអំឡុងពេលមានភាពអាសន្នផ្នែកសុខភាពសាធារណៈដែលប្រកាសនៅថ្នាក់រដ្ឋ ឬថ្នាក់ជាតិ ។

ផ្នែក 231I ៖ មណ្ឌលថែទាំសុខភាពនីមួយៗ ត្រូវបិទប្រកាសនៅកន្លែងដែលអាចមើលឃើញ ឬនៅកន្លែងនានានៅបរិវេណរបស់ខ្លួន ដែលរួមមាននៅក្នុងបន្ទប់នីមួយៗ បន្ទប់អ្នកជំងឺ និងកន្លែងរង់ចាំ លិខិតជូនដំណឹងត្រូវរៀបចំឬអនុម័តដោយគណៈកម្មការគោលនយោបាយសុខភាពរដ្ឋម៉ាសាឈូសេត Massachusetts ដែលអាចអានយ៉ាងងាយស្រួលជាភាសាអង់គ្លេស និងភាសាផ្សេងទៀតដែលកំណត់ដោយគណៈកម្មការដែលដាក់ចេញសេចក្ដីដកស្រង់នានានៃច្បាប់នេះ ដែលរួមមានការកំណត់បែងចែកចំនួនអ្នកជំងឺទាំងអស់ ដែលមានចែងក្នុងផ្នែក 231C ដែលស្របតាមលក្ខណៈនេះ ដែលក្នុងនោះត្រូវរាយការណ៍អំពីការរំលោភបំពាន និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដែលគណៈកម្មការគិតថាចាំបាច់ ដើម្បីពន្យល់អំពីតម្រូវការទាមទារនៃច្បាប់នេះ ។ មណ្ឌលថែទាំសុខភាពណាមួយកំណត់ចំពោះច្បាប់នេះ ដែលបដិសេធមិនគោរពតាមបទប្បញ្ញត្តិនានានៃផ្នែកនេះ ត្រូវផ្ដន្ទាទោសតាមការពិន័យរដ្ឋប្បវេណីនូវចំនួនទឹកប្រាក់មិនតិចជាងពីររយហាសិបដុល្លារ និងមិនលើសពីពីរពាន់ប្រាំរយដុល្លារក្នុងមួយថ្ងៃ ដែលមណ្ឌលថែទាំសុខភាពនោះមិនគោរពច្បាប់ ។ បទប្បញ្ញត្តិនានានៃផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គព្រះរាជអាជ្ញា ។

ផ្នែក 231J ៖ គណៈកម្មការគោលនយោបាយសុខាភិបាលរដ្ឋម៉ាសាឈូសេត Massachusetts នឹងរៀបចំបើកលេខទូរស័ព្ទមួយខ្សែដែលហៅទូរស័ព្ទដោយឥតគិតថ្លៃ ដែលអាចរាយការណ៍អំពីពាក្យបណ្ដឹងប្រឆាំងនឹងមណ្ឌលថែទាំសុខភាពនានា ហើយគេហទំព័រសាធារណៈដែលពាក្យបណ្ដឹង ការបញ្ជាក់វិញ្ញាបនប័ត្រ ផែនការប្រតិបត្តិស្របច្បាប់ និងការរំលោភបំពាន ត្រូវបង្ហាញនិងធ្វើបច្ចុប្បន្នភាពយ៉ាងហោចណាស់ជារៀងរាល់ខែម្ដង សម្រាប់មណ្ឌលថែទាំសុខភាពនីមួយៗ ។ លេខទូរស័ព្ទដោយឥតគិតថ្លៃ និងទីតាំងវែបសាយ ត្រូវរាប់បញ្ចូលក្នុងលិខិតជូនដំណឹងទាំងអស់ដែលបានរៀបចំ និងបិទប្រកាសដោយស្របតាមផ្នែក 231I ខាងលើ ។

ផ្នែក 2 ៖ ភាពដោយឡែក ។ បទប្បញ្ញត្តិនានានៃច្បាប់នេះ អាចមានដោយឡែក ដោយមូលហេតុបែបនោះប្រសិនបើជំពូកច្បាប់ ប្រយោគ កថាខណ្ឌ ឬផ្នែក ឬការដាក់ពាក្យសុំនោះ ត្រូវបានវិនិច្ឆ័យទោសដោយតុលាការនៃយុត្តាធិការដែលមានសមត្ថកិច្ចដើម្បីបញ្ជាក់ថាមិនត្រឹមត្រូវនោះ យុត្តាធិការបែបនេះមិនមានផលប៉ះពាល់ ធ្វើឱ្យខូចខាត ធ្វើឱ្យអស់សុពលភាពផ្នែកនៅសល់នៃជំពូកច្បាប់ ប្រយោគ កថាខណ្ឌ ឬផ្នែកណាមួយ ហើយត្រូវកំណត់ក្នុងប្រតិបត្តិការរបស់ខ្លួនចំពោះជំពូកច្បាប់ ប្រយោគ កថាខ័ណ្ឌ ផ្នែក ឬពាក្យសុំដែលចាត់ទុកថាមិនត្រឹមត្រូវ; ប្រសិនបើជំពូកច្បាប់ ប្រយោគ កថាខ័ណ្ឌ ផ្នែក ឬពាក្យសុំណាមួយបែបនេះ ដែលចាត់ទុកថាមិនត្រឹមត្រូវនោះ ត្រូវកំណែទម្រង់ និងបកស្រាយចំណុចបែបនោះ ដែលវាត្រឹមត្រូវចំពោះវិសាលភាពអតិបរមាដែលបានអនុញ្ញាត ។

ផ្នែក 3 ៖ ច្បាប់នេះ ត្រូវចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2019។

# 2

**សំណួរ 2 ៖ ច្បាប់ដែលស្នើឡើងតាមបណ្ដឹងទាមទារដែលមានគំនិតផ្ដួចផ្ដើម**

# *កម្រៃជើងសារលើការកំណត់ចំណាយបោះឆ្នោត និងសិទ្ធិសាជីវកម្ម*

*តើលោកអ្នកយល់ព្រមចំពោះច្បាប់ដែលបានសង្ខេបខាងក្រោមដែលក្នុងនោះគ្មានសម្លេងឆ្នោតគាំទ្រត្រូវបានទទួលយកដោយព្រឹទ្ធសភា ឬអ្នកតំណាងមន្ទីរដ្ឋសភានៅថ្ងៃ ឬមុនថ្ងៃទី 2 ខែឧសភា ឆ្នាំ 2018 ឬទេ?*

---

**សេចក្ដីសង្ខេប**
តាមការកំណត់ដោយច្បាប់ សេចក្ដីសង្ខេបត្រូវបានសរសេរដោយអគ្គព្រះរាជអាជ្ញារដ្ឋ ។

▶ ច្បាប់ដែលបានស្នើឡើងនេះ នឹងបង្កើតគណៈកម្មការ (citizens commission) ដើម្បីគិតពិចារណានិងផ្ដល់អនុសាសន៍ដល់ការធ្វើវិសោធនកម្មជាសក្ដានុពលចំពោះរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ដើម្បីកំណត់ថាសាជីវកម្មមិនមានសិទ្ធិតាមធម្មនុញ្ញដូចគ្នានឹងប្រជាពលរដ្ឋ ហើយការចូលរួមយុទ្ធនាការ និងការចំណាយនានា អាចត្រូវបានកំណត់ ។

អ្នករស់នៅណាម្នាក់នៅរដ្ឋម៉ាសាឈូសេត Massachusetts ដែលជាពលរដ្ឋអាមេរិក នឹងអាចដាក់ពាក្យសុំការតែងតាំងគណៈកម្មការដែលមានសមាជិកចំនួន 15 នាក់ ហើយសមាជិកនានានឹងបម្រើការដោយគ្មានសំណង ។ អភិបាលរដ្ឋ លេខាធិការសហគមន៍ឯករាជ្យ អគ្គព្រះរាជអាជ្ញារដ្ឋ អ្នកនាំពាក្យនៃអ្នកតំណាងមន្ទីរសភារដ្ឋ និងប្រធានព្រឹទ្ធសភារដ្ឋ ដែលម្នាក់ៗអាចតែងតាំងសមាជិកគណៈកម្មការចំនួនបីរូប ហើយក្នុងការតែងតាំងទាំងនេះ នឹងស្វែងរកដើម្បីធានាថា គណៈកម្មការនេះបង្ហាញពីប្រវត្តិភូមិសាស្ត្រ នយោបាយ និងប្រជាសាស្ត្រ ។

គណៈកម្មនេះនឹងត្រូវបានគេទាមទារឱ្យមានការស្រាវជ្រាវ និងការធ្វើជាកសិណសក្សី ហើយបន្ទាប់មកចេញរបាយការណ៍ដែលទាក់ទងនឹង (1) ផលប៉ះពាល់ពីការចំណាយខាងនយោបាយនៅរដ្ឋម៉ាសាឈូសេត Massachusetts; (2) ការកំណត់សមត្ថភាពរបស់រដ្ឋ ដើម្បីគ្រប់គ្រងសាជីវកម្មនិងអង្គភាពផ្សេងទៀត ដោយផ្អែកលើការសម្រេចចិត្តរបស់តុលាការកំពូលដែលអនុញ្ញាតឱ្យសាជីវកម្មនានាដើម្បីអះអាងការពារសិទ្ធិតាមរដ្ឋធម្មនុញ្ញជាក់លាក់; (3) ការផ្ដល់អនុសាសន៍ចំពោះការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ; (4) ការវិភាគវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលបានណែនាំដល់សភា; និង (5) ការផ្ដល់អនុសាសន៍អំពីការជម្រុញវិសោធនកម្មដែលបានស្នើឡើងចំពោះរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ។

គណៈកម្មការនេះនឹងកំណត់តាមច្បាប់ស្ដីពីកិច្ចប្រជុំបើកចំហនៅថ្នាក់រដ្ឋ និងច្បាប់ស្ដីពីកំណត់ត្រាសាធារណៈ ។ របាយការណ៍ដំបូងរបស់គណៈកម្មការនឹងដល់ពេលកំណត់នៅថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019 ហើយលេខាធិការសហគមន៍ឯករាជ្យនឹងត្រូវបានគេទាមទារឱ្យបញ្ជូនរបាយការណ៍របស់គណៈកម្មការទៅអង្គនីតិបញ្ញត្តិរដ្ឋ សភាសហរដ្ឋអាមេរិក និងប្រធានាធិបតីសហរដ្ឋអាមេរិក ។

ច្បាប់ដែលបានស្នើឡើងកំណត់ថា ប្រសិនបើផ្នែកណាមួយរបស់វាត្រូវបានប្រកាសថាមិនត្រឹមត្រូវនោះ ផ្នែកផ្សេងទៀតនឹងនៅជាធរមាន ។ ច្បាប់ដែលបានស្នើឡើងនេះ នឹងចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2019។

---

**សម្លេងឆ្នោតគាំទ្ររបស់អ្នកនឹងមានន័យអ្វីខ្លះ**
តាមការកំណត់ដោយច្បាប់ របាយការណ៍នានាដែលរៀបរាប់អំពីផលប៉ះពាល់ដល់សម្លេងឆ្នោត "បាទ/ចាស៎" ឬ "ទេ" ត្រូវបានសរសេររួមគ្នាដោយអគ្គព្រះរាជអាជ្ញារដ្ឋ និងលេខាធិការសហគមន៍ឯករាជ្យ ។

▶ ***ការបោះឆ្នោត បាទ/ចាស៎*** នឹងបង្កើតគណៈកម្មការ (citizens commission) ដើម្បីជម្រុញការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ដើម្បីកំណត់ឥទ្ធិពលប្រាក់នៅក្នុងការបោះឆ្នោត និងកំណត់ថាសាជីវកម្មនានាមិនមានសិទ្ធិដូចគ្នានឹងពលរដ្ឋឡើយ ។

***ការបោះឆ្នោត ទេ*** នឹងមិនបង្កើតកម្រៃជើងសារនេះ ។

---

**របាយការណ៍អំពីផលវិបាកនៃសារពើពន្ធ**
តាមការកំណត់ដោយច្បាប់នោះ របាយការណ៍អំពីផលវិបាកនៃសារពើពន្ធ ត្រូវបានសរសេរដោយការិយាល័យប្រតិបត្តិផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ។

▶ ច្បាប់ដែលបានស្នើឡើងនេះ មិនមានផលវិបាកខាងសារពើពន្ធដែលអាចយល់ដឹងអំពីហិរញ្ញវត្ថុរដ្ឋាភិបាល ក្រុង និងរដ្ឋឡើយ ។

**ការពិភាក្សារកហេតុផល ▶** តាមការកំណត់ដោយច្បាប់ ការពិភាក្សារកហេតុផលដែលមាន 150 ពាក្យ ត្រូវបានសរសេរដោយអ្នកគាំទ្រ និងអ្នកប្រឆាំងចំពោះសំណួរនីមួយៗ និងបង្ហាញអំពីមតិយោបល់របស់ពួកគេ ។ សហគមន៍ឯករាជ្យនៃរដ្ឋម៉ាសាឈូសេត Massachusetts មិនយល់ព្រមចំពោះការពិភាក្សារកហេតុផលទាំងនេះទេ ហើយមិនបញ្ជាក់ភាពត្រឹមត្រូវនៃរបាយការណ៍ណាមួយដែលបានធ្វើឡើងនៅក្នុងការពិភាក្សារកហេតុផលទាំងនេះឡើយ ។ ឈ្មោះរបស់បុគ្គលនិងអង្គភាពនានាដែលបានសរសេរការពិភាក្សារកហេតុផលនីមួយៗ និងមតិយោបល់ណាមួយដែលសរសេរជាលាយលក្ខណ៍អក្សរដោយអ្នកដទៃទៀតអំពីការពិភាក្សារកហេតុផលនីមួយៗនោះ មាននៅក្នុងឯកសារនៅការិយាល័យលេខាធិការសហគមន៍ឯករាជ្យ ។

***តាមចំណូលចិត្ត ៖*** ការបោះឆ្នោត បាទ/ចាស៎ ជម្រុញការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក ដើម្បីកំណត់ឥទ្ធិពលប្រាក់នៅក្នុងការបោះឆ្នោត និងធានាថាពលរដ្ឋអាមេរិកទាំងអស់ មានការសម្ដែងមតិយោបល់ស្មើគ្នានៅក្នុងលទ្ធិប្រជាធិបតេយ្យរបស់យើង ។

ចំពោះបញ្ហាប្រឈមនៃប្រទេសជាតិរបស់យើង គឺវិបត្តិរបស់មហាសេដ្ឋី និងផលប្រយោជន៍ពិសេសដោយប្រើលុយដើម្បីទិញចូលយកឱកាសប្រើប្រាស់ និងមានឥទ្ធិពលលើអ្នកនយោបាយទាំងឡាយ ។ ផលប្រយោជន៍ពិសេសទាំងនេះ ត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ នៅខណៈពេលប្រជាពលរដ្ឋអាមេរិកភាគច្រើន មិនមានឡើយ ។

តុលាការកំពូលនិយាយថាច្បាប់នានាដែលកំណត់ការចំណាយខាងនយោបាយ រំលោភបំពានលើវិសោធនកម្មលើកដំបូង ។ ពលរដ្ឋអាមេរិកភាគច្រើន ដឹងថាការណ៍នេះមិនត្រឹមត្រូវ ៖ លុយមិនមែនជាការបញ្ចេញមតិទេ វាជាអំណាច ហើយអំណាចប្រមូលផ្ដុំតម្រូវឱ្យមានការត្រួតពិនិត្យ និងការរក្សាតុល្យភាព ។ ពលរដ្ឋអាមេរិក 75% ដែលរួមមានអ្នកសេរីនិយម និងអ្នកអភិរក្សនិយមគាំទ្រវិសោធនកម្មនេះ ដើម្បីកែតម្រូវតុលាការដែលមាន 19 រដ្ឋ និងសហគមន៍ម៉ាសាឈូសេត Massachusetts ជាង 200 ដែលអំពាវនាវជាផ្លូវការ ។

វិធានការនេះបង្ហាញថា គណៈកម្មការពលរដ្ឋដែលមិនបង់ប្រាក់ គ្មានការប្រកាន់បក្សពួក ដើម្បីតស៊ូមតិរបស់ប្រជាពលរដ្ឋសម្រាប់វិសោធនកម្មនេះ ដោយមានអ្នកយកកម្រៃជើងសារដែលបម្រើការងារដោយគ្មានការចំណាយលើអ្នកបង់ពន្ធ ។

**Jeff Clements**
**ពលរដ្ឋគ្រប់គ្រង មិនមែនលុយទេ (People Govern, Not Money)**
**33 Bradford St.**
**Concord, MA 01742**
**978-254-6275**
**https://voteyeson2ma.org**

***ការជំទាស់ ៖*** ភាពចម្រូងចម្រាសជុំវិញការសម្រេចចិត្តរួមគ្នារបស់ប្រជាពលរដ្ឋ Citizens United ដោយផ្អែកលើសិទ្ធិសេរីភាពបញ្ចេញមតិដែលពេញចិត្តបំផុតរបស់យើង ។ ចំពោះការសម្រេចនេះ តុលាការបានសម្រេចបើកទូលាយនូវសេរីភាពនោះ និងអនុវត្តវាដូចគ្នាចំពោះអង្គភាព និងអង្គការទាំងអស់ជាជាងមានតែបញ្ជីអ្នកឈ្នះនិងអ្នកចាញ់ដែលធ្វើតាមទំនើងចិត្តដោយមន្ត្រីជាប់ឆ្នោតនៅក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុយុទ្ធនាការកាលពីមុន ។

ការណ៍នេះជារឿងល្អ ។ ការការពារវិសោធនកម្មលើកដំបូងសម្រាប់សេរីភាពបញ្ចេញមតិរបស់យើងគឺជាចំណុចសំខាន់មួយនៃលទ្ធិប្រជាធិបតេយ្យរបស់យើង ហើយត្រូវបានការពារ និងពង្រីកនៅគ្រប់ឱកាសដែលអាចប្រព្រឹត្តទៅបាន ។ រដ្ឋាភិបាលរំខានតិចតួចចំពោះការអនុវត្តសិទ្ធិនោះ វាធ្វើឱ្យកាន់តែខ្លាំងជាង ។

ប៉ុន្តែបើទោះជាលោកអ្នកមិនយល់ស្របនឹងការសម្រេចចិត្តរបស់ប្រជាពលរដ្ឋ Citizens United ក៏ដោយ ក៏ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក គឺជាមធ្យោបាយគ្រោះថ្នាក់ និងមធ្យោបាយខុសឆ្គង ដើម្បីដោះស្រាយបញ្ហានោះ ។ សូមបោះឆ្នោត ទេ នៅក្នុងសំណួរនេះ ។

**Massachusetts Fiscal Alliance**
**18 Tremont St., Suite 527**
**Boston, MA 02108**
**www.MassFiscal.org**
**www.MassFiscalScorecard.org**

## អត្ថបទសំណួរពេញលេញ

វាត្រូវអនុម័តដោយប្រជាពលរដ្ឋ និងដោយអាជ្ញាធររបស់ពួកគេ ៖

ផ្នែក 1 ៖ គោលនយោបាយ និងគោលបំណង

a. ច្បាប់នេះបង្កើតគណៈកម្មការពលរដ្ឋ ដែលគ្មានការប្រកាន់បក្សពួក ដើម្បីជម្រុញគោលនយោបាយរដ្ឋម៉ាសាឈូសេត Massachusetts តាមចំណូលចិត្តចំពោះការកែប្រែរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក (i) បញ្ជាក់ថាអង្គភាពសិប្បនិម្មិតមិនមានសិទ្ធិប្រជាពលរដ្ឋចំពោះរដ្ឋធម្មនុញ្ញដែលមិនអាចលុបបាន ហើយ (ii) ដើម្បីលុបបំបាត់ឥទ្ធិពលហួសហេតុពីលុយដែលប្រមូលផ្ដុំលើការបោះឆ្នោតនានាចំពោះគោលនយោបាយរបស់រដ្ឋាភិបាល ការចូលរួមយុទ្ធនាការ និងការចំណាយដែលអាចធ្វើនិយតកម្ម និងកំណត់លក្ខខណ្ឌ ។

b. វាជាបំណងនៃច្បាប់នេះដែលការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ឬការធ្វើវិសោធនកម្មដែលបានស្នើឡើងដែលជាកម្មវត្ថុនៃច្បាប់នេះ ត្រូវបានព្រាងនិងបកស្រាយដើម្បីការពារសេចក្ដីសុចរិតភាពនិងយុត្តិធម៌នៃការបោះឆ្នោត និងរដ្ឋាភិបាល; បង្ការអំពើពុករលួយ; ការពារសិទ្ធិពលរដ្ឋអាមេរិកទាំងអស់ដែលត្រូវធ្វើជាតំណាង និងចូលរួមក្នុងរដ្ឋាភិបាលដោយខ្លួនឯងជាពលរដ្ឋស្មើភាពគ្នា; ការពារសេរីភាពនៃការបញ្ចេញមតិយោបល់ សារព័ត៌មាន និងសិទ្ធិផ្សេងៗរបស់ពលរដ្ឋអាមេរិកទាំងអស់ចំពោះអភ័យសិទ្ធិរបស់អង្គភាពសិប្បនិម្មិតនានា; និងធានាស្របតាមរដ្ឋធម្មនុញ្ញភាពដែលមានបទបញ្ជាត្រឹមត្រូវ និងប្រតិបត្តិការសាជីវកម្ម និងអង្គភាពសេដ្ឋកិច្ចផ្សេងៗទៀតដោយប្រជាពលរដ្ឋ ។

c. ដើម្បីជួយបំណងនេះ និងជម្រុញវិសោធនកម្មរដ្ឋធម្មនុញ្ញ និងគោលនយោបាយដែលបានពណ៌នានៅទីនេះ តាមន័យនេះគណៈកម្មការពលរដ្ឋ ដែលគ្មានការប្រកាន់បក្សពួក ដែលឯករាជ្យ ត្រូវបានបង្កើតឡើងសម្រាប់គោលបំណងនៃការរាយការណ៍ និងការផ្ដល់អនុសាសន៍ដែលអាចមានជំនួយក្នុងការធ្វើសេចក្ដីព្រាង ការលើកកម្ពស់ ការស្នើសុំ និងការផ្ដល់សច្ចាប័នលើការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញបែបនេះ។

d. ច្បាប់នេះ ត្រូវបានគេស្គាល់ថាជាគណៈកម្មការ Citizens Commission ដែលទាក់ទងនឹងវិសោធនកម្មរដ្ឋធម្មនុញ្ញចំពោះរដ្ឋាភិបាលពីច្បាប់ពលរដ្ឋ ។

ផ្នែក 2 ៖ ការបង្កើតគណៈកម្មការ Citizens Commission ដែលទាក់ទងនឹងវិសោធនកម្មរដ្ឋធម្មនុញ្ញចំពោះរដ្ឋាភិបាលពីច្បាប់ពលរដ្ឋ ។

a) ច្បាប់នេះកំណត់គណៈកម្មការ Citizens Commission ដែលទាក់ទងនឹងវិសោធនកម្មរដ្ឋធម្មនុញ្ញចំពោះរដ្ឋាភិបាលពីច្បាប់ពលរដ្ឋ ដើម្បីលើកកម្ពស់គោលនយោបាយសហគមន៍ឯករាជ្យនៃរដ្ឋម៉ាសាឈូសេត Massachusetts (1) ថាសិទ្ធិរដ្ឋធម្មនុញ្ញ

## អត្ថបទសំណួរពេញលេញ (បន្ត)

ដែលមិនអាចលុបចោលបានគឺជាសិទ្ធរបស់ពលរដ្ឋដែលរស់នៅជាលក្ខណៈឯកជន និងមិនមែនជាអង្គភាពសិប្បនិម្មិត ឬការប្រមូលផ្តុំប្រជាពលរដ្ឋឡើយ និង (2) ដូចមានចែងនៅក្នុងដំណោះស្រាយដែលបានអនុម័តដោយតុលាការធម្មតានៃរដ្ឋម៉ាសាឈូសេត Massachusetts ក្នុងឆ្នាំ 2012 ដែលបានដោះស្រាយថា "សហគមន៍ឯករាជ្យនៃរដ្ឋម៉ាសាឈូសេត Massachusetts ដែលតាមន័យនេះសូមអំពាវនាវដល់សភាសហរដ្ឋអាមេរិក ដើម្បីអនុម័ត និងបញ្ជូនទៅរដ្ឋនានាដើម្បីផ្តល់សច្ចាប័នលើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីស្តារឡើងវិញនូវវិសោធនកម្មលើកដំបូង និងការបោះឆ្នោតដោយយុត្តិធម៌ជូនប្រជាពលរដ្ឋ" ដោយផ្អែកលើចំណុចដូចខាងក្រោម ៖

i) "ចំណែកឯវិសោធនកម្មលើកដំបូងចំពោះរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក បានរៀបចំឡើងដើម្បីការពារសិទ្ធិសេរីភាពចំពោះប្រជាពលរដ្ឋក្នុងការបញ្ចេញមតិយោបល់ដែលមិនមែនសាជីវកម្មឡើយ;

ii) នៅអំឡុងពេលបីទសវត្សរ៍កន្លងមកនេះ តុលាការកំពូលរបស់សហរដ្ឋអាមេរិកដែលបានបែងចែកនោះ មានផ្លាស់ប្តូរវិសោធនកម្មលើកដំបូងទៅជាឧបករណ៍ដ៏មានឥទ្ធិពលមួយសម្រាប់ក្រុមហ៊ុនសាជីវកម្មដែលស្វែងរកចៀសវាង និងធ្វើឱ្យបែកបាក់ដល់កំណែទម្រង់ការអនុម័តច្បាប់តាមបែបលទ្ធិប្រជាធិបតេយ្យ;

iii) ខណៈពេលការកាន់កាប់សាជីវកម្មពីវិសោធនកម្មលើកដំបូង នេះ បានឈានដល់ការសន្និដ្ឋានយ៉ាងជ្រាលជ្រៅរបស់ខ្លួន ចំពោះការសម្រេចរបស់តុលាការកំពូលសហរដ្ឋអាមេរិកនាពេលថ្មីៗនេះ នៅក្នុងផ្នែក *Citizens United v. FEC*;

iv) ខណៈពេលការសម្រេចរបស់តុលាការកំពូលរបស់សហរដ្ឋអាមេរិកនៅក្នុងផ្នែក *Citizens United v. FEC* បានបដិសេធសាជីវកម្មដែលហាមឃាត់រយៈពេលយូរអង្វែងពីការចំណាយប្រាក់រតនាគារទូទៅរបស់ខ្លួននៅក្នុងការបោះឆ្នោតរបស់យើង;

v) ខណៈពេលការសម្រេចរបស់តុលាការកំពូលរបស់សហរដ្ឋអាមេរិកនៅក្នុងផ្នែក *Citizens United v. FEC* ដែលឥឡូវនេះនឹងបង្ហាញការធ្លាក់ចុះយ៉ាងគំហុកពីប្រាក់កាសាជីវកម្មនៅក្នុងដំណើរការនយោបាយរបស់យើង ដែលមិនស្របគ្នាពីការសុបចំណាយលើយុទ្ធនាការនៅក្នុងប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក;

iv) ខណៈពេលការសម្រេចរបស់តុលាការកំពូលរបស់សហរដ្ឋអាមេរិកនៅក្នុងផ្នែក *Citizens United v. FEC* បង្ហាញពីការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរនិងដោយផ្ទាល់ដល់លទ្ធិប្រជាធិបតេយ្យរបស់យើង;

vii) ទន្ទឹមនេះ កាលពីមុនប្រជាពលរដ្ឋអាមេរិកធ្លាប់បានប្រើប្រាស់ដំណើរការវិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីកែតម្រូវការសម្រេចចិត្តរបស់តុលាការជាន់ខ្ពស់សហរដ្ឋអាមេរិកដែលមានកំហុសឆ្គងមិនប្រក្រតីទាំងនោះ ដែលស្ថិតនៅក្នុងបេះដូងនៃលទ្ធិប្រជាធិបតេយ្យរបស់យើង និងរដ្ឋាភិបាលខ្លួនឯង ។"

b) ប្រជាពលរដ្ឋរកឃើញនិងប្រកាសថាគ្មានការប្រកាន់បក្សពួក ដូចជាបានផ្តល់ជូននៅទីនេះនឹងធានាការគិតពិចារណាដោយប្រុងប្រយ័ត្នអំពីវិសោធនកម្មរដ្ឋធម្មនុញ្ញបែបនេះតាមរយៈគណៈប្រតិភូសភាម៉ាសាឈូសេត Massachusetts និងតាមរយៈប្រជាពលរដ្ឋនិងតុលាការធម្មតានៃរដ្ឋម៉ាសាឈូសេត Massachusetts នៅអំឡុងពេលដំណើរការផ្តល់សច្ចាប័ន ដើម្បីទទួលបានការអនុម័តពីសភា ។

c) គណៈកម្មការ Citizens Commission ត្រូវធ្វើការស្រាវជ្រាវ ទទួលយកចម្លើយកសិណសាក្សី របាយការណ៍ និងការផ្តល់អនុសាសន៍បែបនេះ ដែលអាចជាជំនួយក្នុងការធ្វើសេចក្តីព្រាង ការជម្រុញ ការស្នើសុំ ការផ្តល់សច្ចាប័នលើវិសោធនកម្មរដ្ឋធម្មនុញ្ញបែបនេះ ។

ផ្នែក 3 ៖ សមាសភាព ការតែងតាំង និងដំណើរការពិភាក្សា

a) គណៈកម្មការ Citizens Commission ត្រូវមានពលរដ្ឋអាមេរិកចំនួន 15 នាក់ ដែលជាអ្នករស់នៅរដ្ឋម៉ាសាឈូសេត Massachusetts ហើយត្រូវបានតែងតាំងដូចខាងក្រោម ៖

   i) អភិបាលរដ្ឋ ត្រូវតែងតាំងសមាជិក 3 នាក់;

   ii) លេខាធិការសហគមន៍ឯករាជ្យ ត្រូវតែងតាំងសមាជិក 3 នាក់;

   iii) អគ្គព្រះរាជអាជ្ញា ត្រូវតែងតាំងសមាជិក 3 នាក់;

   iv) អ្នកនាំពាក្យមន្ទីររដ្ឋសភា ត្រូវតែងតាំងសមាជិក 3 នាក់; និង

   v) ប្រធានព្រឹទ្ធសភា ត្រូវតែងតាំងសមាជិក 3 នាក់;

b) គ្មាននរណាម្នាក់ត្រូវបានតែងតាំងគណៈកម្មការ Citizens Commission ដែលមិនបានដាក់ពាក្យសុំជាសាធារណៈសម្រាប់ការតែងតាំងបែបនេះ ដោយមានពាក្យសុំនានាដែលអភិបាលរដ្ឋត្រូវបិទប្រកាសនៅលើទំព័រដែលបង្កើតឡើងសម្រាប់ការដឹងឮជាសាធារណៈ និងការត្រួតពិនិត្យអំពីការតែងតាំងនិងការប្រព្រឹត្តទៅរបស់គណៈកម្មការ Citizens Commission តាមគេហទំព័រផ្លូវការនៃសហគមន៍ឯករាជ្យនៃរដ្ឋម៉ាសាឈូសេត Massachusetts ។

c) ការដាក់ពាក្យសុំពីប្រជាពលរដ្ឋណាម្នាក់ ដែលស្វែងរកបម្រើការងារគណៈកម្មការនេះត្រូវកំណត់ថា ៖

   i) បំណងរបស់អ្នកដាក់ពាក្យសុំ ដើម្បីគោរពនិងជម្រុញគោលនយោបាយដែលបានបង្កើតឡើងដោយច្បាប់នេះ;

   ii) លក្ខណៈសម្បត្តិគ្រប់គ្រាន់ និងចំណាប់អារម្មណ៍របស់អ្នកដាក់ពាក្យសុំក្នុងការបម្រើការងារគណៈកម្មការ Citizens Commission;

   iii) ការជាប់ពាក់ព័ន្ធគណបក្សនយោបាយ ប្រសិនបើមានអ្នកដាក់ពាក្យសុំណាម្នាក់ដែលមានរយៈពេលលើសពី 5 ឆ្នាំមុន;

   iv) ទីក្រុង ឬខេត្ត ដែលក្នុងនោះអ្នកដាក់ពាក្យសុំរស់នៅ;

   v) ការងាររបស់អ្នកដាក់ពាក្យសុំ ប្រសិនបើមានការងារ ។

d) ពាក្យសុំទាំងអស់សម្រាប់សេវាកម្មគណៈកម្មការ Citizens Commission ត្រូវដាក់ជូនក្នុងរយៈពេល 60 ថ្ងៃ បន្ទាប់ពីការប្រកាសអំពីឱកាសតែងតាំងនៅលើគេហទំព័រជាផ្លូវការរបស់សហគមន៍ឯករាជ្យនៃរដ្ឋម៉ាសាឈូសេត Massachusetts ដែលប្រកាសពីអភិបាលរដ្ឋ ត្រូវធ្វើឡើងក្នុងរយៈពេល 30 ថ្ងៃ ចាប់ពីកាលបរិច្ឆេទមានប្រសិទ្ធភាពនៃច្បាប់នេះ ។

e) ការតែងតាំងគណៈកម្មការ Citizens Commission ទាំងអស់ ត្រូវធ្វើឡើងដែលមានរយៈពេលមិនច្រើនជាង 90 ថ្ងៃ និងមិនលើសពី 120 ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទមានប្រសិទ្ធភាពនៃច្បាប់នេះ ។

f) ចំពោះការតែងតាំងគណៈកម្មការ អភិបាលរដ្ឋ រដ្ឋមន្ត្រីក្រសួងការបរទេស អគ្គព្រះរាជអាជ្ញា ប្រធានព្រឹទ្ធសភា និងអ្នកនាំពាក្យនៃអ្នកតំណាងមន្ទីររដ្ឋសភាបានដល់ពេលកំណត់ដែលពាក់ព័ន្ធនឹងប្រភេទគណៈកម្មការ Citizens Commission ដែល

## អត្ថបទសំណួរពេញលេញ (បន្ត)

គ្មានការប្រកាន់បក្សពួក ហើយត្រូវស្វែងរកការធានាថាគណៈកម្មការ Citizens Commission ឆ្លុះបញ្ចាំងពីប្រវត្តិភូមិសាស្ត្រ នយោបាយ និងប្រជាសាស្ត្រ ។

g) អ្នកដែលគេតែងតាំងជាគណៈកម្មការ Citizens Commission ត្រូវបម្រើការងារដោយគ្មានសំណង ។

h) សមាជិកគណៈកម្មការ Citizens Commission ត្រូវជ្រើសរើសប្រធានឬសហប្រធានតាមលក្ខណៈដែលសមាជិកនៃគណៈកម្មការអាចសម្រេចតាមការបោះឆ្នោតសម្លេងភាគច្រើន ។

i) គណៈកម្មការ Citizens Commission ត្រូវជួបជុំគ្នា តាមគោលការណ៍ជាទៀងទាត់ដើម្បីប្រមូលភស្តុតាង ចម្លើយកសិណសាក្សី និងការផ្តល់ឱវាទតាមលក្ខណៈដែលសមាជិកគណៈកម្មការ កំណត់មានប្រសិទ្ធភាពបំផុតក្នុងការសម្រេចគោលបំណងនានានៃច្បាប់នេះ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ការបន្តដំណើរការនិងសកម្មភាពរបស់គណៈកម្មការ Citizen Commission ត្រូវស្ថិតនៅក្រោមច្បាប់ស្តីពីកិច្ចប្រជុំបើកចំហ និងច្បាប់ស្តីពីកំណត់ត្រាសាធារណៈ ហើយថាប្រជាពលរដ្ឋទាំងអស់នៅរដ្ឋម៉ាសាឈូសេត Massachusetts មានឱកាសសមហេតុសមផល ដើម្បីផ្តល់ជូនទស្សនៈនិងគំនិតយោបល់របស់ពួកគេដែលទាក់ទងនឹងគោលនយោបាយនៅក្នុងគណៈកម្មការនេះ ។

ផ្នែក 4 ៖ របាយការណ៍ និងអនុសាសន៍

a) គណៈកម្មការ Citizens Commission ត្រូវចេញរបាយការណ៍លទ្ធផល និងអនុសាសន៍ ដែលត្រូវរាប់បញ្ចូលដូចខាងក្រោម ៖

   i) ប្រភេទនិងផលប៉ះពាល់ចំពោះការចំណាយលើនយោបាយ និងការបោះឆ្នោតនៅក្នុងរដ្ឋម៉ាសាឈូសេត Massachusetts;

   ii) ការកំណត់លក្ខខណ្ឌនានា ប្រសិនបើមានសមត្ថភាពសហគមន៍ឯករាជ្យស្របច្បាប់ និងប្រជាពលរដ្ឋរបស់ខ្លួនក្នុងការគ្រប់គ្រងសាជីវកម្មនិងអង្គភាពផ្សេងៗដោយសមហេតុផល ដោយយោងតាមសេចក្តីសន្និដ្ឋានរបស់តុលាការកំពូលថាក្រុមហ៊ុនសាជីវកម្មនានាអាចអះអាងថាមានសិទ្ធិជាពលរដ្ឋតាមរដ្ឋធម្មនុញ្ញ;

   iii) អនុសាសន៍នានាចំពោះវិសាលភាពនិងភាសាសម្រាប់ដំណោះស្រាយវិសោធនកម្មរដ្ឋធម្មនុញ្ញមួយឬច្រើន ដែលនឹងដោះស្រាយបញ្ហានិងគោលនយោបាយដែលបានពណ៌នានៅទីនេះ ហើយថាត្រូវមានការប្រុងប្រយ័ត្នចំពោះសហគមន៍ឯករាជ្យនៅរដ្ឋម៉ាសាឈូសេត Massachusetts ដើម្បីផ្តល់សច្ចាប័នដែលស្ថិតនៅក្រោមមាត្រា V នៃរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក;

   iv) ការវិភាគលើវិសោធនកម្មរដ្ឋធម្មនុញ្ញដែលបានដាក់ជូននៅក្នុងកិច្ចប្រជុំរដ្ឋសភាពរហូតដល់មានកាលបរិច្ឆេទឆ្លើយតបទៅនឹងការសម្រេចរបស់តុលាការកំពូលក្នុងផ្នែក *Citizens United v. FEC* ដែលជាការវាយតម្លៃភាពសមស្របរបស់ពួកគេចំពោះគោលនយោបាយនិងគោលបំណងដែលមានចែងនៅក្នុងច្បាប់នេះ; និង

   v) អនុសាសន៍ចំពោះវិធានការនានាដែលត្រូវធ្វើឡើងតាមរយៈរដ្ឋសភា តុលាការធម្មតានៅរដ្ឋម៉ាសាឈូសេត Massachusetts អភិបាលរដ្ឋ លេខាធិការសហគមន៍ឯករាជ្យ អគ្គព្រះរាជអាជ្ញា និងមន្ត្រីសាធារណៈ និងអង្គភាពផ្សេងទៀត និងប្រជាពលរដ្ឋនៃសហគមន៍ឯករាជ្យនៅរដ្ឋម៉ាសាឈូសេត Massachusetts ដើម្បីលើកកម្ពស់ ការស្នើសុំ និងការផ្តល់សច្ចាប័នបន្ថែមទៀតចំពោះវិសោធនកម្មរដ្ឋធម្មនុញ្ញ ឬវិសោធនកម្មជាច្រើនទៀត ដែលបានផ្តល់អនុសាសន៍ ។

b) គណៈកម្មការ Citizens Commission ត្រូវផ្តល់ជូនរបាយការណ៍និងអនុសាសន៍លើកដំបូងរបស់ខ្លួនជូនប្រធានព្រឹទ្ធសភា អ្នកនាំពាក្យនៃអ្នកតំណាងមន្ទីររដ្ឋសភា អភិបាលរដ្ឋ លេខាធិការសហគមន៍ឯករាជ្យ អគ្គព្រះរាជអាជ្ញា និងប្រជាពលរដ្ឋនៅរដ្ឋម៉ាសាឈូសេត Massachusetts នៅថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019 ឬមុនកាលបរិច្ឆេទនេះ ។

c) ការទទួលបាននៅក្នុងរយៈពេល 5 ថ្ងៃនោះ លេខាធិការសហគមន៍ឯករាជ្យ ត្រូវបានគេណែនាំឱ្យប្រគល់ជូនរបាយការណ៍និងអនុសាសន៍របស់គណៈកម្មការ Citizens Commission ជូនទៅសមាជិកបច្ចុប្បន្នទាំងអស់នៃតុលាការធម្មតានៅរដ្ឋម៉ាសាឈូសេត Massachusetts សមាជិកសភាអាមេរិកបច្ចុប្បន្នទាំងអស់ និងប្រធានាធិបតីសហរដ្ឋអាមេរិក ។

d) លេខាធិការសហគមន៍ឯករាជ្យ ត្រូវបានគេណែនាំឱ្យផ្តល់ជូនឯកសារថតចម្លងភ្លាមៗនៃច្បាប់នេះនៅពេលបានអនុម័តចំពោះបុគ្គលដូចខាងក្រោម ៖ អភិបាលរដ្ឋ អគ្គព្រះរាជអាជ្ញា សមាជិកបច្ចុប្បន្នទាំងអស់នៃតុលាការធម្មតានៅរដ្ឋម៉ាសាឈូសេត Massachusetts សមាជិកសភាអាមេរិកបច្ចុប្បន្នទាំងអស់ និងប្រធានាធិបតីសហរដ្ឋអាមេរិក ។

e) ដោយមានច្បាប់នេះ ប្រជាពលរដ្ឋជម្រុញរដ្ឋសភា តុលាការធម្មតានៅរដ្ឋម៉ាសាឈូសេត Massachusetts អភិបាលរដ្ឋ លេខាធិការសហគមន៍ឯករាជ្យ អគ្គព្រះរាជអាជ្ញា និងមន្ត្រីសាធារណៈ និងអង្គភាពផ្សេងទៀត និងប្រជាពលរដ្ឋនៃសហគមន៍ឯករាជ្យនៅរដ្ឋម៉ាសាឈូសេត Massachusetts ពិនិត្យមើលឡើងវិញដោយប្រុងប្រយ័ត្នចំពោះលទ្ធផលរបស់គណៈកម្មការ Citizens Commission និងចាត់វិធានការតាមរដ្ឋធម្មនុញ្ញនិងវិធានការច្បាប់ទាំងអស់ ដើម្បីបន្តសំណើរនេះ និងការផ្តល់សច្ចាប័នបន្ថែមទៀតចំពោះវិសោធនកម្មរដ្ឋធម្មនុញ្ញ ឬវិសោធនកម្មជាច្រើនទៀត ដែលបានផ្តល់អនុសាសន៍ ។

ផ្នែក 5 ៖ ភាពដោយឡែក ។

បទប្បញ្ញត្តិជាច្រើននៃច្បាប់នេះ គឺឯករាជ្យនិងអាចមានដោយឡែក ហើយការគ្មានសុពលភាព ប្រសិនបើមានផ្នែកណាមួយឬលក្ខណៈពិសេសនោះ មិនត្រូវមានផលប៉ះពាល់ ឬធ្វើឱ្យនៅសេសសល់នៃច្បាប់ដែលមិនត្រឹមត្រូវ ឬដែលមិនអនុវត្តឡើយ ។

ផ្នែក 6 ៖ កាលបរិច្ឆេទមានប្រសិទ្ធភាព

ច្បាប់នេះ ត្រូវចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2019។

# 3

**សំណួរ 3 ៖ ការធ្វើប្រជាមតិអំពីច្បាប់ដែលមានស្រាប់**

# *ការរើសអើងប្រឆាំងនឹងការប្តូរភេទ*

*តើលោកអ្នកយល់ព្រមចំពោះច្បាប់ដែលបានសង្ខេបខាងក្រោម ដែលបានអនុម័តដោយអ្នកតំណាងមន្ទីរដ្ឋសភា និងព្រឹទ្ធសភានៅថ្ងៃទី 7 ខែកក្កដា 2016 ឬទេ?*

**សេចក្តីសង្ខេប**
តាមការកំណត់ដោយច្បាប់ សេចក្តីសង្ខេបត្រូវបានសរសេរដោយអគ្គព្រះរាជអាជ្ញារដ្ឋ ។

▶ ច្បាប់នេះបន្ថែមអត្តសញ្ញាណយេនឌ័រទៅក្នុងបញ្ជីមូលហេតុដែលហាមឃាត់ចំពោះការរើសអើងនៅទីកន្លែងនានានៃទីកន្លែងស្នាក់អាស្រ័យឯកជននិងរដ្ឋដែលសាធារណជនប្រើប្រាស់ រមនីយដ្ឋាន ឬកន្លែងលេងកម្សាន្ត ។ មូលហេតុបែបនេះ ក៏រួមបញ្ចូលជាតិសាសន៍ ពណ៌សម្បុរ លទ្ធិសាសនា ប្រភពដើមជនជាតិ ភេទ ពិការភាព និងពូជពង្ស ។ “ទីកន្លែងនៃទីស្នាក់អាស្រ័យឯកជននិងរដ្ឋដែលសាធារណជនប្រើប្រាស់ រមនីយដ្ឋាន ឬកន្លែងលេងកម្សាន្ត” ត្រូវបានកំណត់នៅក្នុងច្បាប់ដែលមានស្រាប់ថាជាកន្លែងណាមួយ ដែលបើកចំហ និងទទួលយក ឬស្នើសុំការជួយគាំទ្រដល់សាធារណជនទូទៅ ដូចជាសណ្ឋាគារ ហាងលក់ទំនិញ ភោជនីយដ្ឋាន រោងភាពយន្តឬរោងល្ខោន អគារកីឡា និងមន្ទីរពេទ្យ ។ “អត្តសញ្ញាណយេនឌ័រ” ត្រូវបានកំណត់ថាជាបុគ្គលដែលមានដោយស្មោះត្រង់ចំពោះអត្តសញ្ញាណ រូបរាង ឬចរិយាដែលទាក់ទងនឹងយេនឌ័រ ទោះបីជាមានលក្ខណៈខុសគ្នាដែលទាក់ទងនឹងប្រពៃណីជាមួយសរីរៈសាស្ត្ររបស់បុគ្គល ឬភេទដែលបានកំណត់នៅពេលសម្រាលកូនក៏ដោយ ។

ច្បាប់នេះ ហាមប្រាមចំពោះការរើសអើងដោយផ្អែកលើអត្តសញ្ញាណយេនឌ័រនៅក្នុងការអនុញ្ញាតរបស់បុគ្គល ឬការចាត់ទុកនៅកន្លែងណាមួយនៃនៃទីស្នាក់អាស្រ័យឯកជននិងរដ្ឋដែលសាធារណជនប្រើប្រាស់ ។

ច្បាប់នេះតម្រូវឱ្យមានកន្លែងណាមួយបែបនេះ ដែលមានកន្លែងដាច់ដោយឡែកសម្រាប់បុរសនិងស្រី (ដូចជាបន្ទប់ទឹក) ដើម្បីអនុញ្ញាតឱ្យមានការចូលប្រើប្រាស់ និងការប្រើប្រាស់ទីកន្លែងពេញលេញទាំងនោះ ស្របតាមអត្តសញ្ញាណយេនឌ័ររបស់បុគ្គលម្នាក់ ។ ច្បាប់នេះក៏ហាមឃាត់ម្ចាស់កម្មសិទ្ធិ ឬប្រធានគ្រប់គ្រងទីកន្លែងនៃទីស្នាក់អាស្រ័យឯកជននិងរដ្ឋដែលសាធារណជនប្រើប្រាស់ពីការប្រើប្រាស់ការផ្សាយពាណិជ្ជកម្ម ឬការបង្ហាញស្លាកសញ្ញាដែលរើសអើងដោយផ្អែកលើអត្តសញ្ញាណយេនឌ័រ ។

ច្បាប់នេះណែនាំអំពីគណៈកម្មការរដ្ឋប្រឆាំងនឹងការរើសអើង ដើម្បីអនុម័តច្បាប់ ឬគោលនយោបាយ និងការផ្តល់អនុសាសន៍ ដើម្បីអនុវត្តច្បាប់នេះ ។ ច្បាប់ននេះក៏ណែនាំដល់អគ្គព្រះរាជអាជ្ញារដ្ឋ ដើម្បីចេញបទបញ្ជាឬការណែនាំដែលទាក់ទងនឹងការចាត់វិធានការផ្លូវច្បាប់ចំពោះបុគ្គលណាម្នាក់ដែលអះអាងអត្តសញ្ញាណយេនឌ័រក្នុងគោលបំណងមិនត្រឹមត្រូវ ។

បទប្បញ្ញត្តិនៃច្បាប់នេះ ដែលគ្រប់គ្រងសិទ្ធិចូលទៅទីកន្លែងនានានៃទីស្នាក់អាស្រ័យឯកជននិងរដ្ឋដែលសាធារណជនប្រើប្រាស់ មានប្រសិទ្ធភាពចាប់ពីថ្ងៃទី 1 ខែតុលា ឆ្នាំ 2016 ។ បទប្បញ្ញត្តិដែលនៅសល់ មានប្រសិទ្ធភាពចាប់ពីថ្ងៃទី 8 ខែកក្កដា ឆ្នាំ 2016 ។

---

**សម្លេងឆ្នោតគាំទ្ររបស់អ្នកនឹងមានន័យអ្វីខ្លះ:**
តាមការកំណត់ដោយច្បាប់ របាយការណ៍នានាដែលរៀបរាប់អំពីផលប៉ះពាល់ដល់សម្លេងឆ្នោត “បាទ/ចាស៎” ឬ “ទេ” ត្រូវបានសរសេររួមគ្នាដោយអគ្គព្រះរាជអាជ្ញារដ្ឋ និងលេខាធិការសហគមន៍ឯករាជ្យ ។

▶ ***ការបោះឆ្នោត បាទ/ចាស៎*** នឹងរក្សាទុកនៅនឹងកន្លែងនូវច្បាប់បច្ចុប្បន្នដែលហាមប្រាមចំពោះការរើសអើងដោយផ្អែកលើអត្តសញ្ញាណយេនឌ័រនៅទីកន្លែងនានានៃទីស្នាក់អាស្រ័យឯកជននិងរដ្ឋដែលសាធារណជនប្រើប្រាស់ ។

***ការបោះឆ្នោត ទេ*** នឹងលុបចោលបទប្បញ្ញត្តិនៃច្បាប់ស្តីពីទីស្នាក់អាស្រ័យឯកជននិងរដ្ឋដែលសាធារណជនប្រើប្រាស់ ។

---

**របាយការណ៍អំពីផលវិបាកនៃសារពើពន្ធ**
តាមការកំណត់ដោយច្បាប់នោះ របាយការណ៍អំពីផលវិបាកនៃសារពើពន្ធ ត្រូវបានសរសេរដោយការិយាល័យប្រតិបត្តិផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ។

▶ ការលុបចោលដែលបានស្នើឡើងចំពោះច្បាប់ដែលមានស្រាប់ មិនមានផលវិបាកខាងសារពើពន្ធដែលមានខ្លឹមសារ ដែលអាចយល់ដឹងអំពីហិរញ្ញវត្ថុរដ្ឋាភិបាល ក្រុង និងរដ្ឋឡើយ ។

**ការពិភាក្សារកហេតុផល** តាមការកំណត់ដោយច្បាប់ ការពិភាក្សារកហេតុផលដែលមាន 150 ពាក្យ ត្រូវបានសរសេរដោយអ្នកគាំទ្រ និងអ្នកប្រឆាំងចំពោះសំណួរនីមួយៗ និងបង្ហាញអំពីមតិយោបល់របស់ពួកគេ ។ សហគមន៍ឯករាជ្យនៃរដ្ឋម៉ាសាឈូសេត Massachusetts មិនយល់ព្រមចំពោះការពិភាក្សារកហេតុផលទាំងនេះទេ ហើយមិនបញ្ជាក់ភាពត្រឹមត្រូវនៃរបាយការណ៍ណាមួយដែលបានធ្វើឡើងនៅក្នុងការពិភាក្សារកហេតុផលទាំងនេះឡើយ ។ ឈ្មោះរបស់បុគ្គលនិងអង្គភាពនានាដែលបានសរសេរការពិភាក្សារកហេតុផលនីមួយៗ និងមតិយោបល់ណាមួយដែលសរសេរជាលាយលក្ខណ៍អក្សរដោយអ្នកដទៃទៀតអំពីការពិភាក្សារកហេតុផលនីមួយៗនោះ មាននៅក្នុងឯកសារនៅការិយាល័យលេខាធិការសហគមន៍ឯករាជ្យ ។

▶ ***តាមចំណូលចិត្ត ៖*** បោះឆ្នោត បាទ/ចាស់ ដើម្បីរក្សានៅនឹងកន្លែងនូវច្បាប់បច្ចុប្បន្នថា ៖

- រក្សាស្វាគមន៍និងយុត្តិធម៌រដ្ឋ Massachusetts ។
- ការពារពីការរើសអើងនៅទីកន្លែងនានា ដូចជាហាងលក់ទំនិញ ភោជនីយដ្ឋាន និងមន្ទីរពេទ្យ ។
- ការពារយុវជន និងមនុស្សពេញវ័យប្តូរភេទ ។
- អនុញ្ញាតឱ្យពលរដ្ឋប្តូរភេទ មានជីវិតនៅប្រចាំថ្ងៃរបស់ពួកគេ ដែលរួមមានបន្ទប់ទឹកដែលយើងទាំងអស់គ្នាត្រូវការប្រើប្រាស់ ។

យើងខ្ញុំទាំងអស់គ្នាលើកកម្ពស់សុវត្ថិភាពនិងសិទ្ធិឯកជនភាព ដែលរួមទាំងពលរដ្ឋប្តូរភេទ ។ ច្បាប់នេះ ត្រូវបានអនុវត្តអស់រយៈពេលពីរឆ្នាំហើយ ដោយមិនមានការកើនឡើងឧប្បត្តិហេតុសុវត្ថិភាពសាធារណៈឡើយ ។ ការបៀតបៀនកេរ្តិ៍ខ្មាសបុគ្គលនៅតែខុសច្បាប់ ហើយអ្នកទាំងនោះដែលប្រព្រឹត្តបទឧក្រិដ្ឋនៅតែត្រូវកាត់ទោស ។

នោះហើយជាមូលហេតុដែលអ្នកជំនាញនានាគាំទ្រច្បាប់ រួមមាន ៖

- ការអនុវត្តច្បាប់ ដែលរួមមានប្រធានប៉ូលីសសមាគមប៉ូលីសរដ្ឋម៉ាសាឈូសេត Massachusetts និងប្រធានប៉ូលីសទីក្រុងធំៗនៃរដ្ឋម៉ាសាឈូសេត Massachusetts ។
- អង្គការស្ត្រី និងសម្ព័ន្ធរដ្ឋម៉ាសាឈូសេត Massachusetts ប្រឆាំងនឹងការរំលោភបំពានផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ ។
- សមាគមមាតាបិតា - គ្រូបង្រៀនរដ្ឋ Massachusetts ។

ពលរដ្ឋប្តូរភេទគឺជាអ្នកជិតខាង អ្នករួមការងារ និងមិត្តភក្តិ ដែលរួមចំណែកដល់សហគមន៍ដែលរីកចម្រើនរបស់យើង ។ ការបោះឆ្នោត បាទ/ចាស់ ជួយគាំទ្រលើកកម្ពស់តម្លៃភាពត្រឹមត្រូវយុត្តិធម៌ សេចក្តីថ្លៃថ្នូរ និងការគោរពអ្នកទាំងអស់គ្នាជាមូលដ្ឋាន ។

**Susan Donnelly**
**សេរីភាពសម្រាប់រដ្ឋម៉ាសាឈូសេតទាំងអស់ (Freedom for All Massachusetts)**
**www.freedommassachusetts.org**

***ការជំទាស់ ៖*** ការបោះឆ្នោត ទេ មិនលុបចោលឬទុកជានិរាករណ៍ច្បាប់ស្តីពី "បង្គន់និងបន្ទប់ទឹកសារធារណៈ" និងការពារបុរសមិនឱ្យចូលបន្ទប់ទឹកស្ត្រី បន្ទប់មានទូចាក់សោ បន្ទប់ដូរខោអាវ និងកន្លែងឯកជនឬផ្ទាល់ខ្លួន ។ ច្បាប់នេះបំពានលើសិទ្ធិឯកជនភាព និងសុវត្ថិភាពរបស់ស្ត្រី ដោយអនុញ្ញាតឱ្យបុរសណាម្នាក់កំណត់អត្តសញ្ញាណជាស្ត្រីម្នាក់ ដែលរួមមានពិរុទ្ធជនផ្លូវភេទដែលផ្តន្ទាទោស ដើម្បីប្រើប្រាស់រួមគ្នានៃទីកន្លែងរបស់ស្ត្រី ។ នៅក្រោមច្បាប់នេះ ការប៉ុនប៉ងរារាំងណាមួយចំពោះបុរសម្នាក់ពីការចូលបន្ទប់មានទូចាក់សោ បន្ទប់ដូរខោអាវ ឬបន្ទប់ទឹកស្ត្រី អាចបណ្តាលឱ្យមានការផាកពិន័យបុគ្គល ដែលមានទឹកប្រាក់រហូតដល់ $50,000 ដុល្លារ និងជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ ។ អាជីវកម្មនានាក៏រងផលប៉ះពាល់ផងដែរ ដូចជាម្ចាស់ស្ប៉ាជាស្ត្រីម្នាក់ ដែលប្រឈមនឹងការតវ៉ាអំពីការរើសអើងចំពោះការបដិសេធចំពោះការដករោមចេញពីប្រដាប់ភេទបុរសម្នាក់ដែលកំណត់អត្តសញ្ញាណថាជាស្ត្រីម្នាក់ ។ គ្មានច្បាប់ណាត្រូវកំណត់ស្ត្រី និងក្មេងស្រីមានអារម្មណ៍ថា មិនមានសុវត្ថិភាពនិងកេងប្រវ័ញ្ចលើសិទ្ធិឯកជននិងការធានាសុវត្ថិភាពរបស់ពួកគេឡើយ ។ អង្គនីតិបញ្ញត្តិនៅរដ្ឋ MA បានអនុម័តច្បាប់មួយដែលហួសពីការពិត បើទោះជាមានការបដិសេធមិនរាប់បញ្ចូលបទប្បញ្ញត្តិ ដើម្បីដកចេញជនល្មើសផ្លូវភេទក៏ដោយ ។ ការបោះឆ្នោត ទេ ការពារសិទ្ធិឯកជនភាព និងសុវត្ថិភាពរបស់ស្ត្រី ។

**Debby Dugan**
**រក្សា MA សុវត្ថិភាព (Keep MA Safe)**
**400 TradeCenter, Suite 1950**
**Woburn, MA 01801**
**339-298-7567**
**www.keepmasafe.org**

## អត្ថបទសំណួរពេញលេញ

ចំណែកឯការប្រតិបត្តិការដែលពន្យាពេលច្បាប់នេះ នឹងមានទំនោរទៅរកជ័យជំនះលើគោលបំណងរបស់ខ្លួន ដែលផ្តល់ជូនការការពារជាបន្ទាន់ពីការរើសអើងដោយផ្អែកលើអត្តសញ្ញាណយេនឌ័រ ដូច្នេះហើយតាមន័យនេះត្រូវបានគេប្រកាសថាជាច្បាប់គ្រាអាសន្នដែលចាំបាច់សម្រាប់ការការពារសាធារណជនជាបន្ទាន់ ។

*ត្រូវបានអនុម័តដោយព្រឹទ្ធសភា និងអ្នកតំណាងមន្ទីរដ្ឋសភានៅតុលាការធម្មតាដែលប្រមូលផ្តុំគ្នា និងតាមរយៈការផ្តល់សិទ្ធិដូចគ្នា ដូចខាងក្រោម ៖*

ផ្នែក 1 ៖ ផ្នែក 92A នៃជំពូកទី 272 នៃច្បាប់ទូទៅដែលមានបង្ហាញនៅក្នុងការកែសម្រួលជាផ្លូវការឆ្នាំ 2014 តាមន័យនេះត្រូវបានកែតម្រូវដោយការដាក់បញ្ចូលក្រោយពាក្យ "ភេទ" នៅក្នុងបន្ទាត់ទី 9 ដែលមានពាក្យនានាដូចតទៅ ៖ - អត្តសញ្ញាណយេនឌ័រ ។

ផ្នែក 2 ៖ កថាខ័ណ្ឌទីពីរនៃផ្នែក 92A នៃជំពូក 272 ដែលមានចែងដូចដែលមានបង្ហាញបែបនេះ តាមន័យនេះត្រូវបានកែតម្រូវថែមទៀតដោយបន្ថែមប្រយោគ ដូចខាងក្រោម ៖- ម្ចាស់កម្មសិទ្ធិ អ្នកជួល ម្ចាស់អាជីវកម្ម នាយក ភ្នាក់ងារ ឬនិយោជិតពីទីកន្លែងណាមួយនៃទីស្នាក់អាស្រ័យឯកជននិងរដ្ឋដែលសាធារណជនប្រើប្រាស់ រមនីយដ្ឋាន ឬកន្លែងលេងកម្សាន្ត ដែលបំបែកចេញដោយឡែក ឬដាច់ដោយឡែកពីសិទ្ធិចូលទៅទីកន្លែងនៃទីស្នាក់អាស្រ័យឯកជននិងរដ្ឋដែលសាធារណជនប្រើប្រាស់បែបនេះ ឬផ្នែកមួយនៃទីកន្លែងនៃទីស្នាក់អាស្រ័យឯកជននិងរដ្ឋដែលសាធារណជនប្រើប្រាស់បែបនេះ ដោយលើមូលដ្ឋានភេទរបស់បុគ្គល ត្រូវផ្តល់ជូនការអនុញ្ញាតដល់មនុស្សគ្រប់រូបចូល និងការពេញចិត្តពេញលេញចំពោះទីកន្លែងនៃទីស្នាក់អាស្រ័យឯកជននិងរដ្ឋដែលសាធារណជនប្រើប្រាស់បែបនេះ ឬឬចំណែកមួយដែលស្របតាមអត្តសញ្ញាណយេនឌ័ររបស់បុគ្គលនេះ ។

ផ្នែក 3 ៖ ដូចដែលបង្ហាញនៅផ្នែក 98 នៃជំពូក 272 ដែលមានចែង តាមន័យនេះត្រូវបានកែតម្រូវដោយការដាក់បញ្ចូលក្រោយពាក្យ "ភេទ" នៅក្នុងបន្ទាត់ទី 3 ដែលមានពាក្យនានាដូចតទៅ ៖ - អត្តសញ្ញាណយេនឌ័រ ។

## អត្ថបទសំណួរពេញលេញ (បន្ត)

ផ្នែក 4 ៖ (a) គណៈកម្មការប្រឆាំងនឹងការរើសអើងនៅរដ្ឋម៉ាសាឈូសេត Massachusetts ត្រូវអនុម័ត ប្រកាសឱ្យប្រើ កែតម្រូវ និងលុបចោលច្បាប់និងបទបញ្ជានានា ឬបង្កើតគោលនយោបាយ និងផ្ដល់អនុសាសន៍ដើម្បីបំពេញគោលបំណងនានានៃច្បាប់នេះ ដែលរួមទាំងនៅពេលណា និងរបៀបកំណត់អត្តសញ្ញាណយេនឌ័រ ដូចមានចែងក្នុងប្រការហាសិបប្រាំបួននៃផ្នែក 7 នៃជំពូក 4 នៃច្បាប់ទូទៅ អាចបង្ហាញឱ្យឃើញជាក់ស្ដែង ។

(b) ការិយាល័យអគ្គព្រះរាជអាជ្ញា ត្រូវចេញបទបញ្ជាឬគោលការណ៍ការណែនាំសម្រាប់ទីភ្នាក់ងារអនុវត្តច្បាប់ដែលសមស្រប ឬអាជ្ញាធរសមស្របផ្សេងទៀត ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ចំពោះជនណាម្នាក់ ដែលការអះអាងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ មានគោលបំណងមិនត្រឹមត្រូវដូចមានចែងក្នុងកថាខ័ណ្ឌទីហាសិបប្រាំបួន នៃផ្នែក 7 នៃជំពូក 4 ។

(c) គណៈកម្មការប្រឆាំងនឹងការរើសអើងនៅរដ្ឋម៉ាសាឈូសេត Massachusetts និងការិយាល័យអគ្គព្រះរាជអាជ្ញា ត្រូវរាយការណ៍អំពីបទបញ្ជា បទប្បញ្ញត្តិ គោលនយោបាយ អនុសាសន៍ ឬគោលការណ៍ណែនាំចំពោះស្មៀននានានៃអ្នកតំណាងមន្ទីរដ្ឋសភា និងព្រឹទ្ធសភា មិនត្រូវយឺតជាងថ្ងៃទី 1 ខែកញ្ញា ឆ្នាំ 2016 ។

ផ្នែក 5 ៖ ផ្នែក 2 និង 3 ត្រូវចូលជាធរមាននៅថ្ងៃទី 1 ខែតុលា ឆ្នាំ 2016

# *របៀបចុះឈ្មោះបោះឆ្នោត...*

**លោកអ្នកអាចដាក់ជូនសំណុំបែបបទចុះឈ្មោះអ្នកបោះឆ្នោត ប្រសិនបើលោកអ្នក ៖**

- **ពលរដ្ឋអាមេរិក និង**
- **អ្នករស់នៅរដ្ឋម៉ាសាឈូសេត Massachusetts និង**
- **មានអាយុយ៉ាងតិច 16 ឆ្នាំ និង**
- **មិនជាប់ឃុំឃាំងពីការផ្តន្ទាទោសឧក្រិដ្ឋនាពេលបច្ចុប្បន្ន ។**

## ការចុះឈ្មោះមុន ដើម្បីបោះឆ្នោត

លោកអ្នកត្រូវមានអាយុ 18 ឆ្នាំ ដើម្បីបោះឆ្នោត លោកអ្នកអាចចុះឈ្មោះមុនដើម្បីបោះឆ្នោតប្រសិនបើលោកអ្នកមានអាយុយ៉ាងតិច 16 ឆ្នាំ ។ ប្រសិនបើលោកអ្នកចង់ចុះឈ្មោះមុន អ្នកអាចដាក់ជូនសំណុំបែបបទចុះឈ្មោះអ្នកបោះឆ្នោតទៅមន្ត្រីបោះឆ្នោតនៅមូលដ្ឋានរបស់អ្នក ។ មន្ត្រីបោះឆ្នោតនៅមូលដ្ឋានរបស់អ្នក នឹងបន្ថែមលោកអ្នកទៅក្នុងបញ្ជីឈ្មោះអ្នកចុះឈ្មោះមុន ដែលនឹងក្លាយជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះ មុននឹងមានអាយុ 18 ឆ្នាំ ។ លោកអ្នកនឹងទទួលបានដំណឹងតាមប៉ុស្តប្រៃសណីយ៍ នៅពេលលោកអ្នកមានសិទ្ធិបោះឆ្នោត ។

សូមចំណាំថាលោកអ្នកនឹងអាចមានសិទ្ធិបោះឆ្នោតនៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2018 តែប៉ុណ្ណោះ ប្រសិនបើលោកអ្នកនឹងមានអាយុ 18 ឆ្នាំនៅកាលបរិច្ឆេទ ឬមុននោះ ។ ប្រសិនបើលោកអ្នកនឹងមានអាយុ 18 ឆ្នាំ នៅត្រឹមថ្ងៃបោះឆ្នោតនោះ សម្រាប់ថ្ងៃផុតកំណត់បោះឆ្នោត លោកអ្នកត្រូវតែចុះឈ្មោះនៅត្រឹមថ្ងៃទី 17 ខែតុលា ឆ្នាំ 2018 ទោះបីជាថ្ងៃខួបកំណើតរបស់អ្នក មានបន្ទាប់ពីថ្ងៃផុតកំណត់នេះក៏ដោយ ។

## ចុះឈ្មោះនៅពេលណា

មិនមានរយៈពេលរង់ចាំ ដើម្បីមានសិទ្ធិចុះឈ្មោះបោះឆ្នោតឡើយ ។ នៅពេលឆាប់ៗដែលលោកអ្នកគិតអំពីអាសយដ្ឋានរបស់អ្នក "ផ្ទះ" របស់អ្នកនោះ លោកអ្នកអាចចុះឈ្មោះបោះឆ្នោតពីអាសយដ្ឋាននោះ ។ សូមចងចាំថានៅរាល់ពេលដែលលោកអ្នកផ្លាស់ទីលំនៅ លោកអ្នកត្រូវតែចុះឈ្មោះម្តងទៀត ។ ប្រសិនបើលោកអ្នកផ្លាស់ទីលំនៅ លោកអ្នកអាចចុះឈ្មោះបោះឆ្នោតនៅពេលឆាប់ៗដែលលោកអ្នកផ្លាស់ទីលំនៅទៅផ្ទះថ្មីរបស់អ្នក ។

ថ្ងៃផុតកំណត់ចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតរដ្ឋនៅថ្ងៃទី 6 ខែវិច្ឆិកា គឺថ្ងៃទី 17 ខែតុលា ។ សំណុំបែបបទចុះឈ្មោះអ្នកបោះឆ្នោតតាមប៉ុស្តប្រៃសណីយ៍របស់អ្នក ត្រូវមានវាយត្រាលើសំបុត្រដោយមានកាលបរិច្ឆេទនិងម៉ោងនៅត្រឹមថ្ងៃទី 17 ខែតុលា ឆ្នាំ 2018 ដើម្បីឱ្យលោកអ្នកមានសិទ្ធិបោះឆ្នោតក្នុងការបោះឆ្នោតរដ្ឋនៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2018 ។

## របៀបចុះឈ្មោះ

**តាមអនឡាញ** ៖ ប្រសិនបើលោកអ្នកមានប័ណ្ណបើកបរយានយន្តនៅរដ្ឋម៉ាសាឈូសេត Massachusetts ឬអត្តសញ្ញាណប័ណ្ណផ្សេងទៀតដែលចេញដោយការិយាល័យចុះបញ្ជីយានយន្តនោះ លោកអ្នកអាចដាក់ពាក្យសុំតាមអនឡាញតាមវែបសាយ **www.RegisterToVoteMA.com** ។ សំណុំបែបបទចុះឈ្មោះអ្នកបោះឆ្នោតតាមអនឡាញ ត្រូវតែដាក់ជូននៅមុនពាក់កណ្តាលអាធ្រាតនៅថ្ងៃទី 17 ខែតុលា  ដើម្បីឱ្យលោកអ្នកមានសិទ្ធិបោះឆ្នោតនៅថ្ងៃទី 6 ខែវិច្ឆិកា ។

**ជួបដោយផ្ទាល់** ៖ សូមចូលទៅទីតាំងចុះឈ្មោះណាមួយ ដូចជាសាលាក្រុង ឬសាលាខេត្តរបស់អ្នក ហើយបំពេញលិខិតបញ្ជាក់ការចុះឈ្មោះ ។ ការិយាល័យបោះឆ្នោតនៅមូលដ្ឋាន ត្រូវបើកដំណើរការចុះឈ្មោះអ្នកបោះឆ្នោតរហូតដល់ម៉ោង 8 យប់ នៅថ្ងៃទី 17 ខែតុលា ឆ្នាំ 2018 ។

**តាមប៉ុស្តប្រៃសណីយ៍** ៖ សំណុំបែបបទចុះឈ្មោះតាមប៉ុស្តប្រៃសណីយ៍ អាចប្រព្រឹត្តទៅបានយ៉ាងទូលំទូលាយ ។ សំណុំបែបបទចុះឈ្មោះតាមប៉ុស្តប្រៃសណីយ៍ ត្រូវបានភ្ជាប់ជូនជាមួយកូនសៀវភៅនេះ ។ ដើម្បីទទួលបានសំណុំបែបបទចុះឈ្មោះតាមប៉ុស្តប្រៃសណីយ៍បន្ថែមទៀត សូមចូលមើលគេហទំព័ររបស់យើង **www.sec.state.ma.us/ele** ដើម្បីទាញយកសំណុំបែបបទ ឬហៅទូរស័ព្ទលេខ 1-800-462-VOTE (8683) ។ ផ្ញើតាមប៉ុស្តប្រៃសណីយ៍នូវសំណុំបែបបទដែលបានបំពេញហើយ ជូនទៅសាលក្រុង ឬសាលាខេត្តរបស់អ្នក ។

**នៅការិយាល័យចុះបញ្ជីរថយន្ត** ៖ លោកអ្នកអាចបំពេញពាក្យសុំចុះឈ្មោះអ្នកបោះឆ្នោតនៅពេលលោកអ្នកដាក់ពាក្យសុំ ឬបន្តប័ណ្ណបើកបរយានយន្ត ។ ពិនិត្យមើលបង្កាន់ដៃអ្នកបោះឆ្នោតរបស់អ្នក មុនលោកអ្នកចាកចេញ - វានឹងបញ្ជាក់ថាលោកអ្នកបានចុះឈ្មោះបោះឆ្នោតហើយឬនៅ ។ សូមរក្សាទុកបង្កាន់ដៃអ្នកបោះឆ្នោតរបស់អ្នករហូតដល់អ្នកទទួលបានការបញ្ជាក់ពីមន្ត្រីរៀបចំការបោះឆ្នោតនៅមូលដ្ឋានរបស់អ្នក ។

## ការផ្លាស់ប្តូរអាសយដ្ឋានរបស់អ្នក

ប្រសិនបើលោកអ្នកបានផ្លាស់ប្តូរលំនៅដ្ឋាន លោកអ្នកត្រូវតែចុះឈ្មោះម្តងទៀត ។ លោកអ្នកអាចចុះឈ្មោះបោះឆ្នោតនៅពេលឆាប់ៗដែលលោអ្នកផ្លាស់ទីលំនៅទៅផ្ទះថ្មីរបស់អ្នក ។ លោកអ្នកអាចធ្វើបច្ចុប្បន្នភាពការចុះឈ្មោះរបស់អ្នកដោយដាក់ជូនសំណុំបែបបទថ្មីមួយតាមអនឡាញ តាមប៉ុស្តប្រៃសណីយ៍ ឬជួបដោយផ្ទាល់នៅទីកន្លែងចុះឈ្មោះអ្នកបោះឆ្នោតណាមួយ ។ ការផ្លាស់ប្តូរណាមួយ ត្រូវធ្វើឡើងនៅត្រឹមថ្ងៃផុតកំណត់ចុះឈ្មោះបោះឆ្នោតនៅថ្ងៃទី 17 ខែតុលា ។

## ការបញ្ជាក់អំពីការចុះឈ្មោះអ្នកបោះឆ្នោត

មិនថាអ្នកចុះឈ្មោះតាមរបៀបណាឡើយ លោកអ្នកត្រូវទទួលបានការបញ្ជាក់ពីការចុះឈ្មោះរបស់អ្នកពីមន្ត្រីរៀបចំការបោះឆ្នោតនៅមូលដ្ឋានរបស់អ្នកក្នុងរយៈពេល 2-3 សប្តាហ៍ ។ ប្រសិនបើលោកអ្នកមិនបានទទួលលិខិតជូនដំណឹងរបស់អ្នកតាមប៉ុស្តប្រៃសណីយ៍ទេ សូមទាក់ទងការិយាល័យបោះឆ្នោតនៅមូលដ្ឋានរបស់អ្នក ដើម្បីផ្ទៀងផ្ទាត់ស្ថានភាពបោះឆ្នោតរបស់អ្នក ។ លោកអ្នកក៏អាចបញ្ជាក់អំពីស្ថានភាពចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នកតាមវែបសាយរបស់យើងផងដែរ **www.sec.state.ma.us/ele** ។

## *ការក្រើនរំលឹក!* សូមយកអត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួនទៅកន្លែងបោះឆ្នោត!

លោកអ្នកអាចត្រូវបានគេទាមទារឱ្យបង្ហាញអត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួន ដើម្បីបោះឆ្នោត ។ ប្រសិនបើលោកអ្នកបានចុះឈ្មោះបោះឆ្នោតតាមប៉ុស្តប្រៃសណីយ៍ លោកអ្នកអាចត្រូវបានគេកំណត់ក្រោមសហព័ន្ធ ដើម្បីបង្ហាញអត្តសញ្ញាណប័ណ្ណលើកដំបូងដែលលោកអ្នកបោះឆ្នោតនៅក្នុងការបោះឆ្នោតសហព័ន្ធ ដូចជាការបោះឆ្នោតរដ្ឋឆ្នាំ 2018 ។ នៅក្រោមច្បាប់រដ្ឋ Massachusetts អ្នកបោះឆ្នោតណាម្នាក់ អាចត្រូវបានគេស្នើសុំឱ្យបង្ហាញអត្តសញ្ញាណប័ណ្ណ ប្រសិនបើមានសំណួរមួយអំពីអត្តសញ្ញាណប័ណ្ណរបស់ពួកគេ ។ គេបានផ្តល់អនុសាសន៍ថា អ្នកបោះឆ្នោតទាំងអស់ ត្រូវត្រៀមរៀបចំបង្ហាញ អត្តសញ្ញាណប័ណ្ណនៅថ្ងៃបោះឆ្នោត ។

អត្តសញ្ញាណប័ណ្ណដែលអាចទទួលយកបាន ត្រូវតែមានឈ្មោះនិងអាសយដ្ឋានដែលលោកអ្នកបានចុះឈ្មោះបោះឆ្នោត ឧទាហរណ៍ ៖ ប័ណ្ណបើកបរយានយន្តថ្មីនិងមានសុពលភាព អត្តសញ្ញាណប័ណ្ណមានរូបថត វិក្កយបត្របង់សេវាប្រចាំថ្ងៃថ្មី របាយការណ៍ធនាគារ គល់បង្កាន់ដៃបង់ប្រាក់ សែករដ្ឋាភិបាល លិខិតពីអន្តេវាសិកដ្ឋានដែលក្បាលលិខិតសាលា ឬឯកសារផ្លូវការ និងថ្មីផ្សេងទៀត ដែលបង្ហាញឈ្មោះរបស់អ្នក និងអាសយដ្ឋានដែលលោកអ្នកបានចុះបញ្ជីឈ្មោះ ។

# មធ្យោបាយតាមអនឡាញ













## ចុះឈ្មោះបោះឆ្នោតតាមអនឡាន

ប្រជាពលរដ្ឋជាច្រើននៅរដ្ឋម៉ាសាឈូសេត Massachusetts អាចដាក់ជូនសំណុំបែបបទចុះឈ្មោះអ្នកបោះឆ្នោតរបស់ពួកគេតាមអនឡាញ ។ ប្រសិនបើលោកអ្នកមានប័ណ្ណបើកបរយានយន្តនៅរដ្ឋម៉ាសាឈូសេត Massachusetts ឬអត្តសញ្ញាណប័ណ្ណផ្សេងទៀតដែលចេញដោយការិយាល័យចុះបញ្ជីយានយន្តនោះ លោកអ្នកអាចដាក់ជូនសំណុំបែបបទចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នកតាមវែបសាយ **www.RegisterToVoteMA.com** ។

ប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោតតាមអនឡាញរបស់លេខាធិការសហគមន៍ឯករាជ្យអនុញ្ញាតឱ្យលោកអ្នកចុះឈ្មោះបោះឆ្នោត ផ្លាស់ប្តូរអាសយដ្ឋានរបស់អ្នក ឬធ្វើបច្ចុប្បន្នភាពគណបក្សនយោបាយរបស់អ្នក ។

នៅពេលលោកអ្នកបានដាក់ជូនសំណុំបែបបទចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នកតាមអនឡាន លោកអ្នកអ្នកនឹងទទួលបានទំព័របញ្ជាក់មួយ ដើម្បីបោះពុម្ពឬព្រីនសម្រាប់កំណត់ត្រារបស់អ្នក ។ ទំព័រនេះគឺជាលិខិតបញ្ជាក់របស់អ្នកថា លោកអ្នកបានដាក់ជូនសំណុំបែបបទរបស់អ្នកតាមកាលកំណត់នៃការចុះឈ្មោះនេះ ។ បន្ទាប់មកសំណុំបែបបទរបស់អ្នក នឹងត្រូវបញ្ជូនទៅមន្ត្រីរៀបចំការបោះឆ្នោតនៅមូលដ្ឋានរបស់អ្នកដែលត្រូវពិនិត្យឡើងវិញនិងអនុម័តលើសំណុំបែបបទរបស់អ្នក ។ នៅពេលការបោះឆ្នោតនៅមូលដ្ឋានរបស់អ្នក បានដំណើរការសំណុំបែបបទរបស់អ្នក លោកអ្នកនឹងត្រូវទទួលបានលិខិតបញ្ជាក់អំពីការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នកតាមប៉ុស្តប្រៃសណីយ៍ ។

ពាក្យសុំនានាដែលបានដាក់ជូនតាមអនឡាញ ត្រូវតែបញ្ចប់នៅម៉ោង 11:59 យប់ នៅថ្ងៃទី 17 ខែតុលា ឆ្នាំ 2018 ដើម្បីឱ្យលោកអ្នកមានសិទ្ធិបោះឆ្នោតនៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2018 ។

## ពិនិត្យមើលស្ថានភាពចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក

ប្រសិនបើលោកអ្នកចង់បញ្ជាក់ថា លោកអ្នកបានចុះឈ្មោះបោះឆ្នោតនៅអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក លោកអ្នកអាចរកព័ត៌មានអំពីការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នកតាមអនឡាញ ដោយចូលទៅវែបសាយ **www.sec.state.ma.us/ele** ហើយចុចប៊ូតុងដែលនិយាយថា "តើខ្ញុំបានចុះឈ្មោះបោះឆ្នោតហើយឬនៅ?" គេបានផ្តល់អនុសាសន៍ថា លោកអ្នកបញ្ជាក់ព័ត៌មានអំពីការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក មុនថ្ងៃផុតកំណត់នៅថ្ងៃទី 17 ខែតុលា ដើម្បីចុះឈ្មោះបោះឆ្នោត ដូច្នេះលោកអ្នកអាចធ្វើការផ្លាស់ប្តូរណាមួយដែលចាំបាច់ មុនថ្ងៃផុតកំណត់នោះ ។

សូមប្រើប្រាស់វែបសាយនេះ ដើម្បីបញ្ជាក់ការចុះឈ្មោះអ្នកបោះឆ្នោត អាសយដ្ឋាន និងគណបក្សនយោបាយរបស់អ្នក ។ ប្រសិនបើលោកអ្នកមិនអាចស្វែងរកព័ត៌មានអំពីការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក លោកអ្នកនៅតែអាចចុះឈ្មោះបោះឆ្នោតនៅអាសយដ្ឋានមុន ។

ប្រសិនបើលោកអ្នកមិនបានចុះឈ្មោះបោះឆ្នោតនៅអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក ឬលោកអ្នកមានបំណងចង់ធ្វើការផ្លាស់ប្តូរអ្វីមួយផ្សេងទៀតចំពោះព័ត៌មានចុះឈ្មោះរបស់អ្នក លោកអ្នកអាចដាក់ជូនសំណុំបែបបែចុះឈ្មោះអ្នកបោះឆ្នោតថ្មីតាមវែបសាយ **www.RegisterToVoteMA.com** ដើម្បីធ្វើការផ្លាស់ប្តូរទាំងនោះ ។

## សូមស្វែងរកកន្លែងបោះឆ្នោតរបស់អ្នក និងមើលសន្លឹកឆ្នោតរបស់អ្នក

កន្លែងបោះឆ្នោតរបស់អ្នក អាចមានការផ្លាស់ប្តូរចាប់តាំងពីលោកអ្នកបានបោះឆ្នោតចុងក្រោយ ។ លោកអ្នកអាចស្វែងរកកន្លែងបោះឆ្នោតរបស់អ្នកដោយបញ្ចូលអាសយដ្ឋានរបស់អ្នកតាមវែបសាយ **www.WhereDoIVoteMA.com** ។ បន្ថែមពីលើនេះព័ត៌មានអំពីកន្លែងបោះឆ្នោតរបស់អ្នក លោកអ្នកនឹងត្រូវបានគេផ្តល់ជូនជម្រើស ដើម្បីមើលសន្លឹកឆ្នោតរបស់អ្នកផងដែរ ។ សូមចុចមើលសន្លឹកឆ្នោតរបស់ខ្ញុំ "View My Ballot" ដើម្បីពិនិត្យមើលបេក្ខជន និងសំណួរនានាដែលបង្ហាញនៅលើសន្លឹកឆ្នោតរបស់អ្នកនៅថ្ងៃទី 6 ខែវិច្ឆិកា ។

## តាមដានសន្លឹកឆ្នោតរបស់អ្នក

ប្រសិនបើលោកអ្នកបានដាក់ពាក្យសុំសន្លឹកឆ្នោតបោះមុនដែលមិនអាចទៅស្ថានីយបោះឆ្នោត ឬសន្លឹកឆ្នោតបោះមុនតាមប៉ុស្តប្រៃសណីយ៍នោះ លោកអ្នកអាចតាមដានសន្លឹកឆ្នោតរបស់អ្នកតាមវែបសាយ **www.sec.state.ma.us/ele** ។ បញ្ចូលឈ្មោះ និងអាស័យដ្ឋានរបស់អ្នក ដើម្បីមើលកាលបរិច្ឆេទដែលសន្លឹកឆ្នោតរបស់អ្នកបានផ្ញើប៉ុស្តប្រៃសណីយ៍ជូនទៅលោកអ្នក កាលបរិច្ឆេទដែលបានទទួលដោយមន្ត្រីរៀបចំការបោះឆ្នោតនៅមូលដ្ឋានរបស់អ្នក និងការរៀបចំសន្លឹកឆ្នោតរបស់អ្នក ។

ព័ត៌មានដែលបង្ហាញនៅលើគេហទំព័រនេះ ត្រូវបានផ្តល់ជូនដោយមន្ត្រីរៀបចំការបោះឆ្នោតនៅមូលដ្ឋានរបស់អ្នក ។ លោកអ្នកត្រូវទាក់ទងមន្ត្រីរៀបចំការបោះឆ្នោតនៅមូលដ្ឋានរបស់អ្នកដោយមានសំណួរ ឬការព្រួយបារម្ភអំពីសន្លឹកឆ្នោតបោះមុនដែលមិនអាចទៅស្ថានីយបោះឆ្នោត ឬសន្លឹកឆ្នោតបោះមុនរបស់អ្នក ។ ប្រសិនបើសន្លឹកឆ្នោតរបស់អ្នកត្រូវបានបដិសេធដោយមូលហេតុណាមួយ (ដូចជាការខកខានចុះហត្ថលេខាលើលិខិតបញ្ជាក់នៅលើស្រោមសំបុត្រសន្លឹកឆ្នោត) លោកអ្នកនឹងត្រូវបានគេផ្ញើជូនសន្លឹកឆ្នោតថ្មី ដរាបណាមានពេលវេលាអនុញ្ញាត ។ គេបានផ្តល់អនុសាសន៍ថា លោកអ្នកដាក់ពាក្យសុំសន្លឹកឆ្នោតរបស់អ្នក ហើយបញ្ជូនត្រឡប់មកវិញភ្លាមៗដែលអាចធ្វើទៅបាននៅមុនថ្ងៃបោះឆ្នោត ។

# ការបោះឆ្នោតមុន និងការបោះឆ្នោតមុនដែលមិនអាចទៅស្ថានីយបោះឆ្នោត

## ការបោះឆ្នោតមុន

ដើម្បីភាពងាយស្រួលរបស់អ្នក លោកអ្នកអាចបោះឆ្នោតសម្រាប់ការបោះឆ្នោតរដ្ឋនៅថ្ងៃទី 6 ខែវិច្ឆិកា មុនថ្ងៃបោះឆ្នោត ។

### តើការបោះឆ្នោតមុនជាអ្វី?

សន្លឹកឆ្នោតបោះមុន គឺសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតធម្មតា ដែលអ្នកបោះឆ្នោតអាចស្នើសុំ និងបោះឆ្នោតមុនថ្ងៃបោះឆ្នោត ។ សន្លឹកឆ្នោតបោះមុនដែលមានសុពលភាពទាំងអស់ នឹងត្រូវរាប់នៅថ្ងៃបោះឆ្នោត ដោយមានសន្លឹកឆ្នោតដែលបានបោះនៅកន្លែងបោះឆ្នោត ។

### តើអ្នកណាអាចបោះឆ្នោតមុន?

អ្នកបោះឆ្នោតនៅរដ្ឋ Massachusetts ដែលចុះឈ្មោះទាំងអស់ មានសិទ្ធិបោះឆ្នោតមុន ។

### តើខ្ញុំអាចបោះឆ្នោតមុនដោយរបៀបណា?

លោកអ្នកអាចបោះឆ្នោតមុនដោយផ្ទាល់នៅកន្លែងបោះឆ្នោតមុនណាមួយនៅទីក្រុង ឬខេត្តរបស់អ្នក ឬតាមប៉ុស្តិ៍ប្រៃសណីយ៍ ។

ពាក្យសុំដែលអាចបោះពុម្ពឬព្រីនបាន សម្រាប់សន្លឹកឆ្នោតបោះមុនដែលបានផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ អាចរកបានតាមវ៉ែបសាយ **www.MassEarlyVote.com** ។ សំណុំបែបបទនេះ ត្រូវបំពេញ និងដាក់ជូនមន្ត្រីរៀបចំការបោះឆ្នោតនៅមូលដ្ឋានរបស់អ្នក ដែលនឹងផ្ញើសន្លឹកឆ្នោតរបស់អ្នកតាមប៉ុស្តិ៍ប្រៃសណីយ៍នៅពេលចាប់ផ្តើមបោះឆ្នោតមុនពេល ។ សន្លឹកឆ្នោតទាំងអស់ត្រូវបញ្ជូនត្រឡប់មកវិញទៅមន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋានរបស់អ្នកនៅត្រឹមម៉ោង 8 ល្ងាច នៅថ្ងៃបោះឆ្នោត ។

### តើខ្ញុំអាចបោះឆ្នោតមុននៅឯណា?

មានកន្លែងបោះឆ្នោតមុនយ៉ាងតិចមួយកន្លែងនៅតាមទីក្រុង និងខេត្តនីមួយៗ ។ សម្រាប់បញ្ជីទីកន្លែងបោះឆ្នោតមុននៅក្នុងសហគមន៍របស់អ្នក សូមចូលទៅវ៉ែបសាយ www.MassEarlyVote.com នៅដើមខែតុលា ។

### តើខ្ញុំអាចបោះឆ្នោតមុននៅពេលណា?

រយៈពេលបោះឆ្នោតមុន នឹងចាប់ផ្តើមនៅថ្ងៃទី 22 ហើយនឹងបញ្ចប់នៅថ្ងៃទី 2 ខែវិច្ឆិកា ។ មន្ត្រីរៀបចំការបោះឆ្នោតនៅមូលដ្ឋានរបស់អ្នក ត្រូវតែអនុវត្តដំណើរការបោះឆ្នោតមុន នៅម៉ោងធ្វើការធម្មតារបស់ពួកគេ ប៉ុន្តែពួកគេអាចមានម៉ោងបន្ថែម ។ សម្រាប់បញ្ជីកាលបរិច្ឆេទនិងពេលវេលានៃដំណើរការបោះឆ្នោតមុននៅក្នុងសហគមន៍របស់អ្នក សូមចូលទៅវ៉ែបសាយ **www.MassEarlyVote.com** នៅដើមខែតុលា ។

## ការបោះឆ្នោតមុនដែលមិនអាចទៅស្ថានីយបោះឆ្នោត

ការបោះឆ្នោតមុនដែលមិនអាចទៅស្ថានីយបោះឆ្នោតសម្រាប់អ្នកទាំងនោះ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។ អ្នកបោះឆ្នោតអាចបោះសន្លឹកឆ្នោតមុនដែលមិនអាចទៅស្ថានីយបោះឆ្នោត ប្រសិនបើពួកគេនឹងអវត្តមានពីទីក្រុងរបស់ពួកគេនៅថ្ងៃបោះឆ្នោត ឬប្រសិនបើពួកគេមានពិការភាព ឬជំនឿសាសនា ដែលរារាំងពួកគេពីការបោះឆ្នោតនៅកន្លែងបោះឆ្នោតរបស់ពួកគេ ។ មិនដូចគ្នាការបោះឆ្នោតមុនទេ ដែលបច្ចុប្បន្នអាចប្រព្រឹត្តទៅបានសម្រាប់ការបោះឆ្នោតរដ្ឋនៅខែវិច្ឆិកាតែប៉ុណ្ណោះ ការបោះឆ្នោតមុនដែលមិនអាចទៅស្ថានីយបោះឆ្នោតអាចប្រព្រឹត្តទៅបានសម្រាប់ការបោះឆ្នោតទាំងអស់ ។

ការដាក់ពាក្យសុំសន្លឹកឆ្នោតបោះមុនដែលមិនអាចទៅស្ថានីយបោះឆ្នោត អាចប្រព្រឹត្តទៅបានតាមវ៉ែបសាយ **www.sec.state.ma.us/ele** ។

សេវាកម្មប៉ុស្តិ៍ប្រៃសណីយ៍ ផ្តល់អនុសាសន៍ថា អ្នកបោះឆ្នោតនានាផ្ញើសន្លឹកឆ្នោតតាមប៉ុស្តិ៍ប្រៃសណីយ៍ **មិនយូរជាងមួយសប្តាហ៍មុនថ្ងៃបោះឆ្នោត** ដើម្បីដោះស្រាយបញ្ហាដែលមិអាចដឹងមុនបាន ឬបញ្ហាអាកាសធាតុ និងដើម្បីអនុញ្ញាតឱ្យមានការទទួលនិងដំណើរការទាន់ពេលវេលាតាមរយៈមន្ត្រីរៀបចំការបោះឆ្នោត ។

# អ្នកបោះឆ្នោតជាយោធា និងនៅបរទេស

នៅរដ្ឋម៉ាសាឈូសេត Massachusetts សមាជិកសេវាកម្មដែលមានឯកសណ្ឋានដែលបំពេញ **កាតព្វកិច្ចយ៉ាងសកម្ម** ក្រុមគ្រួសាររបស់ពួកគេ និងពលរដ្ឋអាមេរិកដែលរស់នៅក្រៅប្រទេស មានសិទ្ធិបោះឆ្នោតនៅក្នុងការបោះឆ្នោតទាំងអស់ ។ អ្នកបោះឆ្នោតទាំងនេះ **មិនចាំបាច់ចុះឈ្មោះបោះឆ្នោត ដើម្បីស្នើសុំសសន្លឹកឆ្នោតបោះមុនដែលមិនអាចទៅស្ថានីយបោះឆ្នោតឡើយ** ។ សន្លឹកឆ្នោតបោះមុនដែលមិនអាចទៅស្ថានីយបោះឆ្នោត អាចស្នើសុំដោយប្រើប្រាស់ការដាក់ពាក្យសុំប័ណ្ណប្រៃសណីយ៍របស់សហព័ន្ធ ឬសំណុំបែបបទនៃការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរណាមួយ ឬ**សមាជិកក្រុមគ្រួសារ អាចស្នើសុំ**ថា សន្លឹកឆ្នោតបោះមុនដែលមិនអាចទៅស្ថានីយបោះឆ្នោត ត្រូវផ្ញើជូនទៅអ្នកបោះឆ្នោត ។

អ្នកបោះឆ្នោតទាំងនេះ អាចស្នើសុំថាសន្លឹកឆ្នោតបោះមុនដែលមិនអាចទៅស្ថានីយបោះឆ្នោតរបស់ពួកគេ ត្រូវផ្ញើទៅពួកគេតាមប៉ុស្តិ៍ប្រៃសណីយ៍ ទូរសា ឬតាមអ៊ីម៉ែល; សន្លឹកឆ្នោតក៏អាចត្រូវប្រគល់ជូនមន្ត្រីរៀបចំការបោះឆ្នោតនៅមូលដ្ឋានផងដែរ តាមវិធីសាស្ត្រទាំងនេះ ។

រដ្ឋម៉ាសាឈូសេត Massachusetts ក៏អនុញ្ញាតឱ្យអ្នកបោះឆ្នោតជាយោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេស ដើម្បីឆ្នោតបោះមុនដែលមិនអាចទៅស្ថានីយបោះឆ្នោតនៅក្នុងការបោះឆ្នោតទាំងអស់ ដោយប្រើសន្លឹកឆ្នោតបោះមុនដែលមិនអាចទៅស្ថានីយបោះឆ្នោតដែលមានបញ្ជាក់ជាលាយលក្ខណ៍អក្សរពីសហព័ន្ធ (FWAB) ។ សន្លឹកឆ្នោតបោះមុន FWAB អាចត្រូវប្រើប្រាស់ ដើម្បីបោះឆ្នោតគ្រប់ពេលវេលា មុនការបោះឆ្នោត ទោះបីជាអ្នកបោះឆ្នោតមិនបានដាក់ពាក្យសុំសន្លឹកឆ្នោតបោះមុនដែលមិនអាចទៅស្ថានីយបោះឆ្នោតក៏ដោយ ។ បន្ទាប់ពីការបោះឆ្នោតនៅលើសន្លឹកឆ្នោតបោះមុន FWAB អ្នកបោះឆ្នោតអាចបញ្ជូនវាតាមប៉ុស្តិ៍ប្រៃសណីយ៍ ឬតាមអេឡិចត្រូនិក ។ ពាក្យសុំប័ណ្ណតាមប៉ុស្តិ៍ប្រៃសណីយ៍របស់សហព័ន្ធ និងសន្លឹកឆ្នោតបោះមុនដែលមិនអាចទៅស្ថានីយបោះឆ្នោតដែលមានបញ្ជាក់ជាលាយលក្ខណ៍អក្សរពីសហព័ន្ធ អាចរកបានតាមហទំព័រនៃកម្មវិធីជំនួយគាំទ្រការបោះឆ្នោតសហព័ន្ធ ។**www.FVAP.gov** ។

# ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត

## តើខ្ញុំបោះឆ្នោតនៅឯណា?

អាសយដ្ឋាននីមួយៗ កំណត់កន្លែងបោះឆ្នោត ។ សូមចូលវែបសាយ**www.WhereDoIVoteMA.com** ដើម្បីរកកន្លែងបោះឆ្នោតរបស់អ្នក ។

លោកអ្នកក៏អាចហៅទូរស័ព្ទទៅផ្នែករៀបចំការបោះឆ្នោតតាមលេខ 1-800-462-VOTE (8683) សម្រាប់ជំនួយស្វែងរកកន្លែងបោះឆ្នោតរបស់អ្នក ។

កន្លែងបោះឆ្នោតទាំងអស់ត្រូវកំណត់ដោយច្បាប់សហព័ន្ធ និងច្បាប់រដ្ឋ ដែលអ្នកបោះឆ្នោតវ័យចាស់ និងជនពិការអាចចូលមើលបាន ។

## តើកន្លែងបោះឆ្នោត បើកដំណើរការនៅពេលណា?

ទីកន្លែងបោះឆ្នោតនានា បើកដំណើរការចាប់ពីម៉ោង 7:00 ព្រឹក ដល់ 8:00 ល្ងាច សម្រាប់ការបោះឆ្នោតរដ្ឋ ។ ទីក្រុងមួយចំនួនអាចបើកដំណើរការទីកន្លែងបោះឆ្នោតរបស់ពួកគេឆាប់ជាងនេះ គឺចាប់ពីម៉ោង 5:45 ព្រឹក សូមទាក់ទងមន្ត្រីរៀបចំការបោះឆ្នោតនៅមូលដ្ឋានរបស់អ្នក ដើម្បីផ្ទៀងផ្ទាត់ម៉ោងបោះឆ្នោតរបស់អ្នក ។

## តើខ្ញុំអាចរកឃើញការិយាល័យ និងបេក្ខជនណាខ្លះ ដែលមាននៅលើសន្លឹកឆ្នោតរបស់ខ្ញុំដោយរបៀបណា?

សន្លឹកឆ្នោតគំរូ ក៏ដូចជាប័ណ្ណណែនាំ ត្រូវបានបិទប្រកាសនៅកន្លែងបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។ លោកអ្នកក៏អាចមើលសន្លឹកឆ្នោតគំរូផងដែរតាមវែបសាយ **www.WhereDoIVoteMA.com** ។

## ខ្ញុំបានចុះឈ្មោះបោះឆ្នោត ប៉ុន្តែឈ្មោះរបស់ខ្ញុំមិនមាននៅក្នុងបញ្ជីឈ្មោះបោះឆ្នោត—តើខ្ញុំត្រូវធ្វើដូចម្ដេច?

ប្រសិនបើលោកអ្នកចុះឈ្មោះបោះឆ្នោត ប៉ុន្តែឈ្មោះរបស់អ្នកមិនមាននៅក្នុងបញ្ជីឈ្មោះបោះឆ្នោត សូមសាកសួរមន្ត្រីរៀបចំការបោះឆ្នោតដែលទទួលបន្ទុកនៅកន្លែងបោះឆ្នោត ដើម្បីពិនិត្យមើលការចុះឈ្មោះរបស់អ្នក ដោយពិនិត្យមើលបញ្ជីឈ្មោះបោះឆ្នោតអសកម្ម ហើយពិនិត្យមើលស្មៀនទីក្រុងឬខេត្ត ដើម្បីដឹងថាតើលោកអ្នកអាចត្រូវបានគេចុះបញ្ជីឈ្មោះនៅក្នុងមណ្ឌលបោះឆ្នោតមួយទៀតនៅក្នុងទីក្រុងនោះឬទេ ។

ប្រសិនបើពួកគេនៅតែមិនអាចរកឈ្មោះរបស់អ្នក លោកអ្នកអាចទៅសាលាក្រុងឬខេត្ត ដើម្បីព្យាយាមកំណត់អត្តសញ្ញាណរបស់អ្នកជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះ ឬលោកអ្នកអាចបោះឆ្នោតបណ្ដោះអាសន្ននៅកន្លែងបោះឆ្នោត ។

ដើម្បីបោះឆ្នោតបណ្ដោះអាសន្ន លោកអ្នកត្រូវតែបំពេញលិខិតបញ្ជាក់សន្លឹកឆ្នោតបណ្ដោះអាសន្ន ដែលប្រកាសថាលោកអ្នកជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះនៅក្នុងទីក្រុងឬខេត្តដែលលោកអ្នករស់នៅក្នុងមណ្ឌលបោះឆ្នោតនោះ ។ លោកអ្នកត្រូវតែបង្ហាញប័ណ្ណសម្គាល់ខ្លួនដែលសមស្រប ។

បន្ទាប់ពីការបោះឆ្នោតហើយ មន្ត្រីរៀបចំការបោះឆ្នោតនៅមូលដ្ឋាននឹងស្វែងរកកំណត់ត្រានានា ដើម្បីបញ្ជាក់អំពីការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក ។ ប្រសិនបើភាពមានសិទ្ធិបោះឆ្នោតរបស់អ្នក ត្រូវបានបញ្ជាក់នោះ សន្លឹកឆ្នោតរបស់អ្នកនឹងត្រូវបានរាប់បញ្ចូល ។ ប្រសិនបើភាពមានសិទ្ធិបោះឆ្នោតរបស់អ្នក មិនអាចបញ្ជាក់បាននោះ សន្លឹកឆ្នោតរបស់អ្នកនឹងនៅតែបិទនៅក្នុងស្រោមសំបុត្រដដែល ។

## តើមានអ្វីកើតឡើងនៅកន្លែងបោះឆ្នោត?

នៅរដ្ឋម៉ាសាជូសេត Massachusetts អ្នកបោះឆ្នោតម្នាក់ៗបោះឆ្នោតជាសន្លឹកឆ្នោតក្រដាស ។ នៅពេលលោកអ្នកចូលកន្លែងបោះឆ្នោត លោកអ្នកត្រូវតែទៅតុត្រួតពិនិត្យអ្នកចូលបោះឆ្នោត ដែលលោកអ្នកនឹងត្រូវបានគេសួររកឈ្មោះនិងអាសយដ្ឋានរបស់អ្នក ។

នៅពេលលោកអ្នកទទួលបានសន្លឹកឆ្នោតរបស់អ្នកហើយ លោកអ្នកទៅបន្ទប់បោះឆ្នោតជាទីកន្លែងដែលលោកអ្នកគូសយកជម្រើសរបស់អ្នកសម្រាប់បេក្ខជន និងសំណួរបោះឆ្នោត ។

បន្ទាប់ពីបានគូសសន្លឹកឆ្នោតរបស់អ្នកហើយ លោកអ្នកត្រូវតែទៅតុត្រួតពិនិត្យអ្នកចេញពីបោះឆ្នោត ហើយប្រាប់ឈ្មោះនិងអាសយដ្ឋានរបស់អ្នកម្ដងទៀត មុនដាក់ចូលសន្លឹកឆ្នោតរបស់អ្នកទៅក្នុងប្រអប់ឆ្នោត ។

## ចុះបើខ្ញុំត្រូវការជំនួយ?

ប្រសិនបើលោកអ្នកត្រូវការជំនួយដោយសារតែពិការភាព ពិការភ្នែក ឬអសមត្ថភាពក្នុងការអាន ឬអានភាសាអង់គ្លេសនោះ លោកអ្នកអាចស្វែងរកជំនួយពីបុគ្គលណាម្នាក់ដែលជាជម្រើសរបស់អ្នក ដែលរួមមានមន្ត្រីរៀបចំការបោះឆ្នោតនៅកន្លែងបោះឆ្នោតរបស់អ្នក ។

លោកអ្នកក៏អាចស្នើសុំមន្ត្រីរៀបចំការបោះឆ្នោតផងដែរ ដើម្បីបង្ហាញលោកអ្នកទៅកាន់ឧបករណ៍ជំនួយអ្នកបោះឆ្នោតដោយស្វ័យប្រវត្តិ (AutoMARK Voter Assist Terminal) ដែលជាឧបករណ៍គូសសន្លឹកឆ្នោតដែលអាចប្រើប្រាស់បានដែលអនុញ្ញាតឱ្យលោកអ្នកអាចគូសសន្លឹកឆ្នោតរបស់អ្នកដោយឯកជន និងដោយឯករាជ្យ ។ ឧបករណ៍ជំនួយអ្នកបោះឆ្នោតដោយស្វ័យប្រវត្តិ AutoMARK Voter Assist Terminal មានមួយយ៉ាងតិច នៅកន្លែងបោះឆ្នោតនីមួយៗ ។ បន្ទាប់ពីបានបញ្ចូលសន្លឹកឆ្នោតចូលទៅក្នុងឧបករណ៍ AutoMARK នោះ អ្នកបោះឆ្នោតអាចពិនិត្យមើលសន្លឹកឆ្នោតឡើងវិញ និងធ្វើការជ្រើសរើសដោយប្រើអេក្រង់ថាច់ស្គ្រីន ឬអេក្រង់ចុចដោយប្រើដៃ និង/ឬ ប៊ូតុងចុច នៅខណៈពេលកំពុងស្ដាប់សន្លឹកឆ្នោតតាមកាសស្ដាប់ត្រចៀក ។ ឧបករណ៍ AutoMARK នឹងគូសសន្លឹកឆ្នោតស្របតាមជម្រើសរបស់អ្នក ដោយបំពេញនៅក្នុងប្រអប់រាងពងក្រពើដែលត្រូវគ្នា ឬមានភ្ជាប់សញ្ញាព្រួញនៅលើសន្លឹកឆ្នោត ។ បន្ទាប់មកសន្លឹកឆ្នោតនឹងវិលត្រឡប់មកលោកអ្នកវិញ ដើម្បីដាក់ចូលក្នុងប្រអប់ឆ្នោត ។

## តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំមានកំហុសឆ្គងនៅលើសន្លឹកឆ្នោតរបស់ខ្ញុំ?

ប្រសិនបើលោកអ្នកមានកំហុសឆ្គងនៅលើសន្លឹកឆ្នោតរបស់អ្នកលោកអ្នកអាចស្នើសុំសន្លឹកឆ្នោតថ្មីមួយទៀត ។ លោកអ្នកអាចស្នើសុំសន្លឹកឆ្នោតថ្មីរហូតដល់ចំនួនពីរសន្លឹក ។

## តើខ្ញុំអាចនាំយកសម្ភារទៅក្នុងកន្លែងបោះឆ្នោតបានឬទេ?

បាទ/ចាស៎ លោកអ្នកអាចនាំយកសម្ភារទៅក្នុងបន្ទប់បោះឆ្នោត ។ លោកអ្នកអាចនាំយកខិត្តប័ណ្ណដែលបានបោះពុម្ពឬព្រីនជាមុន ឬកូនសៀវភៅផ្សព្វផ្សាយ ឬកូនសៀវភៅកំណត់ត្រាផ្ទាល់ខ្លួនរបស់អ្នក ប៉ុន្តែលោកអ្នកមិនអាចបង្ហាញសម្ភារទាំងនោះបានទេ នៅខណៈពេលលោកអ្នកនៅក្នុងកន្លែងបោះឆ្នោត ។ លោកអ្នកត្រូវយកសម្ភារណាមួយជាមួយលោកអ្នក នៅពេលលោកអ្នកចាកចេញពីបន្ទប់បោះឆ្នោត ។

# សេវាកម្មនៃលេខាធិការសហគមន៍ឯករាជ្យនៃរដ្ឋម៉ាសាឈូសេត Massachusetts

• **សេវាកម្មព័ត៌មានប្រជាពលរដ្ឋ** មានមុខងារជាទីភ្នាក់ងារព័ត៌មានសំខាន់ និងទីភ្នាក់ងារដែលជាអ្នកជំនាញត្រូវបញ្ជូនមកសម្រាប់រដ្ឋ ដែលផ្តល់ជូនព័ត៌មានអំពីកម្មវិធី និងទីភ្នាក់ងាររបស់រដ្ឋ ។ CIS ព្យាយាមឆ្លើយតបគ្រប់សំណើទាំងអស់ ដោយផ្តល់ជូនជំនួយផ្ទាល់ ឬអ្នកជំនាញត្រូវបញ្ជូនមកភ្លាមៗទៅកាន់ទីភ្នាក់ងារដែលសមស្រប ។ ជាផ្នែកមួយនៃគោលដៅរបស់ខ្លួន ដើម្បីធ្វើឱ្យរដ្ឋាភិបាលរដ្ឋអាចចូលដំណើរការបានចំពោះសាធារណជនកាន់តែច្រើនថែមទៀតនោះ CIS បានបង្កើតស៊េរីបោះពុម្ពផ្សាយប្រធានបទអំពីអត្ថប្រយោជន៍ជាក់លាក់ ដែលរួមមាន ៖

- មគ្គុទ្ទេសន៍របស់ពលរដ្ឋចំពោះសេវាកម្មរដ្ឋ ៖ បញ្ជីឈ្មោះដែលជ្រើសរើសសម្រាប់ទីភ្នាក់ងារនិងកម្មវិធីរបស់រដ្ឋាភិបាល ដោយមានអាសយដ្ឋានលេខទូរស័ព្ទ និងការពណ៌នាអំពីទីភ្នាក់ងារ ។ តម្លៃ ៖ $22.00 ($15 បូក $7.00 ថ្លៃឈ្នួលដឹកជញ្ជូន) ។ អនឡាញដោយឥតគិតថ្លៃ តាមវែបសាយ **www.sec.state.ma.us/cis/ciscig/guide.html** ។ អាចរកបានពីបណ្ណាគារមន្ទីររដ្ឋសភារដ្ឋ សូមមើលខាងក្រោម ។
- សូមស្វាគមន៍មកកាន់រដ្ឋម៉ាសាឈូសេត Massachusetts ៖ មគ្គុទ្ទេសន៍ជាក់ស្តែងក្នុងការរស់នៅក្នុងរដ្ឋ ដោយឥតគិតថ្លៃ ។
- ពន្ធអាករលើរថយន្ត ដោយឥតគិតថ្លៃ ។
- ការលើកលែងពន្ធលើអចលនទ្រព្យចំពោះមនុស្សចាស់ ប្តីឬប្រពន្ធដែលនៅរស់រានមានជីវិត និងអនីតិជន ដោយឥតគិតថ្លៃ ។
- ផ្ទះសម្បែងដែលមានសុវត្ថិភាពនិងអនាម័យសម្រាប់អ្នករស់នៅរដ្ឋម៉ាសាឈូសេត Massachusetts ដោយឥតគិតថ្លៃ ។
- មគ្គទេសក៍អំពីច្បាប់និងអត្ថប្រយោជន៍អតីតយុទ្ធជន ដោយឥតគិតថ្លៃ ។
- ហេតុការណ៍ពិតនៅរដ្ឋម៉ាសាឈូសេត Massachusetts ៖ ការពិនិត្យឡើងវិញនូវប្រវត្តិសាស្ត្រ រដ្ឋាភិបាល និងនិមិត្តសញ្ញារបស់រដ្ឋ សម្រាប់សិស្សដល់អាយុរៀនវិទ្យាល័យ ដោយឥតគិតថ្លៃ ។

សេវាកម្មព័ត៌មានប្រជាពលរដ្ឋ អាចទាក់ទងតាមទូរស័ព្ទលេខ 617-727-7030 ឬ 1-800-392-6090 (ដោយឥតគិតថ្លៃនៅរដ្ឋ Massachusetts តែប៉ុណ្ណោះ), វែបសាយ ៖ **www.sec.state.ma.us/cis**, ដែលឯកសារជាច្រើនខាងលើ អាចរកមើលបាន ។
អ៊ីម៉ែល ៖ cis@sec.state.ma.us

• **ផ្នែកបោះឆ្នោត** គ្រប់គ្រងការបោះឆ្នោតរដ្ឋទាំងអស់ ផ្តល់ជូនព័ត៌មានអំពីការបោះឆ្នោត និងផ្គត់ផ្គង់សម្ភារបោះឆ្នោតដល់សាធារណជន បេក្ខជន និងមន្ត្រីរដ្ឋាភិបាល ។ 617-727-2828 ឬ 1-800-462-VOTE (8683),
វែបសាយ ៖ **www.sec.state.ma.us/ele**
អ៊ីម៉ែល ៖ elections@sec.state.ma.us

• **ផ្នែកមូលបត្រ** ខិតខំការពារវិនិយោគិននៅរដ្ឋម៉ាសាឈូសេត Massachusetts តាមរយៈការផ្តល់អាជ្ញាប័ណ្ណលក់មូលបត្រ ដែលកំណត់ថាមូលបត្រដែលមានហានិភ័យខ្ពស់ត្រូវចុះបញ្ជី ការស៊ើបអង្កេតពាក្យបណ្តឹង និងការចាត់វិធានការអនុវត្ត និង និងវិធានការវិន័យសមស្រប ។ 617-727-3548 ឬ 1-800-269-5428 (នៅក្នុងរដ្ឋ Massachusetts), វែបសាយ ៖ **www.sec.state.ma.us/sct**
អ៊ីម៉ែល ៖ securities@sec.state.ma.us

• **ផ្នែកកំណត់ត្រាសាធារណៈ** រក្សាទុក ថែរក្សា និងធ្វើឱ្យកំណត់ត្រារបស់រដ្ឋាភិបាលដែលអាចចូលប្រើបាន និងកត់ត្រារាល់ការណាត់ជួបអភិបាលខេត្ត និងគណៈកម្មការទាំងអស់ ។ 617-727-2832,
វែបសាយ ៖ **www.sec.state.ma.us/pre**
អ៊ីម៉ែល ៖ pre@sec.state.ma.us

• **កំណត់ត្រាអចលនទ្រព្យ** ។ ព័ត៌មានអំពីការទាញយកសិទ្ធិជាម្ចាស់ និងផ្ទះកំណើត - រដ្ឋម៉ាសាឈូសេត Massachusetts ត្រូវបានបែងចែកជា 21 មណ្ឌលចុះបញ្ជីដោយមានការិយាល័យចុះបញ្ជីលិខិតផ្ទេរកម្មសិទ្ធិដែលបានជ្រើសរើស ដែលទទួលខុសត្រូវនៅតាមការិយាល័យនីមួយៗ ។ ឯកសារពាក់ព័ន្ធនឹងភាពជាម្ចាស់កម្មសិទ្ធិអចលនទ្រព្យនៅក្នុងមណ្ឌល ត្រូវបានកត់ត្រានៅការិយាល័យចុះបញ្ជីលិខិតផ្ទេរកម្មសិទ្ធិ ។
គេហទំព័រ ៖ **www.masslandrecords.com**

• **កន្លែងទុកឯកសារនៅរដ្ឋម៉ាសាឈូសេត Massachusetts** ប្រមូល ចុះបញ្ជីឈ្មោះជាក្រុម និងថែរក្សាកំណត់ត្រា តម្លៃបិតថេរពីរដ្ឋាភិបាលនៃរដ្ឋ ដែលមានរយៈពេលជិត 400 ឆ្នាំ ។ កន្លែងទុកឯកសារបម្រើការជាធនធានដ៏សំខាន់ដល់សិស្ស អ្នកតំណពូជពង្ស និងនិស្សិត និងជាទីប្រឹក្សារបស់សហគមន៍កត់ត្រាប្រវត្តិសាស្ត្រនៅរដ្ឋម៉ាសាឈូសេត Massachusetts ។ 617-727-2816,
វែបសាយ ៖ **www.sec.state.ma.us/arc**
អ៊ីម៉ែល ៖ archives@sec.state.ma.us

• **សារមន្ទីរសហគមន៍ឯករាជ្យ** នាំមកប្រវត្តិសាស្ត្ររដ្ឋម៉ាសាឈូសេត Massachusetts ដែលមានសកម្មភាពរស់រវើកតាមរយៈការតាំងពិព័រណ៍ ការផ្សព្វផ្សាយ និងកម្មវិធីសិស្ស និងការបោះពុម្ពផ្សព្វផ្សាយ ។ 617-727-9268 វែបសាយ ៖ **www.commonwealthmuseum.org**

• **គណៈកម្មការប្រវត្តិសាស្ត្ររដ្ឋម៉ាសាឈូសេត Massachusetts** គឺជាទីភ្នាក់ងាររដ្ឋដែលទទួលខុសត្រូវចំពោះការថែរក្សាប្រវត្តិសាស្ត្រនៅសហគមន៍ឯករាជ្យ ។ គណៈកម្មការនេះ ផ្តល់ជំនួយដល់សហគមន៍នានាក្នុងការចុះបញ្ជីអចលនទ្រព្យជាមួយនឹងការិយាល័យចុះបញ្ជីទីកន្លែងប្រវត្តិសាស្ត្រថ្នាក់ជាតិ និងការបង្កើតមណ្ឌលប្រវត្តិសាស្ត្រនៅមូលដ្ឋាន ។ 617-727-8470
វែបសាយ ៖ **www.sec.state.ma.us/mhc**
អ៊ីម៉ែល ៖ mhc@sec.state.ma.us

• **បណ្ណាគាររដ្ឋ** ផ្តល់ជូនសៀវភៅនិងខិត្តប័ណ្ណជាច្រើន ដែលត្រូវបានបោះពុម្ពផ្សព្វផ្សាយដោយលេខាធិការសហគមន៍ឯករាជ្យ និងទីភ្នាក់ងាររដ្ឋផ្សេងៗទៀត ដែលរួមមានក្រមនៃបទប្បញ្ញត្តិរដ្ឋ Massachusetts ផងដែរ ។ កាតាឡុកបណ្ណាគារឥតគិតថ្លៃ ដែលអាចរកបាន ។ 617-727-2834 វែបសាយ ៖ **www.sec.state.ma.us/spr**
អ៊ីម៉ែល ៖ bookstore@sec.state.ma.us

• **ការិយាល័យប្រចាំតំបន់** នៅ Springfield និង Fall River ផ្តល់ជូនសេវាកម្មជាច្រើន ដែលផ្តល់ដោយការិយាល័យបូស្តុន Boston និងនាំរដ្ឋាភិបាលរដ្ឋកាន់តែជិតស្និទ្ធនឹងប្រជាពលរដ្ឋនៃរដ្ឋម៉ាសាឈូសេត Massachusetts ។ Springfield 413-784-1376, Fall River 508-646-1374,
វែបសាយ ៖ **www.sec.state.ma.us/wso**

• **ផ្នែកសាជីវកម្ម** ផ្នែកសាជីវកម្ម ទទួលខុសត្រូវចំពោះការចុះបញ្ជីក្រុមហ៊ុនសាជីវកម្មដែលរកប្រាក់ចំណេញ និងមិនរកប្រាក់ចំណេញទាំងអស់នៃរដ្ឋម៉ាសាឈូសេត Massachusetts និងផ្តល់ព័ត៌មានសង្ខេបភ្លាមៗអំពីអង្គភាពជិត 400,000 ដែលកំពុងធ្វើអាជីវកម្មនៅក្នុងរដ្ឋនេះ ។ 617-727-2850 ឬ 617-727-9640,
វែបសាយ ៖ **www.sec.state.ma.us/cor**
អ៊ីម៉ែល ៖ corpinfo@sec.state.ma.us

ផ្នែកផ្សេងទៀត រួមមាន ៖

• **អ្នកបញ្ចុះបញ្ចូល** ៖ វែបសាយ ៖ **www.sec.state.ma.us/lob**

• **មជ្ឈមណ្ឌលកំណត់ត្រារដ្ឋ**
វែបសាយ ៖ **www.sec.state.ma.us/rec**

• **ការបោះពុម្ពផ្សព្វផ្សាយ និងបទបញ្ជារបស់រដ្ឋ**
វែបសាយ ៖ **www.sec.state.ma.us/spr**

• **ដំណើរកម្សាន្តនៅមន្ទីររដ្ឋសភារដ្ឋ** ៖ វែបសាយ ៖ **www.sec.state.ma.us/trs**

# ប្រសិនបើលោកអ្នកជាជនរងគ្រោះពីការលួចបន្លំវិនិយោគនោះ ការិយាល័យលេខាធិការ Galvin អាចជួយបាន!

ការិយាល័យលេខាធិការ Secretary Galvin ធ្វើនិយតកម្មនិងអនុវត្តច្បាប់នានាដែលទាក់ទងនឹងការវិនិយោគដែលមានហានិភ័យគ្រប់ប្រភេទ ដែលត្រូវបានផ្តល់ជូន ឬលក់នៅរដ្ឋម៉ាសាឈូសេត Massachusetts ។

ការិយាល័យលេខាធិការ Secretary Galvin បានទទួលជោគជ័យក្នុងការយកលុយរាប់លានដុល្លារដោយផ្ទាល់ត្រឡប់ទៅអ្នកវិនិយោគដែលគេបោកប្រាស់ ។

**សូមពិនិត្យមើលថាតើស្ថានភាពទាំងនេះដែលយើងខ្ញុំអាចជួយ គឺមានស្រដៀងគ្នានឹងអ្នកដែរឬទេ ៖**

- ស្រ្តីមេម៉ាយវ័យចំណាស់ម្នាក់បានទៅសាខាធនាគារនៅមូលដ្ឋានរបស់នាង ដើម្បីដាក់ប្រាក់ពីការលក់ទ្រព្យសម្បត្តិ ហើយត្រូវបានបញ្ចុះបញ្ចូលដោយឈ្មួញកណ្តាលឱ្យធ្វើវិនិយោគនៅក្នុងមូលនិធិផ្សារហ៊ុន និងស៊ីឌីដែលទាក់ទងនឹងទីផ្សារ ។ អតិថិជនបានគេយល់ច្រឡំអំពីប្រភេទនៃការវិនិយោគ ពីព្រោះទ្រព្យសម្បត្តិបានលក់ឱ្យនាងនៅក្នុងសាខាធនាគារ ហើយឈ្មួញកណ្តាលបានជំទាស់នឹងបំណងប្រាថ្នាជាក់លាក់របស់នាងមិនមានការបង្ហាញទីផ្សារផ្សារហ៊ុនដោយដាក់នាងនៅក្នុងផលិតផលទាំងនោះ ។ អតិថិជនបានទាក់ទងការិយាល័យលេខាធិការ Secretary Galvin ហើយអាចយកលុយធ្វើត្រឡប់មកវិញ និងទទួលបានលុយរបស់នាងទាំងអស់វិញ ។
- ឈ្មួញកណ្តាលទុច្ចរិតពីរនាក់ពីមេឈ្មួញកណ្តាលបានចូលរួមក្នុងការជួញដូរហួសប្រមាណនៅក្នុងគណនីមនុស្សចាស់ម្នាក់ ដើម្បីបង្កើតកម្រៃជើងសារខ្ពស់សម្រាប់ខ្លួនឯង ។ ភ្នាក់ងារនានាបានលាក់បាំងចំនួនទឹកប្រាក់ដែលបានគិតថ្លៃអតិថិជនដូច្នេះគាត់មិនអាចរកឃើញឈ្មួញរកប្រាក់ទឹកតែពីគណនីរបស់គាត់ឡើយ ។ អតិថិជនបានទាក់ទងការិយាល័យលេខាធិការ Secretary Galvin និងទទួលបានមកវិញថ្លៃឈ្នួលហួសប្រមាណមួយចំនួន ដែលបានគិតថ្លៃតាមគណនីរបស់គាត់ និងក្រុមហ៊ុនកម្រៃជើងសារឈ្មួញកណ្តាល បានរារាំងជាអចិន្ត្រៃយ៍ពីការធ្វើជំនួញនៅរដ្ឋម៉ាសាឈូសេត Massachusetts ។
- គូស្វាមីភរិយាវ័យចំណាស់ បានទាក់ទងការិយាល័យលេខាធិការ Secretary Galvin ដោយសារតែលុយទាំងអស់របស់ពួកគេត្រូវបានដាក់បញ្ចូលទៅក្នុងប្រាក់ដែលត្រូវបង់ប្រចាំឆ្នាំដោយឈ្មួញកណ្តាលរបស់ពួកគេហើយពួកគេមិនអាចចូលទៅប្រើប្រាស់លុយរបស់ពួកគេបានដោយមិនមានការទទួលរងបង់ថ្លៃឈ្នួលច្រើនឡើយ ។ ការិយាល័យលេខាធិការ Secretary Galvin អាចយកពួកគេចេញពីប្រាក់ដែលត្រូវបង់ប្រចាំឆ្នាំ ដោយមិនចាំបាច់បង់ថ្លៃឈ្នួលឡើយ ។
- បុគ្គលម្នាក់បានបៀតបៀនលើសាច់ញាតិរបស់គាត់ ដើម្បីទទួលបានការគ្រប់គ្រងសរុបលើគណនីឈ្មួញកណ្តាលរបស់ពួកគេ និងលួចលុយរបស់ពួកគេ ដើម្បីប្រើប្រាស់សម្រាប់ការចំណាយផ្ទាល់ខ្លួន ។ ពួកគេបានជូនដំណឹងដល់ការិយាល័យលេខាធិការ Secretary Galvin នៅពេលគាត់បានសារភាពថាអ្វីគាត់បានធ្វើ ហើយការិយាល័យលេខាធិការ Secretary Galvin អាចទទួលបានក្រុមហ៊ុនកម្រៃជើងសារឈ្មួញកណ្តាល ដើម្បីសងប្រាក់ដែលបានលួច ។
- គូស្វាមីភរិយាដែលចូលនិវត្តន៍ម្នាក់ បានជួលទីប្រឹក្សាវិនិយោគម្នាក់ ដើម្បីជួយពួកគេបញ្ជាហិរញ្ញវត្ថុរបស់ពួកគេ ។ គាត់បានដាក់វាចូលទៅក្នុងផលិតផលដែលគាត់បានរកកម្រៃជើងសារដ៏ច្រើន ប៉ុន្តែផលិតផលមិនសមស្របចំពោះតម្រូវការរបស់ពួកគេ ហើយគូស្វាមីភរិយានេះបានទទួលរងថ្លៃឈ្នួលយ៉ាងច្រើន ។ ការិយាល័យលេខាធិការ Secretary Galvin អាចជួយយកពួកគេចេញពីផលិតផល និងយកថ្លៃឈ្នួល សងពួកគេវិញ ។
- មេឈ្មួញកណ្តាលធំៗ បានខកខានផ្តល់ជូនការបង្ហាញព័ត៌មាន និងឯកសារគ្រប់គ្រាន់ដល់អតិថិជនចាស់ៗដែលទាក់ទងនឹងការគិតថ្លៃឈ្នួលពេលបោះបង់ការធានារ៉ាប់រង ដែលពួកគេបានទទួលរងនៅពេលអតិថិជននានាបានផ្លាស់ប្តូរប្រាក់ដែលត្រូវបង់ប្រចាំឆ្នាំដែលអាចប្រែប្រួល ។ ការិយាល័យលេខាធិការ Secretary Galvin អាចមានមេឈ្មួញកណ្តាលចេញសងថ្លៃឈ្នួលពេលបោះបង់ការធានារ៉ាប់រងជូនប្រជាពលរដ្ឋចាស់ៗនៅរដ្ឋ Massachusetts ។
- ក្រុមហ៊ុនមួយបានបង់ប្រាក់បុគ្គលម្នាក់ ដើម្បីផ្សព្វផ្សាយពាណិជ្ជកម្ម និងលក់ប័ណ្ណដែលមានកិច្ចសន្យាដែលមិនបានចុះបញ្ជីរបស់ខ្លួនដែលទាក់ទងនឹងអចលនទ្រព្យជូនដល់អ្នករស់នៅរដ្ឋ Massachusetts ។ ការិយាល័យលេខាធិការ Secretary Galvin អាចឱ្យក្រុមហ៊ុននេះផ្តល់សំណងជូនដល់អ្នកវិនិយោគទាំងអស់នៅរដ្ឋ Massachusetts ហើយបញ្ឈប់ការលក់ប័ណ្ណនៅរដ្ឋ Massachusetts ។ លើសពីនេះទៀត ការិយាល័យរបស់គាត់ បានរារាំងបុគ្គលនេះពីការចូលក្នុងវិស័យមូលបត្រនាពេលអនាគត ។

ប្រសិនបើលោកអ្នកត្រូវការជំនួយ លោកអ្នកអាចទាក់ទងពួកយើងខ្ញុំដោយឥតគិតថ្លៃតាមលេខ 1-800-269-5428 ។

# ជំនួយសម្រាប់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ

រដ្ឋម៉ាសាឈូសេត Massachusetts ព្យាយាមការពារជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ ការរំលោភផ្លូវភេទ ការរំខានឬការបៀតបៀន ដោយជួយពួកគេរៀបចំអាសយដ្ឋានសម្ងាត់ថ្មី ដើម្បីការពារជនល្មើសនៃអំពើហិង្សាពីការស្វែងរកជនរងគ្រោះដែលបានផ្លាស់ប្តូរទីលំនៅ ។

កម្មវិធីនេះ ហៅថាកម្មវិធីភាពសម្ងាត់អាសយដ្ឋាន (ACP) ត្រូវបានគ្រប់គ្រងដោយលេខាធិការសហគមន៍ឯករាជ្យ ។

ដើម្បីបញ្ជាក់ថាជាអ្នកចូលរួមកម្មវិធីម្នាក់នោះ អ្នកដាក់ពាក្យសុំត្រូវបង្ហាញថា ការបង្ហាញព័ត៌មានអំពីអាសយដ្ឋានរបស់គាត់ គំរាមកំហែងដល់សុវត្ថិភាពអ្នកដាក់ពាក្យសុំ ឬកូនៗរបស់អ្នកដាក់ពាក្យសុំ ។ ACP អនុញ្ញាតឱ្យអ្នកចូលរួមកម្មវិធីប្រើអាសយដ្ឋានផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ជំនួសវិញនៅពេលធ្វើការទាក់ទងជាមួយទីភ្នាក់ងាររដ្ឋាភិបាល ។ អាសយដ្ឋានជំនួសនេះ ត្រូវប្រើលំនៅដ្ឋានស្របច្បាប់របស់អ្នកចូលរួមកម្មវិធី ក៏ដូចជាអាសយដ្ឋានកន្លែងធ្វើការងារ និង/ឬ សាលាផងដែរ ។ ហេតុនេះហើយកំណត់ត្រារបស់រដ្ឋាភិបាល អាចត្រូវផ្សព្វផ្សាយដល់សាធារណជនដោយមិនមានការកំណត់អត្តសញ្ញាណកន្លែងថ្មីរបស់ជនរងគ្រោះឡើយ ។

**តើខ្ញុំអាចរកឃើញទីតាំងអ្នកជំនួយដាក់ពាក្យសុំ ដើម្បីចាប់ផ្តើមដំណើរការដាក់ពាក្យសុំដោយរបៀបណា?**

លោកអ្នកអាចហៅទូរស័ព្ទ ACP តាមលេខ 1-866-SAFE-ADD ដើម្បីរកឃើញទីតាំងអ្នកជំនួយដាក់ពាក្យសុំ ។ លោកអ្នកក៏អាចទាក់ទងផងដែរទៅទីភ្នាក់ងារ ឬកម្មវិធីមិនរកប្រាក់ចំណេញដែលផ្តល់ជូនការប្រឹក្សាយោបល់ អ្នកជំនាញត្រូវបញ្ជូនមក ទីជម្រក ឬសេវាកម្មពិសេសផ្សេងទៀតដល់ជនរងគ្រោះពីការរំលោភបំពានក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ ឬការរំខានឬការបៀតបៀនដែលមិនចង់បាន ។

# សេចក្តីប្រកាសសិទ្ធិឯកជនរបស់អ្នកបោះឆ្នោតនៅរដ្ឋម៉ាសាឈូសេត Massachusetts

**សិទ្ធិបោះឆ្នោតរបស់អ្នកត្រូវបានការពារ ។ សិទ្ធិទាំងនេះត្រូវបានធានាដល់អ្នកបោះឆ្នោតដែលចុះឈ្មោះ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។**

1. លោកអ្នកមានសិទ្ធិបោះឆ្នោត ប្រសិនបើលោកអ្នកជាអ្នកបោះឆ្នោតដែលចុះឈ្មោះ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

2. លោកអ្នកមានសិទ្ធិបោះឆ្នោតរបស់អ្នកក្នុងលក្ខណៈដែលធានាសិទ្ធិឯកជនភាព ។ លោកអ្នកមានសិទ្ធិបោះឆ្នោតដោយគ្មានបុគ្គលណាម្នាក់ព្យាយាមមានឥទ្ធិពលលើការបោះឆ្នោតរបស់អ្នក និងដើម្បីបោះឆ្នោតនៅក្នុងបន្ទប់បោះឆ្នោតដែលរាំងអ្នកដទៃពីការមើលឃើញលោកអ្នកគូសសន្លឹកឆ្នោតរបស់អ្នក ។

3. លោកអ្នកមានសិទ្ធិស្ថិតនៅក្នុងបន្ទប់បោះឆ្នោតក្នុងរយៈពេលប្រាំ (5) នាទី បើមានអ្នកបោះឆ្នោតផ្សេងទៀតកំពុងរង់ចាំ និងរយៈពេលដប់ (10) នាទី បើគ្មានអ្នកបោះឆ្នោតផ្សេងទៀតរង់ចាំ ។

4. លោកអ្នកមានសិទ្ធិទទួលបានសន្លឹកឆ្នោតជំនួសរហូតដល់ពីរ (2) សន្លឹក ប្រសិនបើលោកអ្នកធ្វើខុសឆ្គង ហើយខូចសន្លឹកឆ្នោតរបស់អ្នក ។

5. លោកអ្នកមានសិទ្ធិស្នើសុំជំនួយនៅពេលបោះឆ្នោតពីអ្នកណាម្នាក់ពីការជ្រើសរើសរបស់អ្នក ។ ប្រសិនបើលោកអ្នកមិននាំអ្នកណាម្នាក់មកជាមួយលោកអ្នកទេ លោកអ្នកមានសិទ្ធិទទួលជំនួយពីបុគ្គលិករៀបចំការបោះឆ្នោតចំនួនពីរ (2) នាក់ ។

6. លោកអ្នកមានសិទ្ធិបោះឆ្នោត ប្រសិនបើលោកអ្នកជាជនពិការ ។ កន្លែងបោះឆ្នោតត្រូវតែអាចចូលបាន ហើយត្រូវមានបន្ទប់បោះឆ្នោតដែលអាចប្រើប្រាស់បាន ។

7. លោកអ្នកមានសិទ្ធិបោះឆ្នោត ប្រសិនបើលោកអ្នកមិនអាចអាន ឬសរសេរ ឬមិនអាចអានឬសរសេរភាសាអង់គ្លេស ។

8. លោកអ្នកមានសិទ្ធិបោះឆ្នោត ប៉ុន្តែត្រូវបង្ហាញការកំណត់អត្តសញ្ញាណ ប្រសិនបើ ៖ លោកអ្នកជាអ្នកបោះឆ្នោតលើកដំបូង ដែលបានចុះឈ្មោះបោះឆ្នោតតាមប៉ុស្តិ៍ប្រៃសណីយ៍ និងមិនបានដាក់ជូនអត្តសញ្ញាណប័ណ្ណជាមួយសំណុំបែបបទចុះឈ្មោះបោះឆ្នោត; ឬឈ្មោះរបស់អ្នកនៅក្នុងបញ្ជីបោះឆ្នោតអសកម្ម; ឬការបោះឆ្នោតរបស់អ្នកកំពុងមានបញ្ហាប្រឈម; ឬប្រសិនបើបានស្នើសុំដោយបុគ្គលិករៀបចំការបោះឆ្នោត ។ សំណុំបែបបទអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនដែលអាចទទួលយកបាន ៖ ប័ណ្ណបើកបរយានយន្តនៅរដ្ឋម៉ាសាឈូសេត Massachusetts ឯកសារដែលបោះពុម្ពឬព្រីនផ្សេងទៀត ដែលមានឈ្មោះនិងអាសយដ្ឋានរបស់អ្នក ដូចជាវិក្កយបត្រប្រើសេវាប្រចាំថ្ងៃថ្មី បង្កាន់ដៃបង់ប្រាក់ជួលដែលមានលើក្បាលលិខិតរបស់ម្ចាស់ផ្ទះជួល កិច្ចសន្យាជួល ឬឯកសារថតចម្លងមួយច្បាប់ពីការទទួលស្គាល់ឬបង្កាន់ដៃចុះឈ្មោះអ្នកបោះឆ្នោត ។

9. លោកអ្នកមានសិទ្ធិបោះឆ្នោតតាមសន្លឹកឆ្នោតបោះមុនដែលមិនអាចទៅស្ថានីយបោះឆ្នោត ប្រសិនបើ ៖ លោកអ្នកនឹងអវត្តមានពីទីក្រុងឬខេត្តរបស់អ្នកនៅថ្ងៃបោះឆ្នោត; ឬប្រសិនបើលោកអ្នកមានពិការភាពផ្នែករាងកាយដែលរារាំងការបោះឆ្នោតរបស់អ្នកនៅកន្លែងបោះឆ្នោត; ឬប្រសិនបើលោកអ្នកមិនអាចបោះឆ្នោតនៅកន្លែងបោះឆ្នោតដោយសារតែជំនឿសាសនា ។

10. លោកអ្នកមានសិទ្ធិឆ្នោតតាមសន្លឹកបណ្តោះអាសន្នមួយ ប្រសិនបើលោកអ្នកជឿជាក់ថា លោកអ្នកជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប៉ុន្តែបុគ្គលិករៀបចំការបោះឆ្នោតប្រាប់លោកអ្នកថា លោកអ្នកមិនមានសិទ្ធិបោះឆ្នោត ។

11. លោកអ្នកមានសិទ្ធិតាមដានបញ្ហាប្រឈមណាមួយចំពោះសិទ្ធិបោះឆ្នោតរបស់អ្នកតាមរយៈដំណើរការបណ្តឹងតវ៉ា ។

12. លោកអ្នកមានសិទ្ធិបោះឆ្នោត ប្រសិនបើបច្ចុប្បន្នលោកអ្នកមិនជាប់ឃុំឃាំងចំពោះការផ្តន្ទាទោសបទឧក្រិដ្ឋ ហើយបានចុះឈ្មោះជាអ្នកបោះឆ្នោតម្នាក់បន្ទាប់ពីការដោះលែងអ្នក ។

13. លោកអ្នកមានសិទ្ធទទួលយកសេចក្តីប្រកាសសិទ្ធិឯកជនរបស់អ្នកបោះឆ្នោត ឬឯកសារផ្សេងទៀត ដែលរួមមានសន្លឹកឆ្នោតគំរូ មគ្គុទ្ទេសក៍អ្នកបោះឆ្នោត ឬសម្ភារយុទ្ធនាការឃោសនាបោះឆ្នោតចូលទៅក្នុងបន្ទប់បោះឆ្នោតជាមួយលោកអ្នក ។ សូមចងចាំថា ត្រូវយកចេញក្រដាសទាំងអស់នៅពេលលោកអ្នកចាកចេញពីបន្ទប់បោះឆ្នោត ។

14. លោកអ្នកមានសិទ្ធិបោះឆ្នោតនៅកន្លែងបោះឆ្នោតរបស់អ្នកគ្រប់ពេលវេលានៅចន្លោះម៉ោង 7 ព្រឹក និង 8 ល្ងាច សម្រាប់ការបោះឆ្នោតរដ្ឋ និងសហព័ន្ធ—ម៉ោងអាចប្រែប្រួលសម្រាប់ការបោះឆ្នោតនៅមូលដ្ឋាន ។ ប្រសិនបើលោកអ្នកឈរតម្រង់ជួរនៅកន្លែងបោះឆ្នោតរបស់អ្នកនៅពេលកន្លែងបោះឆ្នោតបិទដំណើរការនៅម៉ោង 8 ល្ងាច លោកអ្នកមានសិទ្ធិបោះឆ្នោត ។

15. លោកអ្នកមានសិទ្ធិនាំកូនៗរបស់អ្នកចូលក្នុងបន្ទប់បោះឆ្នោតជាមួយលោកអ្នក ។

ប្រសិនបើលោកអ្នកមានអារម្មណ៍ថាសិទ្ធិបោះឆ្នោតរបស់អ្នកត្រូវបានគេរំលោភបំពានតាមរបៀបណាមួយនោះ សូមហៅទូរស័ព្ទទៅផ្នែកការបោះឆ្នោតនៃលេខាធិការសហគមន៍ឯករាជ្យ តាមទូរស័ព្ទលេខ 1-800-462-VOTE (8683) ។ ហៅទូរស័ព្ទនេះគឺឥតគិតថ្លៃនៅក្នុងរដ្ឋ Massachusetts ។

# ❌ បញ្ជីផ្ទៀងផ្ទាត់អ្នកបោះឆ្នោត ហែកចេញ និងយកទៅកន្លែងបោះឆ្នោត ។

**សំណួរអំពីសន្លឹកឆ្នោត** ▶ សំណួរ 1 ❑ បាទ/ចាស ❑ ទេ សំណួរ 2 ❑ បាទ/ចាស ❑ ទេ សំណួរ 3 ❑ បាទ/ចាស ❑ ទេ

**ការិយាល័យបោះឆ្នោត** ▶ **ការិយាល័យនៅលើសន្លឹកឆ្នោតនៅឆ្នាំ 2018 មានដូចខាងក្រោម ៖**

សមាជិកព្រឹទ្ធសភានៅក្នុងអង្គការនីតិបញ្ញត្តិ ____________________

អភិបាល និងភូឈួយ ____________________

អគ្គព្រះរាជអាជ្ញា ____________________

រដ្ឋមន្ត្រីក្រសួងការបរទេស ____________________

អគ្គហិរញ្ញិក ____________________

សាវនករ ____________________

អ្នកតំណាងនៅក្នុងសភា ____________________

សមាជិកក្រុមប្រឹក្សា ____________________

សមាជិកព្រឹទ្ធសភានៅតុលាការធម្មតា ____________________

អ្នកតំណាងនៅតុលាការធម្មតា ____________________

មេធាវីមណ្ឌល ____________________

ក្រឡាបញ្ជីតុលាការ ____________________

ការចុះបញ្ជីលិខិតប្រគល់កម្មសិទ្ធិ ____________________

ស្នងការខោនធី ____________________
*(ក្រុមប្រឹក្សារដ្ឋាភិបាល Barnstable, Bristol, Dukes, Norfolk, Plymouth, ឬ Franklin)*

អគ្គហិរញ្ញិកខោនធី ____________________
*(ខោនធី Norfolk តែប៉ុណ្ណោះ)*

ការចុះបញ្ជីលិខិតមរតក ____________________
*(ខោនធី Dukes តែប៉ុណ្ណោះ)*

**William Francis Galvin**
Secretary of the Commonwealth
One Ashburton Place, Room 1705
Boston, MA 02108

Non-Profit Org.
ECRWSS
U.S. Postage
**PAID**
Massachusetts
Secretary of the
Commonwealth

OFFICIAL ELECTION MAIL
Authorized by the U.S. Postal Service ®

**OFFICIAL DOCUMENT**

***Residential Customer***
***VOTERS***

**ព័ត៌មានសម្រាប់អ្នកបោះឆ្នោត** ត្រូវបានផ្ញើទៅអ្នកបោះឆ្នោតនានាតាមប៉ុស្តិ៍ប្រៃសណីយ៍ទៅអាសយដ្ឋានលំនៅដ្ឋាន ទៅអ្នកបោះឆ្នោតនានាដែលរស់នៅក្នុងសង្កាត់រស់នៅជាក្រុម និងទីកន្លែងសាធារណៈដែលងាយស្រួលនៅទូទាំងសមាគមន៍ឯករាជ្យ ។ ឯកសារថតចម្លងបន្ថែមដែលមានកំណត់ អាចទទួលបាននៅសាលាក្រុង និងខេត្តនៅមូលដ្ឋាន និងបណ្ណាល័យមួយចំនួន ឬតាមការហៅទូរស័ព្ទទៅផ្នែករៀបចំការបោះឆ្នោតរបស់លេខាធិការ Secretary Galvin តាមទូរស័ព្ទលេខ 617-727-2828 ឬ 1-800-462-VOTE (8683); ឬសេវាកម្មព័ត៌មានអំពីពលរដ្ឋ តាមទូរស័ព្ទលេខ 617-727-7030 នៅតំបន់បូស្តុន Boston ឬ 1-800-392-6090 ។

អ្នកប្រើ TTY សូមហៅទូរស័ព្ទលេខ 617-878-3889 ។ សូមប្រាកដថា ចូលមើលគេហទំព័ររបស់យើង www.sec.state.ma.us ។ ការបោះពុម្ពផ្សាយព័ត៌មានជាភាសាអេស្ប៉ាញនិងចិនសម្រាប់អ្នកបោះឆ្នោត និងការបោះពុម្ពផ្សាយដែលបោះពុម្ពឬព្រីនជាអក្សរធំៗ សម្រាប់អ្នកពិការភ្នែក អាចរកបាននៅតាមលេខទូរស័ព្ទដូចគ្នាផងដែរ ។ ការបោះពុម្ពផ្សាយអូឌីយោ ក៏អាចរកបានពីបណ្ណាល័យសៀវភៅដែលអក្សរសម្រាប់មនុស្សខ្វាក់ និងការនិយាយនៅ Watertown ផងដែរ តាមទូរស័ព្ទលេខ 1-800-852-3133 ។

♻ បានបោះពុម្ពឬបានព្រីនលើក្រដាស់កែច្នៃឡើងវិញ